ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩**

**សវនាការលើកទី៥៧**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយធ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវ៉ែន
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី
លោក ឌុច ផារី
លោក ម៉ាតូ គ្រីស្ពារ
*(Mr. Matteo Crippa)*
កញ្ញា ណាតាចា វិស៊ែល រីសឺ
*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង
លោក អានីស អះមេដ *(Mr. Anees AHMED)*

លោក ពេជ្រ សម្បត្តិ

លោក វាំងសង់ ជីវ៉ាយជ៍ ជេស្មាឯល

*(M.r Jurgen Assmann)*

ហ្សាឆិរី ឡាំពែល *(Mr. Zachery LAMPEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

កញ្ញា ទី ស្រ៊ុនណា

លោក អាឡាំង វែនណឺ

*(Mr. Alain WERNER)*

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស

*(Ms. Fabienne TRUSSES-NAPROUS)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កែវ កូវរតនៈ

# ឧបសម្ព័ន្ធ

# សាក្សី

## លោក សោម ម៉េត

សួរដោយ លោក តាន់ សេណារ៉ុង ផ្តើមពី ........ ទំព័រ ៣

សួរដោយ អានីស អះមេដ ផ្តើមពី ........ ទំព័រ ៦

សួរដោយ កញ្ញា ទី ស្រ៊ុនណា ផ្តើមពី ........ ទំព័រ ១១

 សួរដោយ លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស ផ្តើមពី ........ ទំព័រ ១៧

 សួរដោយ លោក ការ សាវុត្ថ ផ្តើមពី ........ ទំព័រ ១៩

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អានីស អះមេដ | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក ឌុច ផារី | ខ្មែរ |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ | បារាំង |
| លោក សោម ម៉េត | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោកស្រី ស៊ីលយី ស្ទួតហ្សីនស្គី | អង់គ្លេស |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ប្រធានអង្គជំនុំ | ខ្មែរ |
| លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស | បារាំង |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[០៩:០៥:២៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សីឈ្មោះ សោម ម៉េត ជាបន្ត ។

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីធ្វើការសាកសួរដល់សាក្សីរូបនេះ ។ សហព្រះរាជអាជ្ញាមានពេលវេលាសាមសិបនាទីក្នុងការសួរនេះ ។

សូមអញ្ជើញ! តំណាងសហព្រះរាជអាជ្ញាកុំអាលដំណើរការចាំអាឡាំង វ៉ែនណឺ មានបញ្ហាអី ។ អញ្ជើញអាឡាំង វ៉ែនណឺ ។

**លោក អាឡាំង វ៉ែនណឺ៖**

អរុណសួរស្តីអស់លោក លោកស្រីចៅក្រម! ខ្ញុំសូមជូនជារបាយការណ៍ដោយខ្លីបន្ទាប់ពីការកត់សម្គាល់ពីមេធាវីការពារក្តីកាលពីម្សិលមិញ ។ អាទិត្យក្រោយគាត់នឹងលើបញ្ហាទាក់ទងដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្ញុំ គឺE2/50 ហើយខ្ញុំជម្រាបម្សិលមិញថា ខ្ញុំនឹងផ្តល់ឯកសារមួយចំនួនទៅដល់ខាងមេធាវីការពារក្តីឲ្យគាត់ពិនិត្យ ហើយខ្ញុំបានផ្តល់ឲ្យគាត់ហើយ ។ ដូច្នេះហើយ យើងខ្ញុំនឹងដាក់ពាក្យសុំនិងឯកសាររបស់ខ្ញុំនៅថ្ងៃព្រហស្បតិ៍ ដែលជាឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

សូមអរគុណ គ្រាន់តែជាការជូនដំណឹងដល់លោក លោកស្រីចៅក្រម ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។ អញ្ជើញបាទ មានការអីសូមអញ្ជើញ ។ ប្រញាប់ៗដើម្បីឲ្យឱកាសនៃការដេញដោលនេះតាមកម្មវិធីដែលបានគ្រោងទុក ។ បើសិនជាមានការអូសបន្លាយពេលវេលានោះ គឺនឹងកាត់បន្ថយនៃការដេញដោលហើយ ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សណាព្រូស៖**

លោកប្រធាន! ខ្ញុំសូមស្កាត់នៅទីនេះដើម្បីយើងអាចធ្វើការសន្សំពេលវេលារបស់យើងនៅពេលក្រោយ ។ ចំពោះការស្រាវជ្រាវដែលយើងបានធ្វើឡើង នៅក្នុងឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីរបស់យើងខ្ញុំ ។ យើងកំពុងតែពិនិត្យ និងចាត់ចែងលើឯកសារមួយចំនួន។ ប៉ុន្តែ នៅពេលនេះ យើងអាចបញ្ជាក់ជូនថា យើងបានបោះបង់សិទ្ធិស្តាប់សាក្សីE2/82 គឺដើមបណ្តឹងរដ្ឋប្បវេណីE2/82 បោះបង់សិទ្ធិ

ស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ។ ដូច្នេះហើយ យើងខ្ញុំសង្ឃឹមថាយើងខ្ញុំអាចផ្ដល់ឯកសាររបស់ E2/81 ហើយខ្ញុំសង្ឃឹមថាឯកសារនេះនឹងដាក់ជូននៅថ្ងៃស្អែក ហើយប្រសិនបើមិនដូច្នោះទេ គឺយើងនឹងមិនធ្វើការស្ដាប់សាក្សីរូបនេះទេ នៅក្នុងអង្គសវនាការរបស់យើងទាំងអស់គ្នា ។

[០៩:០៩:១៦]

ចំណុចចុងក្រោយ យើងខ្ញុំយល់ច្បាស់ និងប្រុងប្រយ័ត្នអំពីនីតិវិធីរបស់តុលាការទាក់ទងវិធានការការពារ E2/89 ហើយយើងក៏មិនជំទាស់ដែលទៅលើបញ្ហានេះ ដែលគាត់ ថាគាត់នឹងមកបង្ហាញខ្លួនតាមលក្ខណៈសាមញ្ញ ។ ដូច្នេះ យើងមិនចោទជាបញ្ហាទេ។ ហើយយើងខ្ញុំនឹងធ្វើការពិនិត្យ និងចាត់ចែងឯកសារ ហើយនិងបញ្ជូនឯកសារនេះជូនទៅឲ្យខាងមេធាវីការពារក្ដី ឲ្យបានលឿនតាមដែលយើងខ្ញុំធ្វើទៅបាន ។ នេះជាព័ត៌មានខ្ញុំជូនដំណឹង សូមអរគុណលោក លោកស្រីចៅក្រម ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីក្រុមបីឡើងបញ្ជាក់សាជាថ្មីម្ដងទៀតអំពីបញ្ហាដែលលោកស្រីលើកឡើងនេះ ហើយបំណងជាក់លាក់នៃការដែលលោកស្រីសូមលើកឡើងអំពីបញ្ហាទាំងអស់នេះ ។ តើមានបំណងអ្វីទៅ? ហើយតើបញ្ហាណាដែលសូមឲ្យអង្គជំនុំជម្រះពិនិត្យសម្រេចដែរឬទេ? ឬគ្រាន់តែជាការផ្ដល់ព័ត៌-មានមកដល់អង្គជំនុំជម្រះតែប៉ុណ្ណោះ?

**លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្សណាព្រូស៖**

លោកប្រធាន លោកស្រីចៅក្រមជាទីគោរព! ខ្ញុំគ្រាន់តែផ្ដល់ជាការសង្កេតតែប៉ុណ្ណោះ ដើម្បីជួយរៀបចំផែនការសវនាការយើងថ្ងៃទី១៧ ដែលនៅថ្ងៃនោះ យើងនឹងធ្វើការដេញដោលទៅលើគំរូដែលយើងនឹងពិចារណាស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ។

ដូច្នេះ ដើម្បីដោះស្រាយបញ្ហានីតិវិធីរបស់យើងទាំងអស់នេះចំពោះការរៀបចំផែនការរបស់អង្គសវនាការ ។ ខ្ញុំបានលើកឡើងថា យើងនឹងមិនកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី E2/82 នោះទេ ចំពោះខាងខ្ញុំ គឺយើងខ្ញុំមិនកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីរូបនោះទេ ហើយនៅពេលនេះ យើងកំពុងតែពិនិត្យទៅលើឯកសារទាំងឡាយ ប្រហែលជាយើងអាចមានឯកសារនៅថ្ងៃនេះ ឬថ្ងៃស្អែក ហើយឯកសារនេះវាទាក់ទងទៅនឹង E2/81 ហើយប្រសិនបើយើងមិនទទួលបានឯកសារទាក់ទងទៅនឹង E2/81 នោះទេ យើងខ្ញុំសូមបញ្ជាក់ថា ខ្ញុំនឹងមិនកោះហៅសាក្សី E2/81 នោះទេ ។ ប៉ុន្តែប្រសិនបើយើងមានឯកសារ E2/81 យើងខ្ញុំរក្សាជំហរចង់ស្ដាប់សាក្សី E2/81 នោះ ។

ដូច្នេះហើយ ខ្ញុំគ្រាន់តែលើកជាការសង្កេត ហើយយើងខ្ញុំស្នើសុំឯកសារទាំងអស់ទាក់ទងទៅនឹង E2/81 នោះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមសួរបញ្ជាក់ លោកស្រីបានលើកឡើងថា "លោកស្រីនឹងឈប់-- លោកស្រីនឹងមិនស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីមួយនោះទេ ហើយប្រសិនបើមិនមានឯកសារផ្តល់ជូនឯកសារ ផ្តល់ជូនតុលាការនោះទេ លោកស្រីក៏មិនស្តាប់ E2/81 ផងដែរ ។

ដូច្នេះហើយ តើលោកស្រីអាចបញ្ជាក់ទេ ថាការបោះបង់សិទ្ធិស្តាប់នោះ គឺជាការដកពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណីចេញ ឬក៏គ្រាន់ជាការបោះសិទ្ធិ បោះបង់សិទ្ធិដេញដោលទៅលើសាក្សីនោះតែប៉ុណ្ណោះ? ដោយសារតែយើងចង់បញ្ជាក់ឲ្យបានច្បាស់លាស់ ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្ស ណាព្រូស៖**

គឺវាទាក់ទងទៅនឹកការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីពីររូបនោះតែប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត សូមផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសដើម្បីសួរដល់សាក្សីរូបនេះ ។ សូមអញ្ជើញ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ និងស្វាគមន៍លោក សោម ម៉េត ។

**ស៖** សំណួរទីមួយជូនលោក កាលពីម្សិលមិញលោកបានរៀបរាប់នូវការធ្វើទារុណកម្មដ៏ព្រៃផ្សៃនៅក្នុងមន្ទីរឃុំឃាំងក្នុងរយៈពេលដែលលោកបានដើរយាមកាមនៅផ្នែកអគារខាងក្រៅសារមន្ទីរដែលជាមន្ទីរស-២១ នោះ ។ សំណួរសួរលោកថា តើលោកដែលធ្លាប់ឃើញការធ្វើទារុណកម្មដោយដោះអាវអ្នកទោស ហើយចាក់ទឹកពីលើដោយមិនឲ្យស្លៀកពាក់ខោអាវ ស្លៀកតែខោ ហើយបើកកង្ហារទេលោក?

**លោក សោម ម៉េត៖**

**ឆ៖** បាទ, លោក! គឺថាពេលហ្នឹង គឺថាដែលខ្ញុំបាននិយាយ គឺថាសុទ្ធតែរឿងពិតទាំងអស់ហើយ ។ គឺពិតមែន ។

**ស៖** អរគុណលោក ពីព្រោះនៅក្នុងកំណត់ហេតុយកចម្លើយ ស្តាប់យកចម្លើយដោយសហចៅក្រមស៊ើបអង្កេតនោះ ក៏លោកបានថ្លែងជម្រាបជូនលោកសហចៅក្រមស៊ើបអង្កេតពីបញ្ហាដែលការធ្វើទារុណកម្មដ៏ខ្លាំងឲ្យស្លៀកខោខ្លី ហើយចាក់ទឹកពីលើ និងកម្រាលឥដ្ឋ ។ អ៊ីចឹងលោកនៅរក្សាចម្លើយហ្នឹងថាមានទឹកដូច្នោះមែន?

**ឆ៖** បាទ, លោក! គឺរឿងនេះពិតមែន គឺអត់មានពន្លើសទេ ។

**ស៖** អរគុណលោក។ សំណួរទីពីរជូនលោក ថាតើលោកដែលធ្លាប់បាន-- នៅពេលដែលលោកធ្វើជាអ្នកយាមនៅមន្ទីរស-២១ ហ្នឹង លោកធ្លាប់ដែលបានចូលរួមរៀនសូត្រ និងគេណែនាំលោកឲ្យរៀនពីសារាចរអំពីវិន័យការពារខ្មាំង របៀបចាក់សោបន្ទប់ និងវិធានការនានាដែរឬទេលោក?

**ឆ៖** បាទ, លោក! គឺថាពេលហ្នឹងតែងតែមានហើយ ដែលថាក្នុងពេលការប្រជុំជីវភាពអ្វីមួយ គឺថាមានតែប្រធានក្រុម ហើយនិងប្រធានកងហ្នឹង ដែលគេអាចនិយាយណែនាំយើងអំពីវិន័យការពារខ្មាំងកុំឲ្យខ្មាំងរួច ឬមួយកុំឲ្យខ្មាំងអូសទាញបាន ការពារខ្មាំងកុំឲ្យមានខ្មាំងធ្វើកម្មភាពងាប់ ឬមួយយើងដើរហើរសេរីក៏អត់បានដែរ ។ យើងងក់ងុយក៏អត់បាន អាហ្នឹងគឺថាវិន័យរបស់គេ គឺតឹងរ៉ឹងណាស់ពេលហ្នឹង ។ សូមអរគុណ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោក សោម ម៉េត ។ សំណួរបន្ទាប់ សុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញនូវឯកសារមួយ ដែលមានលេខ P00000025 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍បង្ហាញឯកសារដែលមានលេខដូចលោកតំណាងសហព្រះរាជអាជ្ញាជាតិបានស្នើសុំ នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

[០៩:១៧:៣០]

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** លោក សោម ម៉េត នេះគឺជារូបភាពគំនូរ ដែលគូរដោយលោក វ៉ាន់ ណាត អតីអ្នកទោសនៅក្នុងមន្ទីរស-២១ ហ្នឹង ។ កាលពីម្សិលមិញ លោកបានជម្រាបជូនអង្គជំនុំជម្រះ ដែលមានលោកចៅក្រម ឡាវែន៍ គាត់បានសួរលោក ហើយលោកបានរៀបរាប់ថា លោកបានធ្លាប់ឃើញគេធ្វើទារុណកម្មវាយនឹងរំពាក់ ឆក់ខ្សែភ្លើង ដកក្រចក ។ល។ និង។ល។

តើលោកអាចជម្រាបជូនអង្គជំនុំជម្រះនៅពេលនេះបានទេ នូវអ្វីដែលលោកបានឃើញការធ្វើទារុណកម្ម ដកក្រចក ដែលបានលោកជម្រាបជូនអង្គជំនុំជម្រះកាលពីម្សិលមិញតាមរយៈលោកចៅក្រម ឡាវែន៍ ហ្នឹង ថាលោកពិតជាបានឃើញការធ្វើទារុណកម្មដូចរូបភាពនេះ ឬក៏មានវិធីដទៃទៀតផ្សេងក្រៅពីហ្នឹង?

**ឆ៖** បាទ, លោក! គឺថាពេលហ្នឹង គឺថាដែលគេធ្វើទារុណកម្មកន្លែងដែលខ្ញុំឃាមហ្នឹង គឺថាខុសពីកន្លែងដកក្រចក ។ ដកក្រចកហ្នឹង គឺថាដូចថា គេយកអ្នកទោសពីកន្លែងខ្ញុំយកទៅសួរចម្លើយខាងក្រៅ គឺថាមកវិញ គឺថាខ្ញុំមើលឃើញស្លាកស្នាមអ្នកទោសមែន ឃើញដកក្រចក ឃើញវាយរំពាត់ ផ្តៅ ឃើញមែន ។ ព្រោះកន្លែងខ្ញុំអត់ឃើញមានដកក្រចកទេ អត់ឃើញចាក់ទឹកទេ ប៉ុន្តែ អ្នកទោសគឺថាមានការនិយាយហើយពេលហ្នឹង ។ សូមអស់ ។

**ស៖** អរគុណលោក ។ ចុះវិធីដែលគេវាយម្ជុលបារាំងនៅលើក្រចកហ្នឹង តើលោកបានឃើញផ្ទាល់ ឬក៏លោកបានឃើញនៅពេលដែលអ្នកទោសហ្នឹងត្រឡប់មកវិញលោក?

**ឆ៖** បាទ, លោក! គឺថាពេលនុ៎ងអត់មានបានឃើញផ្ទាល់ទេ ឃើញអ្នកទោសហ្នឹងគេបណ្តើរមកទុកកន្លែងខ្ញុំវិញ គឺថាមានឃើញដកក្រចក ឃើញគេដាក់ម្ជុលដាក់អីមែន ។

**ស៖** អរគុណលោក ។ នៅពេលដែលលោកត្រូវបានផ្លាស់ទៅឲ្យនៅព្រៃស តើនៅពេលនោះអង្គភាពរបស់លោក ដែលបានណែនាំលោក និងបញ្ជូនលោកទៅព្រៃសនោះ គេមានបានណែនាំលោកថាកុំឲ្យនិយាយពីព្រឹត្តិការណ៍នានាដែលលោកបានឃើញ បានដឹង បានឮនៅក្នុងមន្ទីរស-២១ ហ្នឹងដែរឬទេលោក?

[០៩:២០:០៥]

**ឆ៖** បាទ, លោក! គឺថាពេលហ្នឹងដែលគេចាត់តាំងឲ្យខ្ញុំទៅនេះ គឺថាគេក៏អត់មានបាននិយាយពីរឿងបញ្ហាកន្លែងមន្ទីរស-២១ យ៉ាងម៉េចៗក៏អត់មានដែរ គឺ ផល គ្រាន់តែប្រាប់ខ្ញុំថា មិត្តឯងរៀបចំសម្ភារៈបាឡូទៅនៅព្រៃស ទៅនៅស្រែ ។ មានតែប៉ុណ្ណឹង ។

**ស៖** អរគុណលោក ចុះនៅពេលដែលលោកទៅដល់ទីនោះ តើលោកអាចរៀបរាប់ជូនអង្គជំនុំជម្រះបានខ្លះៗទេ នូវរចនាសម្ព័ន្ធ និងការគ្រប់គ្រងនៅទីនោះ ។

**ឆ៖** បាទ,លោក! គឺថាពេលដែលខ្ញុំទៅដល់ហ្នឹងគឺថាគេបញ្ចូលទៅក្នុងអង្គភាពខាងធ្វើស្រែខាងយុវជន ។ ដូច្នេះគឺថា ចូលកន្លែងហ្នឹងគឺថាមាន-- គ្មានអ្វីប្លែកហួសពីជីកប្រឡាយ ទប់ទំនប់ អ៊ីភ្លឺទេ ។

គឺថាក្នុងលក្ខណៈដែលនៅក្នុងហ្នឹង គឺថាហូបចុកអីគឺថាវាមិនដែលបានគ្រប់គ្រាន់ទេ ។ គឺថាធ្វើការហ្នឹង វាមិនដែលបានឈប់មុនម៉ោងដែរ ច្រើនតែលើសម៉ោង គឺថាតឹងរ៉ឹងដែរ កន្លែងហ្នឹង ។ បាទចប់ ។

[០៩:២១:៣០]

**ស៖** អរគុណលោក។ ចុះនៅទីនោះដែរហ្នឹងលោកអាចគេចាត់-- លោកដឹងទេ ថាលោកហ្នឹងគេអាចចាត់ចូលទៅក្នុងចំណាត់ថ្នាក់ណាមួយនៃ-- ដែលៗលោកបាននៅព្រៃសន្ទុំង? ចំណាត់ថ្នាក់ដែលមធ្យម ចំណាត់ថ្នាក់ដែលល្អ ឬចំណាត់ថ្នាក់ដែលលោកជាអ្នកមានកំហុសធ្ងន់ធ្ងរដែលអាចគ្រោះថ្នាក់ដល់បដិវត្តន៍គេនោះ?

**ឆ៖** បាទ, ពេលនោះគឺថាខ្ញុំគ្រាន់តែក្តាប់ក្នុងខ្លួនខ្ញុំបានថា ពេលដែលគេបញ្ជូនខ្ញុំទៅនេះគឺថាមិនទាន់ដឹងដល់ចំណាត់ថ្នាក់ខ្ញុំថ្នាក់ណាទេ ក៏គ្រាន់តែខ្ញុំបានដឹងថាខ្ញុំមានពាក់ព័ន្ធបងខ្ញុំគេចាប់មកកន្លែងមន្ទីរ ស-២១ ។ ដូច្នេះគឺថា ដូចខ្ញុំរាយការណ៍ពីមុនអ៊ីចឹង គឺថាមានតែបង ហ៊ុយ ទេដែលអាចប្រាប់ខ្ញុំ ។ ប្រាប់ថា "បងមិត្តឯងមានឈ្មោះអីគេ!" ខ្ញុំថា "ឈ្មោះ សោម ម៉េង" "ហើយនៅណា?" ខ្ញុំក៏ពីមុនមកខ្ញុំអាចដឹងថា គាត់ហ្នឹងនៅព្រលានយន្តហោះកំពង់ឆ្នាំង ។ ប្រាប់ ហ៊ុយ អ៊ីចឹងទៅ ហ៊ុយ គេថា "ឥឡូវគេចាប់មកហើយ ប៉ុន្តែកុំមាត់នៅឲ្យស្ងៀម តែគេដឹងបែកការណ៍ហ្នឹងចាប់មិត្តឯងដាក់គុកទៀតហើយ" ។ ហ្នឹងគ្រាន់តែខ្ញុំចាប់ចំណុចកន្លែងហ្នឹង គឺថាខ្ញុំយល់កន្លែងហ្នឹងបានៗខ្ញុំទៅស្រែហ្នឹង ។ រឿងវាខុសពី-- សូមអរគុណ ។

[០៩:២៣:១១]

**លោក តាន់ សេណារ៉ុង៖**

អរគុណលោក សោម ម៉េត ដែលខ្ញុំអស់សំណួរដើម្បីសួរបន្ត ខ្ញុំប្រគល់តួនាទីបន្ទាប់ទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

អរគុណលោកប្រធានអង្គជំនុំជម្រះ ។

**សួរដោយលោក អានីស អះមេដ៖**

សូមអរគុណលោក សោម ម៉េត ខ្ញុំជាតំណាងសហព្រះរាជអាជ្ញាមួយរូបទៀត ។ ដូចសហសេវិករបស់ខ្ញុំ ដែលខ្ញុំជួយតុលាការនេះស្វែងរកការពិតថា មានអ្វីកើតនៅស-២១ ។ ខ្ញុំសូមថ្លែងអំណរគុណលោកយ៉ាងជ្រាលជ្រៅចំពោះការផ្តល់ការពិតទាំងឡាយ ដូចដែលលោកបានជម្រាបជូនសហចៅក្រមស៊ើបអង្កេត និងនៅចំពោះមុខនៅចៅក្រមនៅទីនេះផងដែរ ។ ហើយនិងនៅពេលដែលលោកបាន

ទៅចុះដល់កន្លែងកើតហេតុដែលដឹកនាំដោយសហចៅក្រមស៊ើបអង្កេត ។ ខ្ញុំនៅទីនេះគ្រាន់តែចង់បញ្ជាក់ទៅលើអ្វីដែលលោកបាននិយាយប្រាប់អ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ដើម្បីឲ្យចៅក្រមនិងសាធារណជនយល់ច្បាស់ថាមានអ្វីកើតឡើងនៅស-២១ ហើយនិងកត់កំណត់ហេតុទៅលើប្រវត្តិសាស្ត្រដែលបានកើតឡើង ។ ដូច្នេះ ខ្ញុំសួរសំណួរឲ្យលោកបញ្ជាក់តែប៉ុណ្ណោះ នូវអ្វីដែលលោកបានប្រាប់អង្គសវនាការ និងអង្គភាពផ្សេងៗដូចជា សហចៅក្រមស៊ើបអង្កេតជាដើម ។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ខែវិច្ឆិកា ប្រហែលពីរឆ្នាំមុនជូនអ្នកស៊ើបអង្កេតលោកបាននិយាយអំពីការសួរចម្លើយបានកើតឡើងដូច្នេះ ។ ដូច្នេះហើយ ខ្ញុំគ្រាន់តែសួរលោកទៅលើពាក្យដែលលោកបានឆ្លើយ ហើយឲ្យលោកបញ្ជាក់ថា តើលោកយល់ថាការសួរចម្លើយនោះគេធ្វើឡើងយ៉ាងដូចម្តេច? ពេលខ្លះទៅ ទុយ គេជាអ្នកសួរចម្លើយ ហើយលោកមិនច្បាស់ថា តើ ឌុច ហ្នឹងមកដោយផ្ទាល់ ហើយនិយាយជាមួយអ្នកទោសឬក៏យ៉ាងម៉េចនោះទេ? តើលោកគិតថានេះកើតពិតប្រាកដដែរឬទេ ទៅលើអ្វីដែលលោកបាននិយាយនោះ?

**ឆ៖** បាទ, លោក! គឺថាពេលដែលខ្ញុំនិយាយក្នុងឯកសារទាំងប៉ុន្មានគឺថាពិតទាំងអស់ ។ អត់មានពន្លើស អត់មានបំផ្លើសបំភ្លៃអីទេ គឺថាមានតែខ្វះវិញផង ។ តាមការនិយាយរបស់ខ្ញុំគឺថា មានខ្វះហើយ ប៉ុន្តែគ្រាន់តថា ខ្ញុំវាយូរឆ្ងាយពេកទៅគឺថាខ្ញុំវាភ្លេចដែរ ពេលហ្នឹង ។ សូមអស់ ។

[០៩:២៥:៥៧]

**ស៖** សូមអរគុណ ។ ខ្ញុំមិនមានន័យថា លោកធ្វើការនិយាយមិនពិតនោះទេ ។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យបានច្បាស់លាស់នូវអ្វីដែលលោកបានជម្រាបអ្នកស៊ើបអង្កេត ដើម្បីឲ្យចៅក្រមនៅពេលសម្រេចនៅក្នុងសាលក្រមនោះគាត់មានចម្លើយពិត ។ ហើយខ្ញុំគ្រាន់តែចង់បញ្ជាក់ថា តើលោកបាននិយាយពិតនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតដែរឬទេ? អ្នកទោសបានលើកឡើងថា គឺគេបានវាយការណ៍អស់ហើយ ហើយគ្មានអ្វីដែលត្រូវវាយការណ៍នោះ ។ ហើយ ឌុច បានទាត់នឹងអ្នកទោសមួយជើង ឬពីរជើងថាអ្នកឯងនឹងដឹង ហើយបន្ទាប់មកគាត់មក ហើយវាយអ្នកទោស ដើម្បីឲ្យអ្នកទោសនោះឆ្លើយ ។ ហើយខ្ញុំសូមសួរលោក ថាតើចំណុចទាំងអស់នោះលោកបានជម្រាបជូនអ្នកស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** បាទ, លោក! គឺថាពេលហ្នឹងខ្ញុំបានជម្រាបខាងផ្នែកខាងស៊ើបអង្កេតអស់ហើយគឺថារឿងនេះសុទ្ធតែពិតទាំងអស់ ។ សូមអស់យោបល់ ។

**ស៖** នៅចំណុចចុងក្រោយដែលខ្ញុំសូមឲ្យលោកបញ្ជាក់ ។ លោកបានជម្រាបអ្នកសួរចម្លើយ--អ្នកស៊ើបអង្កេតថា ប្រសិនបើ ឌុច មិនទៅណាផ្សេងទេ គាត់នឹងមកមន្ទីរឃុំឃាំង ឬគុកនោះគឺសឹងតែរាល់ថ្ងៃ តើលោកបានបញ្ជាក់អ៊ីចឹងដែរឬទេ នៅចំពោះមុខអ្នកស៊ើបអង្កេតនោះ?

**ឆ៖** បាទ, លោក! គឺថា ពេលហ្នឹងខ្ញុំបាននិយាយបញ្ជាក់ដែរ ក៏ប៉ុន្តែ ថាវាមានការជ្រុលមិនបានមកជារាល់ថ្ងៃទេ។ គឺថា គាត់យូរៗមកម្តងទេ ។ បើនិយាយថាជារឿងរាល់ថ្ងៃ គឺថាខ្ញុំសូមទោស ខ្ញុំបាននិយាយជ្រុល ។ សូមអស់ ។

[០៩:២៧:៥៩]

**ស៖** អ៊ីចឹងថាតើគាត់មកញឹកញាយប៉ុនណាដែរ តាមដែលលោកគិត?

**ឆ៖** បាទ, លោក! គឺថាពេលហ្នឹង គឺថាពេលដែលគាត់ចង់ដឹងសំណុំរឿងពីអ្នកទោសអីហ្នឹងគឺថាគាត់មកហើយ។ ជួនកាលដែលគាត់ទំនេរអីគាត់ចេះតែមកដើរលេងមើលតាមបន្ទប់អ្នកទោសហ្នឹង ។ បាទសូមអស់ ។

**ស៖** សូមអរគុណលោកច្រើន លោក សោម ម៉េត ។ ខ្ញុំចាំនូវចម្លើយដែលលោកផ្តល់បីឆ្នាំមុនដែលលោកឆ្លើយជូនអ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្ញុំនឹងមិនអាចចម្លើយនោះជូនលោកនោះទេ ប៉ុន្តែ ខ្ញុំដកប្រយោគមួយនៅក្នុងនោះ ហើយសូមឲ្យលោកបញ្ជាក់ទៅលើប្រយោគនោះ ។ លោកបានជម្រាបអ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារនោះកត់ត្រានៅខែមករា ឆ្នាំ២០០៣ ប្លុកជនបរទេស រួមទាំងអាមេរិកាំងផង គឺត្រូវបានគេដុតនៅតាមផ្លូវខាងលិចស-២១។ តើលោកចាំនូវព្រឹត្តិការណ៍នេះ កើតឡើងនៅពេលនោះដែរឬទេ?

[០៩:២៨:២០]

**ឆ៖** បាទ, លោក! គឺថាពេលហ្នឹងដែលទៅកន្លែងហ្នឹងមានអ្នកកងការពារម្នាក់ហ្នឹង គឺថាគេនិយាយគឺថាខ្ញុំស្តាប់បាន ។ សួរថារឿងឲ្យខ្ញុំឃើញផ្ទាល់ខ្ញុំអត់មានបានឃើញទេ ។ សូមអស់ ។

**ស៖** តើអ្នកយាមនោះប្រាប់លោកផ្ទាល់ថា គាត់បានឃើញគេដុតអ្នកទោសបរទេសនោះ អ៊ីចឹងមែនទេ?

**ឆ៖** អត់មានបានប្រាប់ខ្ញុំទេ គេរាយការណ៍អំពីខាង ផ្នែកខាងឯកសារខ្ញុំស្តាប់បាន។សូមអស់ ។

**ស៖** សូមអរគុណច្រើនដែលលោកបានបញ្ជាក់ ហើយជាថ្មីម្តងទៀត ចំពោះអ្វីដែលលោកបានឆ្លើយការពិតទាំងអស់នេះ ។ នៅពេលនេះ ខ្ញុំចង់សួរបី និងបួនសំណួរទៀតចំពោះអ្នកទោសដែលលោក

គេឱ្យលោកយាម ។ មានភស្តុតាងនៅចំពោះមុខតុលាការនេះថា អ្នកទោសទាំងអស់នោះឱ្យសរសេរចម្លើយសារភាពដែលមានទំព័រវែង ហើយលោកចាំទេថាមានប៊ិក និងឯកសារក្រដាសផ្សេងៗសម្រាប់ឱ្យអ្នកនោះសរសេរនៅពេលដែលលោកយាមនូវអ្នកទាំងអស់នោះ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, លោក! អ៊ីចឹងមែន ។

[០៩:៣១:០០]

**ស៖** តើគេប្រាប់លោកផងដែរទេ ថាអ្នកទោសទាំងអស់នោះ គឺអ្នកទោសសំខាន់ ហើយត្រូវការពារនឹងយកចិត្តទុកដាក់ឱ្យល្អបំផុត ដើម្បីការពារអ្នកទាំងអស់នោះ ។ តើគេមានប្រាប់អ៊ីចឹងទេ?

**ឆ៖** បាទ, លោក! គឺថាពេលហ្នឹងដែលយាមនឹងគឺថា ប្រធានក្រុម ឬប្រធានកងគឺគេប្រាប់យើងថាអ្នកទោសកន្លែងហ្នឹងសុទ្ធតែសំខាន់ៗកុំឱ្យ ការពារកុំឱ្យគ្រោះថ្នាក់ណា បាទមាន ។ សូមអស់ ។

**ស៖** ថាតើ ឌុច មានបានប្រាប់អំពីការការពារអ៊ីចឹងទេ?

**ឆ៖** បាទ, លោក! គឺថាពេលនុ៎ងអត់មានមកប្រាប់ពួកខ្ញុំទេ មានតែបន្តពីគ្នាមកដល់ប្រធានក្រុម ប្រធានកងហ្នឹងទេ ។ ខ្ញុំមិនដែលបាន បងឌុច ណាមកប្រាប់ខ្ញុំទេ គឺថាតាមខ្សែរយៈប្រធានកង ប្រធានក្រុមហ្នឹងទេ ដែលបានមកណែនាំចំពោះអ្នកយាម ។ សូមអស់ ។

[០៩:៣២:១៤]

**ស៖** តើលោកចាំទេ? ថាតើមានឈ្មោះនៃមនុស្សដែលលោកយាម ឬក៏ក្រុមអ្នកយាមជាមួយគ្នាបានយាមទៅចាំឈ្មោះអ្នកទោសណាម្នាក់ដែរឬទេ?

**ឆ៖** បាទ, លោក! អត់ដឹង ព្រោះអីកន្លែងនុ៎ងគឺថាវិន័យគេអត់ឱ្យយើងដឹងទាំងអស់ ។ អ្នកយាមដូចគ្នាក៏អត់មានប្រាប់ថាពីណា ។ សូមអស់ ។

**ស៖** គេបានជ្រើសលោកឱ្យធ្វើការងារដ៏សំខាន់មួយ គឺយាមអ្នកទោសសំខាន់ៗ ។ តើលោកគិតថា គេជ្រើសរើសលោកដោយសារលោកមានគុណសម្បត្តិល្អក្រៅពីអ្នកយាមផ្សេងទៀតដែលថា គេយាមមនុស្សធម្មតា ប៉ុន្តែលោកជាអ្នកយាមអ្នកទោសពិសេសនោះ?

**ឆ៖** បាទ, លោក! គឺថា ពេលហ្នឹងខ្ញុំក៏មិនដឹងថាខ្ញុំនឹងគឺជាយ៉ាងម៉េចដែរ គ្មានទេ គេចាត់តាំងតាមផ្នែកអ៊ីចឹងមកតែម្តង គឺថាអង្គភាពនីរសារហ្នឹងគឺថាមួយចំនួនដែលជាអ្នកចេះអក្សរហ្នឹងគឺថា គេឱ្យទៅខាងកងសួរចម្លើយ ។ អ្នកអត់ចេះអក្សរគេឱ្យមកខាងផ្នែកការពារអ្នកទោស ។ ដូចខ្ញុំជម្រាបខាងដើមអ៊ីចឹងពីមុនអ៊ីចឹង ។ សូមអស់ ។

**ស៖** ខ្ញុំចង់សួរសំណួរមួយ ឬពីរចុងក្រោយអំពីការប្រាស្រ័យ ឬក៏ជួបជាមួយ ឌុច ជាជនជាប់ចោទ ។ លោកបានឃើញគាត់ជាទៀតទាត់ ថាតើគាត់មានអត្តចរិត ឬបុគ្គលិកលក្ខណៈយ៉ាងម៉េច ចំពោះគាត់ទៅលើអ្នកយាម ឬក៏លើបុគ្គលិកនៃស-២១ កាលនោះ?

**ឆ៖** បាទ, គឺថាខ្ញុំមិនបានដឹងជាអត្តចរិតគាត់ជាយ៉ាងម៉េចទេ ។ អត់បានដឹង ។

**ស៖** តើអ្នកយាម ឬក៏មេរបស់លោកមានការភ័យខ្លាចគាត់ទេ? តើម្នាក់ៗមានការភ័យខ្លាចទេ បើសិនជាយើងធ្វើអីដែលប៉ះពាល់ ឬក៏មិនបានល្អទៅតាមចិត្តគាត់នឹងទទួលទោសឬយ៉ាងម៉េច?

[០៩:៣៤:៤៦]

**ឆ៖** គឺពេលហ្នឹង គឺថា ចិត្តគឺថានៅតែខ្លាចគាត់រហូត ពីព្រោះដែលអង្គភាពនីរសារជាមួយគ្នាទាំងអស់ គឺថាហាសិបនាក់ គឺថាខ្ញុំមើលឃើញនៅសល់តែបួនទៅប្រាំនាក់ទេ អស់មិនដឹងទៅណា ។ ពេលហូបបាយបាត់អស់ យូរៗបាត់មួយ យូរៗបាត់ពីរ ។ ហើយដល់អ៊ីចឹង ខ្ញុំតែងតែញញើតគាត់ដែរ ព្រោះអីគាត់អ្នកដឹកនាំ ។ សូមអស់ ។

**ស៖** តើគាត់ជាមនុស្សបែបម៉េច នៅពេលដែលគាត់និយាយទៅអ្នកយាម តើគាត់និយាយរបៀបញញឹម ឬក៏របៀបជាអ្នកមានអំណាច?

**ឆ៖** បាទ,លោក! គឺថាគាត់និយាយគឺមិនមានជាកំហឹង ហិង្សាយ៉ាងណាទេ គឺថាគាត់និយាយក្នុងការដូចថា លេងខ្លះ សើចខ្លះអ៊ីចឹងទៅ ។ សូមអស់ ។

**ស៖** តើលោកបានឃើញថ្នាក់លើណាដែលខ្ពស់ជាង ឌុច ទេនៅស-២១ ជាពិសេសដែលគេមកជួបអ្នកទោសពិសេស ដែលលោកកំពុងតែយាមនោះដែរឬទេ?

**ឆ៖** បាទ,លោក! គឺថាពេលនោះ ខ្ញុំអត់ដែលឃើញអ្នកធំណាលើសពីគាត់មកដែរ ។ ឃើញតែគាត់បងចាន់ ហើយនិងបងហ៊ុំ, ប៉ុន អីនៅទីហ្នឹងទេ ។ បើថាលើសពីហ្នឹងទៀត អត់មានឃើញទេ ។ សូមអស់ ។

**ស៖** ហ្នឹងមានន័យថា ក្នុងរយៈពេលពីរឆ្នាំ ដែលលោកធ្វើជាអ្នកយាមលោកបានឃើញ ឌុច ជាអ្នកកាន់កាប់ស-២១ ហើយជាអ្នកទទួលបន្ទុកជានិច្ច ។ ហើយម្នាក់ៗនៅធ្វើការកន្លែងនោះ គឺសុទ្ធតែភ័យខ្លាចគាត់ទាំងអស់ តើនិយាយអ៊ីចឹងត្រូវដែរឬទេ?

**ឆ៖** បាទ, ត្រូវមែន ។

**ស៖** លោកអាចមិនបានឮ ប៉ុន្តែលោកអាចប្រាប់យើងប្រសិនបើមិនមែន ថាតើ ឌុច ធ្លាប់នៅក្នុងកិច្ចរៀនសូត្រនយោបាយណាមួយដែលលោកធ្លាប់ឮគាត់និយាយថា ប្រសិនបើមានអំពើកំហុសណាមួយនៅស-២១ គាត់នឹងដាក់ទោស-- គាត់នឹងត្រូវទទួលទោសពីថ្នាក់លើរបស់គាត់ ។ តើធ្លាប់ឮគាត់និយាយបែបនោះដែរឬទេ?

**ឆ៖** អត់ដែលឮផង ។

**លោក អានីស អះមេដ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមិនមានសំណួរអ្វីទៀតទេ ហើយសូមអរគុណលោក សោម ម៉េត ដែលលោកបានព្យាយាមឆ្លើយ នូវសំណួរទាំងអស់ដែលខ្ញុំបានសួរ ។

[០៩:៣៧:៥៧]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីអ្នកតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការសាកសួរដល់សាក្សីរូបនេះ ។ សូមអញ្ជើញ ។

**ការតាំងសំណួរដោយក្រុមមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី៖**

**សួរដោយកញ្ញា ទី ស្រ៊ីនណា៖**

ជាបឋម ខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល ។ នាងខ្ញុំសូមជូនដំណឹងទាក់ទងនឹងការ ដែលក្រុមមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការតាំងសំណួរនៅថ្ងៃនេះ ។ នៅក្នុងថ្ងៃនេះ នាងខ្ញុំបានធ្វើការបែងចែកជាពីរក្រុម ដោយមានក្រុមទីមួយ ដែលមានខ្ញុំនឹងធ្វើការសួរសំណួរ និងមានក្រុមទីបី ។ រវាងក្រុមទីមួយនិងក្រុមទីបី នឹងធ្វើការតាំងសំណួរទៅសាក្សីនៅថ្ងៃនេះ ។

**ស៖** នាងខ្ញុំសូមធ្វើការតាំងសំណួរទៅសាក្សី ។ នាងខ្ញុំឈ្មោះ ទី ស្រ៊ីនណា ជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមមួយ និងលោក អាឡាំង វែនណឺ ជាសហមេធាវីនៅក្នុងក្រុមរបស់នាងខ្ញុំ ។ ហើយខ្ញុំសូមគោរពលោក សោម ម៉េត ។ ទាក់ទងទៅនឹងចំណុចមួយដែលនាងខ្ញុំសូមធ្វើការបញ្ជាក់ពីលោកទាក់ទងទៅនឹងឯកសារដែលលោកបានឆ្លើយ នៅការិយាល័យសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ ដែលមានលេខ ERN ជាភាសាខ្មែរ 00163653 និងភាសាអង់គ្លេសដែលមានលេខ 00163663 ។ នៅក្នុងនុំងលោកបានឆ្លើយជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតដែលលោក

បានឆ្លើយថា ពាក់ព័ន្ធទៅនឹងសំណួរគេសួរលោកថា "តាមដែលលោកធ្លាប់ដឹងពីការយាមអ្នកទោសតាមបន្ទប់នីមួយៗ តើលោកធ្លាប់ឮសូរអ្នកទោសស្រែកទេ?" លោកបានឆ្លើយថា "ខ្ញុំឮសូរពេលគេធ្វើទារុណកម្មអ្នកទោស អ្នកទោសក៏ស្រែកអង្វរលន់តួកុំឲ្យគេធ្វើបាប ដោយសុខចិត្តឆ្លើយ សុខចិត្តនិយាយ" ។ តើលោកនៅរក្សាចម្លើយរបស់លោកដែរឬទេ នៅត្រង់ចំណុចនេះ?

**ឆ៖** បាទ,លោក! គឺថាខ្ញុំរក្សាចម្លើយរបស់ខ្ញុំទាំងអស់នេះ ។

**ស៖** ខ្ញុំសូមបន្តការបញ្ជាក់ទៅលើចំណុចមួយទៀត ។ គេបានសួរលោកថា "តើលោកសម្គាល់ឃើញតើអ្នកទោសដែលនៅក្នុងបន្ទប់នីមួយៗ គឺសុទ្ធតែទទួលទារុណកម្មទាំងអស់?" លោកបានឆ្លើយថា "អ្នកទោសទទួលទារុណកម្មទាំងអស់គ្នា គឺមានទារុណកម្មធ្ងន់ធ្ងរជាទីបំផុត ។ ហើយអ្នកយាមពេលឃើញអ្នកទោសគេធ្វើទារុណកម្មក៏មានការភ័យខ្លាចដូចគ្នាដែរ" ។ តើលោកនៅរក្សាចម្លើយរបស់លោកនៅត្រង់ចំណុចនេះដែរឬទេ? ថាតើអ្នកយាមពេលអំឡុងពេលនុ៎ង គឺពិតជាមានការខ្លាចដូចអ្នកទោសដែរឬក៏យ៉ាងម៉េច?

[០៩:៤១:៣១]

**ឆ៖** បាទ,លោក! គឺថាខ្ញុំរក្សាចម្លើយរបស់ខ្ញុំបាទ មកដល់បច្ចុប្បន្ន ។ សូមអស់ ។

**ស៖** ខ្ញុំសូមបន្តសំណួរទៀត ។ កាលពីម្សិលមិញ លោកបានលើកឡើងទាក់ទងទៅនឹងបញ្ហា ទុយ ហើយលោកបាននិយាយថា "ថ្ងៃមួយ ទុយ គាត់យករំពាត់មួយ ហើយវាយទៅលើអ្នកទោស លើខ្នង ហើយនិងវាយរហូតដល់អ្នកទោសហ្នឹងមានឈាមនៅខ្នងនុ៎ង ។ ហើយបន្ទាប់មកៗទៀត ទុយ ក៏បានប្រើឧបករណ៍ផ្សេងៗទៀត ដើម្បីធ្វើទារុណកម្ម ដូចជាយកខ្សែភ្លើងមកឆក់ត្រង់ត្រចៀក ធ្វើឲ្យអ្នកទោសសន្លប់ ។ នៅពេលដែលអ្នកទោសដឹងខ្លួន ទុយ គាត់ថា គាត់នឹងត្រឡប់មកសួរសាឡើងវិញ" ។ ទាក់ទងទៅនឹងចំណុចហ្នឹង ខ្ញុំគ្រាន់តែចង់សួរលោកបញ្ជាក់ថា តើ ទុយ ជាមនុស្សឃោរឃៅ ឬក៏កាចសាហាវព្រៃផ្សៃ ដូចសកម្មភាពហ្នឹងដែរឬយ៉ាងម៉េច? សូមលោកជួយបំភ្លឺ ទាក់ទងទៅនឹងបុគ្គលដែលឈ្មោះ ទុយ ។

**ឆ៖** បាទ,លោក! ដែលខ្ញុំធ្លាប់បាននិយាយបានដឹងពីមុនមក គឺថាខ្ញុំរក្សារបានរហូតដល់បច្ចុប្បន្ននេះ គឺថាជាការសួរចម្លើយ គឺថាតែងតែមានហិង្សាហើយ ។ សូមអស់ ។

**ស៖** តើ ទុយ ពិតជា-- ខ្ញុំគ្រាន់តែចង់សួរលោកថា តើ ទុយ គឺជាបុគ្គលយ៉ាងម៉េចដែរ? គាត់ជាមនុស្សឃោរឃៅ ឬក៏ជាមនុស្សធម្មតា?

**ឆ៖** បាទ,លោក! គឺថាចំពោះ ទុយ គេអ្នកសួរចម្លើយ គឺថាមិនមែនជាមនុស្សធម្មតាទេ គឺថា គេអ្នកសួរចម្លើយសុទ្ធតែមនុស្សឃោរឃៅហើយ ។ សូមអស់យោបល់ ។

**ស៖** តើលោកមានដឹងពីទំនាក់ទំនងរវាង ទុយ ហើយនិងជនជាប់ចោទឈ្មោះ ឌុច តើលោកមានបានដឹងទំនាក់ទំនងបែបម៉េចដែរ?

**ឆ៖** បាទ, លោក! គឺថាអារឿងអ្នកសួរចម្លើយ ហើយនិងបង ឌុច ហ្នឹងក៏ខ្ញុំក៏មិនបានដឹងដែរទេ អត់បានដឹងទេ ។

[០៩:៤៣:៥៨]

**ស៖** តើអំឡុងពេលហ្នឹងនៅពេលដែល ទុយ គាត់ធ្វើសកម្មភាពបែបហ្នឹង តើជនជាប់ចោទឈ្មោះ ឌុច គាត់ពេញចិត្តទៅនឹងសកម្មភាពហ្នឹងដែរឬក៏ទេ? លោកមានបានដឹងពីបញ្ហានេះឬទេ?

**ឆ៖** បាទ,លោក! គឺថាខ្ញុំអត់បានដឹងទេ ។

**ស៖** ខ្ញុំសូមបន្តទៀត ទាក់ទងទៅនឹងបញ្ហាបង ភី លោកបានឆ្លើយនៅក្នុងឯកសារដែលជាកិច្ចសម្ភាសន៍រវាងលោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០២ ដែលមានលេខ ERN 00051666 និង ERN ជាភាសាអង់គ្លេសដែលមានលេខ 00337636 ។ នៅក្នុងឯកសារនៅក្នុងកិច្ចសម្ភាសន៍នោះ លោកបានសម្ភាសន៍ជាមួយនឹងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលគេសួរលោកថា “ពូមានដែលយកបាយទៅឲ្យហើយមានស្គាល់គ្នាទេ?” “លោកបានឆ្លើយថា ជួបៗ តែមេខ្ញុំម្នាក់ គាត់ជាវរសេនាតូច បងភី ។” គេបានសួរលោកថា “ស្អី ភី?” លោកបានឆ្លើយថា “មិនដឹង ស្អី ភី ដែរ ។” ហើយគេក៏សួរលោកបន្តទៀតថា “គាត់ជាប្រធានវរសេនាតូច ឬក៏ធ្វើអីនៅក្នុងវរសេនា-តូច?” លោកក៏បានឆ្លើយថា “គាត់ជាប្រធានវរសេនាតូច៧០៣ ។ យើងនិងណ៎ាហើយកាលឡើយខ្ញុំមិននីរសារគាត់ ដល់ពេលខ្ញុំឃើញអីចឹង ខ្ញុំស្រងាកចិត្តយ៉ាងម៉េចទេ ខ្ញុំខ្លាចចូលខ្លួនឯងទៀតហ្នឹង ខ្លាចគេស្រាវជ្រាវរកខ្សែអីចេះ” ។ ខ្ញុំសូមសួរលោកថា តើមានអ្វីកើតឡើងចំពោះលោក ភី ដែលនាំឲ្យមានការចាប់ខ្លួនគាត់មកដល់មន្ទីរស-២១?

**ឆ៖** បាទ,លោក! គឺថាពេលហ្នឹង គឺថាខ្ញុំវាភ្លេចដែរ ដល់រំឭកអីចឹង ខ្ញុំបាននឹកឃើញដែរ ។ បងភី ហ្នឹងគាត់ជាមេខ្ញុំមែន នៅអង្គភាព៧០៣ហ្នឹង គឺថាអង្កាល់ហ្នឹងនៅសង្គ្រាមឆ្នាំ១៩៧៤-៧៥ ហ្នឹង គឺថាមេខ្ញុំមែន ។ ដល់ខ្ញុំក្រឡេកឃើញគាត់នៅក្នុងក្រោមផ្ទះឈើហ្នឹង ខ្ញុំក៏ខ្ញុំដើរចេញទៅ ។ ខ្ញុំខ្លាចតែលោមានពាក់ព័ន្ធដល់កន្លែងហ្នឹង ខ្លាចតែគាត់ឃើញខ្ញុំទៅ គាត់ពេលគេធ្វើចម្លើយខ្លាំងបានគាត់ឆ្លើយដាក់ខ្ញុំ

ដែរទៅវាពិបាកអ៊ីចឹង ខ្ញុំខំគេចខ្លួនចេញពីហ្នឹង ។ កន្លែងហ្នឹងពិតមែន ។

**ស៖** តើលោកមានបានដឹងថា បុគ្គលិករបស់កង៧០៣មួយចំនួនដែលមកធ្វើការនៅមន្ទីរស-២១ ដែរឬទេ?

**ឆ៖** បាទ,លោក! គឺថាសុទ្ធតែមានទាំងអស់ហ្នឹង ។ មួយអង្គភាពភាពនីរសារហ្នឹងគឺថា សុទ្ធតែនៅក្នុងអង្គភាព៧០៣ ។ ហើយដូច្នេះ គេយកមកលាយគ្នាជាមួយខាងពួកបស្ចិម ខាងកំពង់ឆ្នាំងហ្នឹង គឺខ្ញុំមកក្រោយហ្នឹងគឺថាឃើញមាន ពួកហ្នឹងនៅហ្នឹងមុនហើយ ។

[០៩:៤៧:៥០]

**ស៖** ចុះលោកមានបានដឹងពីបញ្ហាកង៧០៣ ភាគច្រើនគឺមនុស្សរបស់កង៧០៣ ត្រូវបានសម្លាប់នៅក្នុងមន្ទីរស-២១ តើលោកមានបានដឹងពីបញ្ហាហ្នឹងដែរឬទេ?

**ឆ៖** បាទ,លោក! គឺថាពេលហ្នឹង គឺថាតែងតែមានតែងដឹងហើយ ដឹងជាបន្តៗគ្នាទេ គឺថាមិនបានឃើញផ្ទាល់នឹងភ្នែកទេ ។ ដូចជាប្រធានក្រុម ប្រធានកងអីគេចេះតែខស្សាហ៍ប្រាប់ថា ៧០៣ មកអស់ហើយ ។ បាទ, គ្រាន់តែប៉ុណ្ណឹងទេ ។ សូមអស់យោបល់ ។

**ស៖** តើលោកមានបានដឹងថា ចំនួនប្រហែលជាប៉ុន្មាននាក់ដែលបុគ្គលិករបស់កង៧០៣ ត្រូវបានគេសម្លាប់?

**ឆ៖** បាទ,លោក! គឺថាខ្ញុំក្តាប់មិនបានទេពេលហ្នឹង ព្រោះអីខ្ញុំពេលហ្នឹងគឺថា ខ្ញុំអត់បានទៅតាមដានឬមួយមើលទេ គឺថាខ្ញុំក្តាប់មិនបានតែម្តង ។

**ស៖** នៅពេលដែលគេប្រាប់លោកថា មនុស្សកង៧០៣ គេនាំមកអស់ហើយ ។ អ៊ីចឹងនៅក្នុងពេលហ្នឹងពេលដែលលោកឮបែបហ្នឹង តើលោកមានបានបញ្ជាក់បន្ថែមជាមួយនឹងអ្នកដែលគេប្រាប់លោកហ្នឹងថាតើមូលហេតុអ្វីបានជាគេចាប់កង៧០៣ដែរឬទេ?

**ឆ៖** បាទ,លោក! គឺថាពេលហ្នឹងខ្ញុំគ្មានទៅបានបញ្ជាក់អីជាមួយគ្នាឯងហ្នឹងទេ ព្រោះអីការងារនេះគឺថាអត់មានត្រូវដេញដោលសួរគ្នាអីទេ ព្រោះអីវិន័យរបស់គេតឹងរ៉ឹង គេមិនឲ្យយើងនិយាយរកគ្នាផង ។ បាទ,សូមចប់ ។

**ស៖** ម្សិលមិញខ្ញុំបានឮលោក បានឆ្លើយនៅសាលសវនាការនេះ ដោយជម្រាបទៅអង្គសវនាការថា លោកមានករណីតូចមួយដែលបានកើតឡើង គឺទាក់ទងទៅនឹងបុគ្គលិករបស់មន្ទីរស-២១ បានទុកក្រមាចោលនៅលើបង្គួច ហើយក៏បានដើរចេញទៅ ហើយពេលនុ៎ងអ្នកទោសក៏ស្ទុះហក់យកក្រមានោះ

ចង់ចងកសម្លាប់ខ្លួន ប៉ុន្តែលោកមកទាន់ ។ ពេលនុ៎ងលោកក៏បានប្រាប់ថា លោកក៏ព្យាយាមធ្វើការលាក់ការសម្ងាត់នេះ ដើម្បីកុំឱ្យមានការប៉ះពាល់ដល់អ្នកយាមនោះ ។ តើលោកពិតជានិយាយដូច្នេះមែនដែរឬទេ?

**ឆ៖** បាទ,លោក! ខ្ញុំនិយាយពិតមែន ។

**ស៖** តើលោកមានគោលបំណងចង់ជួយបុគ្គលិក ដែលគេទទួលខុសត្រូវក្នុងការយាមអ្នកទោសហ្នឹង តើមែនឬទេ?

**ឆ៖** បាទ គឺថាមែន ។ បើខ្ញុំមិនជួយ បើខ្ញុំមិនលាក់ គឺថាច្បាស់តែគេចាប់បុគ្គលហ្នឹងដាក់គុកវិញហើយ ។ បើមិនដាក់គុកក៏គេនៅកសាងបន្តបន្ទាប់ដែរ ណែនាំបន្តបន្ទាប់ ។ សូមអស់យោបល់ ។

**ស៖** ទាក់ទងទៅនឹង ហ៊ុយ ខ្ញុំចង់សួរលោកថា អម្បាញ់មិញលោក ពីម្សិលមិញក៏ដូចជាពីព្រឹកមិញដែរ លោកបានជម្រាបដល់អង្គសវនាការទាក់ទងទៅនឹង ហ៊ុយ ។ តើជាការពិតដែរឬទេដែល ហ៊ុយ ជួយសង្គ្រោះជីវិតលោក ដែលលោកមានការពាក់ព័ន្ធជាមួយនឹងបងប្រុសរបស់លោក ដែលគេចាប់យកមកដាក់ក្នុងមន្ទីរស-២១ តើ ហ៊ុយ ជាអ្នកជួយសង្គ្រោះជីវិតលោកដោយបញ្ជូនលោកទៅធ្វើស្រែ អ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ, លោក! អ៊ីចឹងមែន ។ បើ ហ៊ុយ មិនជួយ ច្បាស់ជាខ្ញុំជាប់គុកហើយ ។

**ស៖** ពាក់ព័ន្ធជាមួយនឹងការងាររបស់លោកនៅក្នុងមន្ទីរស-២១ តើថ្នាក់លើគេផ្តល់សិទ្ធិ និងអំណាចត្រឹមកម្រិតណាដែរ នៅក្នុងការដែលលោកធ្វើការនៅមន្ទីរស-២១?

**ឆ៖** បាទ,លោក! សុំម្តងទៀត ។ ស្តាប់អត់ទាន់បាន ។

**ស៖** អរគុណ ។ ខ្ញុំនឹងព្យាយាម ។ ទាក់ទងទៅនឹងបញ្ហានៃអំណាច តើថ្នាក់លើរបស់លោក-- ទាក់ទងអំណាចរបស់លោកនៅក្នុងការធ្វើការនៅក្នុងមន្ទីរស-២១ តើថ្នាក់លើ ឬក៏ថ្នាក់ដឹកនាំ គេមានបានផ្ទេរអី ឬក៏ប្រគល់អំណាចមួយចំនួនឱ្យលោកនៅក្នុងសម្រេចធ្វើការងារនៅក្នុងមន្ទីរស-២១ ដែរឬទេ?

[០៩:៥២:៤៩]

**ឆ៖** បាទ, លោក! គឺថា ពេលដែលហ្នឹង គេគ្មានប្រគល់នាទីអីជាក្រុម ជាកងអីទេ គេគ្រាន់តែប្រគល់ជានាទីរបស់ខ្ញុំហ្នឹង គឺថាការពារតែអ្នកទោសទេ ។ សូមអស់ ។

**ស៖** ខ្ញុំសូមសួរបកទៅក្រោយបន្តិច ដើម្បីចៀសវាងកុំឲ្យមានការហួសបន្តិច ។ ខ្ញុំសូមអភ័យទោស ដែលមានការរំលងសំណួរមួយ ។ ខ្ញុំសូមសួរបញ្ជាក់បន្ថែមទាក់ទៅនឹងការដែលលោក-- ទាក់ទងទៅនឹងការដែលដូចជា ហ៊ុយ គាត់ជួយសង្គ្រោះលោកដោយបញ្ជូនលោកទៅកាន់-- ទៅធ្វើស្រែនៅព្រៃសពេលហ្នឹង ហ៊ុយ គាត់អាចជួយលោកបាន ។ តើខ្ញុំចង់សួរថា តើវាអាចដែរឬទេនៅក្នុងការជួយមនុស្សទូទៅក្នុងមន្ទីរស-២១ ដោយប្រើលក្ខណៈបែប ហ៊ុយ គាត់បានធ្វើចំពោះលោក?

**ឆ៖** បាទ, លោក! គឺថាពេលហ្នឹង ចំពោះ បងហ៊ុយ ហ្នឹងគឺថា រឿងដែលគាត់ជួយខាងណាទៀត ក៏ខ្ញុំអត់បានដឹងដែរទេ ។ បើថាចំណែកចំពោះរូបខ្ញុំគឺថា គាត់ជួយ ។ សូមអស់ ។

**ស៖** ខ្ញុំសូមសួរបន្តទៀតទាក់ទងទៅនឹងសិទ្ធិរបស់លោកនៅក្នុងការទំនាក់ទំនងជាមួយថ្នាក់លើ។ តើលោកមានសិទ្ធិជួបជាមួយថ្នាក់លើដោយផ្ទាល់ និងមានសិទ្ធិទទួលបញ្ជាពីថ្នាក់លើដោយផ្ទាល់ ឬក៏លោកទទួលសិទ្ធិ ឬក៏ទទួលបញ្ជាត្រឹមកម្រិតណាដែរ?

**ឆ៖** បាទ, លោក! គឺថាពេលហ្នឹង ខ្ញុំមិនបានទទួលពីបញ្ជាលោកធំណាទេ គឺគ្មានទេ ។ ខ្ញុំត្រឹមតែប្រធានក្រុមទេ ព្រោះខ្ញុំទទួលបញ្ជាត្រឹមហ្នឹងទេ បើគេឲ្យខ្ញុំទៅយាម គឺខ្ញុំទៅយាមហើយ ។ សូមអស់យោបល់ ។

**ស៖** ពាក់ព័ន្ធជាមួយនឹងលទ្ធភាពរបស់លោកនៃការទទួលព័ត៌មានពីថ្នាក់លើ ឬក៏ពីមេក្រុមរបស់លោក តើលោកមានសិទ្ធិទទួលព័ត៌មានត្រឹមកម្រិតណា? តើលោកមានដែរធ្លាប់ទទួលព័ត៌មានពាក់ព័ន្ធនឹងបញ្ហានយោបាយ ឬក៏បញ្ហាស្ថានភាពស្រុកទេសដែលមានជម្លោះ ដូចជាមានសង្គ្រាមជាមួយជនជាតិវៀតណាមអី តើលោកមានលទ្ធភាពនៅក្នុងការដឹងឮបញ្ហាហ្នឹងដែរឬទេ?

**ឆ៖** បាទ,លោក! គឺថាពេលហ្នឹងដែលខ្ញុំគឺថា ខ្ញុំក្តាប់អត់បានទេ។ អត់បានទទួលព័ត៌មានពីណាៗមកគឺគ្មាន ។

**ស៖** ទាក់ទងទៅនឹងសិទ្ធិនៅក្នុងការដើរហើរ ខ្ញុំចង់សួរថា នៅក្នុងអំឡុងពេលហ្នឹង លោកបាននិយាយថា លោកធ្លាប់ឃើញជនជាប់ចោទនៅក្នុងការដែលគាត់ទៅសួរចម្លើយ ឬក៏គាត់ទៅនេះទៅនោះម្តងម្កាល ជាម្តងម្កាល ។ តើរវាងលោកនិងជនជាប់ចោទទាក់ទងទៅនឹងសិទ្ធិដើរហើរវិញ តើវាយ៉ាងម៉េចដែរ? លោកអាចជួយជម្រាបដល់អង្គសវនាការបានដែរឬទេ នៅក្នុងអំឡុងពេលសម័យកម្ពុជាប្រជាធិបតេយ្យ ដែលលោកជាបុគ្គលិករបស់មន្ទីរស-២១?

[០៩:៥៧:០៩]

**ឆ៖** បាទ, លោក! គឺថាពេលហ្នឹងខ្ញុំ ខ្ញុំនិយាយឲ្យត្រង់គឺថា ពេលដែលគាត់ដើរចូលមកគឺថា ខ្ញុំនៅយាមក្ដី ឬមិនយាមក្ដី គឺថាតែងតែមានឃើញហើយ ព្រោះអីគាត់ដើរចូលមកខ្ញុំមិនឃើញយ៉ាងម៉េច បើខ្ញុំនៅយាមហ្នឹងហើយ ។

**ស៖** ខ្ញុំសូមទោសដែលបង្អាក់លោក ប៉ុន្តែខ្ញុំសូមសួរលោកបញ្ជាក់បន្ថែមបន្តិច ទាក់ទងទៅនឹងចំណុចហ្នឹង ខ្ញុំគ្រាន់តែចង់ដឹងទាក់ទងនឹងសិទ្ធិរបស់លោក នៅក្នុងដើរហើរនៅក្នុងមន្ទីរស-២១ ក៏ដូចជាការដើរហើររបស់លោកទៅក្រៅ ។ បើប្រៀបធៀបរវាងលោកនិងជនជាប់ចោទ តើលោកយល់យ៉ាងម៉េចដែរ?

**ឆ៖** បាទ, គឺថាតាមខ្ញុំយល់ គឺថារឿងបញ្ហាជនជាប់ចោទ គឺគាត់ដើរគឺខ្ញុំអត់មានដឹងពីរឿងគាត់សេរី ឬមិនសេរីទេ អាហ្នឹងភារកិច្ចរបស់គាត់ទេ ។ ដូចពេលរបស់ខ្ញុំ គឺថាមានវិន័យរបស់ខ្ញុំ គឺថាដើរចេញក្រៅក៏អត់បានដែរ គឺថាហូបបាយគឺមានតែមកកន្លែងសម្រាកទេ ។ រឿងឲ្យដើរហើរចេញទៅក្រៅតាមថ្នល់ តាមអី គឺគ្មានទេ ។

**កញ្ញា ទី ស្រីនណា៖**

ខ្ញុំសូមតាងនាមឲ្យនាងខ្ញុំតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី សូមថ្លែងអរគុណចំពោះលោកដែលបានឆ្លើយទៅនឹងសំណួរ និងជួយបំភ្លឺដល់អង្គសវនាការនៅក្នុងរឿងក្ដីនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីអ្នកតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ។

**សួរដោយលោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្សូណាព្រូស៖**

សូមសួរស្ដីលោក សោម ម៉េត ខ្ញុំមេធាវី ណាព្រូស មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ។ ខ្ញុំមានសំណួរតែចំនួនតូចប៉ុណ្ណោះចង់សួរលោក ។

**ស៖** លោកបានជម្រាបជូនអង្គសវនាការ និងយើងខ្ញុំអំពីលក្ខខណ្ឌ និងស្ថានភាពដែលលោកធ្វើការនោះវាមានលក្ខណៈយ៉ាប់យ៉ឺន ហើយជាពិសេសទៅ គឺលក្ខខណ្ឌការងារដែលលោកធ្វើការយាមអ្នកទោសពិសេស ។ ខ្ញុំចង់សួរលោកថា ថាតើលក្ខខណ្ឌ និងស្ថានភាពឃុំខ្លួនរបស់អ្នកទោសផ្សេងនៅក្នុងអគារឃុំឃាំងផ្សេងនោះមានស្ថានភាពយ៉ាងម៉េចដែរ?

[០៩:៥៩:៤៦]

**ឆ៖** បាទ, លោក! គឺថាខាងអគារខាងក្នុងផ្សេងហ្នឹង ខ្ញុំអត់បានដឹងទេ ។

**ស៖** តើលោកអត់បានជជែកគ្នាជាមួយនឹងអ្នកយាមផ្សេង អំពីបញ្ហាស្ថានភាពអ្នកទោសនៅបន្ទប់ផ្សេងទេឬ?

**ឆ៖** បាទ, គឺថាពេលហ្នឹងអត់បានជជែកអត់បានទាក់ទងគ្នាទេ ពីព្រោះគឺថា វិន័យរបស់គេតឹងរ៉ឹងណាស់ គេមិនឱ្យយើងយាមអ្នកទោសឱ្យដឹងយាមអ្នកទោស ។ ពីរឿងដើរទាក់ទងគ្នាតាមបន្ទប់ៗអ្នកទោស គឺថាអត់មានទេ ។

**ស៖** សូមអរគុណលោក សោម ម៉េត ។ លោកក៏បានលើកឡើងនៅក្នុងចម្លើយរបស់លោកផងដែរថា ឌុច ទទួលខុសត្រូវលើអ្នកទោស លើការចូលរបស់អ្នកទោស និងការចេញរបស់អ្នកទោស ។ ហើយលោកបានដឹងអំពីបញ្ហានេះ ទោះបីជាលោកមិនដឹងភារកិច្ចរបស់គាត់ជាក់លាក់ក៏ដោយនៅកន្លែងណា តើលោកដឹងតាមរបៀបណាអំពីចំណុចនេះ?

**ឆ៖** បាទ, លោក! គឺថាពេលដែលខ្ញុំដឹងនេះ ដឹងតាមចំណុចដូចថា ប្រធានកង ប្រធានក្រុមទេ ដែលគេប្រជុំហ្នឹងៗ គេមានផែនការចេញមកពីតែបង ឌុច ទេ ។ បើថាខុសពី បងឌុច មិនដឹងថាមានផែនការពីណាដែរបន្តៗគ្នាមក តាមតា ហ៊ា មក តាមបង ហ៊ុយ, ស្រ៊ុ ហ្នឹងទេ ។ សូមអស់យោបល់ ។

**ស៖** លោកក៏បានលើកឡើងផងដែរថា លោកបានឃើញការធ្វើទារុណកម្ម ដោយសារតែនៅពេលដែលលោកយាមនោះ លោកបានមើលតាមពន្លឺថ្ងៃ ហើយឃើញនូវព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងបន្ទប់ ។ ហើយលោកក៏ជាមនុស្សម្នាក់ដែលផ្តល់ព័ត៌មានផ្សេងៗមួយចំនួនដែលអ្នកយាមមិនបានផ្តល់ឱ្យគេ ។ ហើយទាក់ទងទៅនឹងការធ្វើទារុណកម្មអ្នកទោសនោះ គឺលោកបានបញ្ជាក់ថា ការឆក់ទៅលើប្រដាប់ភេទរបស់អ្នកទោស ។ តើលោកអាចបញ្ជាក់ទៅលើការលើកឡើងរបស់លោកដូច្នេះដែរឬទេ? ហើយតើលោកអាចជម្រាបបន្ថែមថា លោកបានឃើញអ្វីខ្លះ នៅពេលដែលគេឆក់ប្រដាប់ភេទផ្សេងៗនោះ? តើលោកអាចជម្រាបបានទេ ថាលោកបានឃើញព្រឹត្តិការណ៍អ៊ីចឹងនោះបានប៉ុន្មានដងដែរ?

**ឆ៖** បាទ,លោក! គឺថាពេលហ្នឹងដែលខ្ញុំសូមបញ្ជាក់ឱ្យច្បាស់ថា ពេលដែលខ្ញុំឃើញ ខ្ញុំដឹងហ្នឹង គឺថា ដឹងទៅហើយ ប៉ុន្តែគ្រាន់តែដល់បច្ចុប្បន្ននេះ ខ្ញុំមិនអាចនិយាយបានទៀតទេ គឺខ្ញុំនិយាយហើយៗ ។ សូមអស់យោបល់ ។

**ស៖** សូមអរគុណ ។ លោកសូមឱ្យលោកបញ្ជាក់ចំណុចនេះម្តងទៀត ការយល់ឃើញរបស់ខ្ញុំនោះគឺថាលោកគឺជាសាក្សីម្នាក់ប៉ុណ្ណោះដែលអាចផ្តល់ការបញ្ជាក់ដូច្នេះ ។ ដូច្នេះ នៅពេលនេះខ្ញុំចង់សួរសំណួរផ្ទាល់មួយទៅកាន់លោក តើលោកមានអារម្មណ៍យ៉ាងម៉េចនៅពេលដែលលោកដឹងថា បងរបស់

លោកនោះត្រូវគេចាប់ខ្លួន?

**ឆ៖** បាទ, លោក! គឺថាពេលដែលខ្ញុំដឹងពីរឿងចាប់ខ្លួនបងខ្ញុំមក គឺថាអារម្មណ៍របស់ខ្ញុំគឺថាតែងតែមានហើយ គឺថាក្តុកក្តួលតក់ក្រហល់ គឺថាលែងចង់គិតពីការងារផង ។ ប៉ុន្តែ ដោយសារខ្ញុំបាន ហ៊ុយ គេណែនាំមកថា “កុំមាត់កុំក សុខចិត្តឲ្យងាប់តែម្នាក់ទៅ កុំឲ្យងាប់ដល់ពីរនាក់នោះ។ ចាំគេជួយលាក់” ។ ពេលហ្នឹង គឺថាពេលបញ្ចប់ ។

[១០:០៥:១៦]

**ស៖** សូមអរគុណ ។ នៅពេលនេះខ្ញុំសូមនិយាយអំពីព្រៃសម្តង ។ តើលោកបានដឹងដែរឬទេថា នៅពេលដែលលោកធ្វើការនៅព្រៃស មានគេដោះលែងអ្នកទោសនៅទីនោះដែរឬទេ?

**ឆ៖** បាទ, លោក! គឺថាពេលហ្នឹង ខ្ញុំទៅនៅកន្លែងហ្នឹង មិនដឹងកន្លែងណាអ្នកទោស កន្លែងណាគេគុកផង ។ ខ្ញុំទៅហ្នឹងអត់ដឹងព្រៃសហ្នឹង ដឹងថាធ្វើស្រែ ហើយដល់សួរខ្ញុំអ៊ីចឹង ខ្ញុំអត់ដឹង ។

**ស៖** សូមអរគុណលោកសោម ម៉េត ខ្ញុំពុំមានសំណួរសម្រាប់លោកទៀតទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តី ប្រសិនជាមានសំណួរត្រូវសួរដល់សាក្សីរូបនេះ សូមអញ្ជើញ ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី៖**

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាននិងសូមគោរពលោកប្រធាន សូមគោរពចៅក្រមជាតិ និងអន្តរជាតិ ហើយសូមគោរពអង្គសវនាការទាំងមូល ។

**ស៖** លោក សោម ម៉េត លោកថា ហ៊ុយ ជួយលោក បើ ហ៊ុយ រាយការណ៍ពីលោក គឺលោកត្រូវចប់ ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, លោក អ៊ីចឹងមែន ។

**ស៖** អ៊ីចឹង រឿងចាប់បុគ្គលិកស-២១ បើមេក្រោមៗ បានន័យថា មេប្រធាន ខ ប្រធាន ក អីនឹងហូរហែរហ្នឹង មិនរាយការណ៍ឲ្យតា ឌុច គឺតា ឌុច គាត់អត់ដឹងទេ អ៊ីចឹងមែនទេ?

**ឆ៖** ហ្នឹងរឿងហ្នឹងវាមានបញ្ហា បើសិនណាខាងក្រោមមិនរាយការណ៍ឲ្យ តាឌុច ក៏ តាឌុច មិនអាចចាប់បានដែរ ។ ព្រោះរឿងបញ្ហាដែលដឹងនេះ គឺថាសុទ្ធតែក្នុងការប្រជុំជីវភាពនីមួយៗ តែងតែមាន

ហើយពីគុណសម្បត្តិនិងគុណវិបត្តិ ។ ដល់តែគុណវិបត្តិវាច្រើនពេកទៅ គឺថាតែងគេស្រាវជ្រាវតាមតែគុណសម្បត្តិ គុណវិបត្តិហ្នឹង ។ តែគុណវិបត្តិតែងតែខុសហើយ ដល់តែខុស គេស្រាវជ្រាវ វាញឹកញាប់ខ្លាំងពេក គេតែងគេចាប់ខ្លួនហើយពេលហ្នឹង ។ បាទ, សូមអរគុណ ។

[១០:០៨:១៩]

**ស៖** សូមអរគុណ។ លោកជាអ្នកយាម តើនៅតាមបន្ទប់ដែលលោកយាម តើលោកដែលឃើញវិន័យសន្តិបាលទាំង១០ “ខ” ឬទេ? សូមលោកបញ្ជាក់មើល តើលោកដែលឃើញទេ?

**ឆ៖** ខ្ញុំរឿងថា វិន័យប៉ុន្មាន“ខ”ហ្នឹង គឺថាខ្ញុំមិនទាន់បានដឹងទេ ព្រោះអីខ្ញុំវាភ្លេចអស់ហើយពេលហ្នឹង វាយូរឆ្នាំហើយ ។ គឺថាវិន័យតែងនឹងមានហើយ តាំងពីដើរហើយ ដេក ឈរ អង្គុយ និងការហូបចុកគឺថាតែងតែមានហើយ និយាយ ។ គឺថាគ្រាន់តែដឹងថាប៉ុន្មាន “ខ”ៗ ខ្ញុំអត់បាត់ដឹងទេ ខ្ញុំភ្លេចហើយយូរហើយ ។

**ស៖** សូមអរគុណ ។ សូមបញ្ជាក់ម្តងទៀត វិន័យសន្តិបាលទាំង១០ “ខ” ដែលខ្ញុំសួរលោកនេះ គឺវិន័យសន្តិបាលនោះ គេបិទ ឬក៏គេសរសេរនៅបន្ទប់យាម នៅបន្ទប់សួរចម្លើយហ្នឹង? ឧបមាដូចថា គេសួរអីត្រូវឲ្យឆ្លើយហ្នឹង មិនត្រូវបង្វែងដាននអីអ៊ីចឹងឧទាហរណ៍ ។ តើលោកមានដែលឃើញវិន័យហ្នឹងគេសរសេរនៅជញ្ជាំងទុកសម្រាប់ឲ្យអ្នកសួរមើលទេ?

**ឆ៖** បាទ,លោក! គឺថាពេលហ្នឹង គឺថាអត់ដែលឃើញគេសរសេរជញ្ជាំងទេ ខ្ញុំដឹងតែប្រជុំទេ ។ គឺថាវិន័យមានតែប្រជុំទេ បានមាន បើថានៅតាមសរសេរជញ្ជាំង គឺថាគ្មានទេ វិន័យសន្តិបាល គឺថាក្រែងលោមានគេខាងក្នុងទៀតបានមាន គឺខាងខ្ញុំអត់មានទេ ។

**ស៖** បាទ, សូមអរគុណលោក ។ ឯកសារ D28/3 ERN 00163563 លោកបានប្រាប់អ្នកស៊ើបអង្កេតថា ធ្វើទារុណកម្មវាយអ្នកទោសឲ្យឆ្លើយ បើមិនឆ្លើយទេ គេធ្វើទារុណកម្មអ្នកទោសទាល់តែស្លាប់ ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ, លោក! គឺថាចម្លើយរបស់ខ្ញុំ គឺថាពិតមែន ។ សូមអរគុណ ។

**ស៖** សូមអរគុណលោក ។ តើលោកដែលឃើញអ្នកសួរចម្លើយ ធ្វើទារុណកម្មអ្នកទោសទាល់តែស្លាប់ ឬទេ?

**ឆ៖** បាទ, លោក! គឺថាដែលអ្នកសួរចម្លើយអ្នកទោស គឺថាមិនបានដល់ស្លាប់ទេ គឺថាគ្រាន់តែគេសួរចម្លើយអស់ហើយ គឺថាគេយកចេញ ។ រឿងវាយដំច្រំផាក់ពេលសួរចម្លើយហ្នឹង គឺអត់មាន អត់

មានគ្រោះថ្នាក់អីស្លាប់ទេ គ្មាន ។ សូមអស់យោបល់ ។

**ស៖** សូមអរគុណ ។ អ៊ីចឹង ចម្លើយរបស់លោកដែលលោកឆ្លើយនៅអ្នកស៊ើបអង្កេតថា បើអ្នកទោសមិនឆ្លើយទេ គេធ្វើទារុណកម្មអ្នកទោសទាល់តែស្លាប់ ។ អ៊ីចឹង នៅពេលសវនាការនេះ លោកបានបញ្ជាក់ជូនអង្គសវនាការថា គេសួរចម្លើយ គេអត់មានវាយឲ្យស្លាប់ទេ ។ អ៊ីចឹង លោកយកចម្លើយនៅពេលសវនាការនេះ ឬមួយយកចម្លើយនៅពេលដែលអ្នកអង្កេតសួរលោក? សូមលោកបញ្ជាក់ លោកយកចម្លើយមួយណា?

[១០:១១:៣៩]

**ឆ៖** បាទ, គឺថាពេលហ្នឹង គឺថាខ្ញុំយកចម្លើយពេលដែលស៊ើបអង្កេតហើយ ព្រោះអីពេលនោះគឺថាពេលដែលខ្ញុំមានពេលឱកាសល្អ ដែលខ្ញុំត្រូវនិយាយ គឺថាពេលនេះខ្ញុំឱកាសមិនសូវល្អទេ ព្រោះអីខ្ញុំនិយាយអត់កើត ។

**ស៖** សូមអរគុណ ។ អ៊ីចឹង ចម្លើយលោកនៅពេលសវនាការនេះលោកអត់យកទេ គឺលោកយកចម្លើយពេលដែលអ្នកស៊ើបអង្កេតសួរលោក ។ សូមអរគុណ ។

ឯកសារ D28/3 ERN 00163653 លោកប្រាប់អ្នកស៊ើបអង្កេតថា ពេលធ្វើទារុណកម្មទាល់តែឆក់ខ្សែភ្លើង ទើបមានអ្នកទោសសន្លប់ បើវ៉ៃអត់មានសន្លប់ទេ ។ សូមលោកជួយបញ្ជាក់មើល ហេតុអីបានជាវាយអត់សន្លប់?

**ឆ៖** បាទ, លោក! ខ្ញុំសូមបញ្ជាក់លោកថា ពេលវាយរំពាត់ផ្តៅនេះ គឺថាមិនអាចសន្លប់ទេ គឺថាបើឆក់ គឺសន្លប់មែន ។ សូមអស់យោបល់ ។

**ស៖** សូមអរគុណ ។ លោកធ្វើការនៅស-២១ តើលោកស្គាល់ពេទ្យស-២១ ទេ? ហើយពេទ្យស-២១ មានពេទ្យជាស្ត្រីអេទទេ? ហើយមានពេទ្យជាកុមារទេ? បានន័យថា កុមារពេទ្យ ។ សូមលោកបញ្ជាក់មើល ។

**ឆ៖** បាទ,លោក! ខ្ញុំសូមបញ្ជាក់ពីរឿងបញ្ហាពេទ្យ គឺថាពេទ្យ ខ្ញុំស្គាល់តែពេទ្យ ទ្រី មួយទេ ដែលពេទ្យប្រុស ដែលគាត់ឧស្សាហ៍ចូលទៅកន្លែងគុកពិសេសហ្នឹង គឺថាពេទ្យស្រី ឬពេទ្យកុមារអ្វីមួយ គឺថាខ្ញុំអត់ដែលបានដឹងទេ ព្រោះអីកន្លែងខាងក្នុងគេមែន ។ បាទ, សូមអរគុណ ។

**ស៖** សូមអរគុណលោក ។ លោកយាមនៅស-២១ តើលោកដែលឃើញ តា ឌុច នេះ សម្លាប់អ្នកទោសណាម្នាក់ដោយផ្ទាល់ដៃ ដែលលោកឃើញហ្នឹងភ្នែកឬទេ?

**ឆ៖** បាទ, លោក! គឺថាខ្ញុំអត់ដែលឃើញគាត់ទេ ។ សូមអស់យោបល់ ។

**ស៖** សូមអរគុណ ដែលលោកឆ្លើយថាមិនដែលឃើញ តាឌុច សម្លាប់អ្នកណាដោយផ្ទាល់ដៃនោះទេ ។ នៅស-២១ តើលោកដឹងទេ អ្នកធំណាខ្លះខ្ញុំសួរអ្នកធំណាខ្លះដែលនៅពីលើ តា ឌុច ដែលបញ្ជា តា ឌុច? សូមលោកបញ្ជាក់ ។

[១០:១៤:៣០]

**ឆ៖** បាទ, លោក! ខ្ញុំសូមបញ្ជាក់ថា ពេលដែលខ្ញុំជាឋានៈយុទ្ធជននេះ គឺថាខ្ញុំមិនអាចដឹងរឿងអ្នកធំពីលើពី តាឌុច ទេ គឺខ្ញុំមិនដែលឃើញ ។ ព្រោះខ្ញុំយាមអ្នកទោសនៅខាងក្នុង មិនដែលអ្នកធំមកខាងក្រៅមិនដឹង ក៏ខ្ញុំអត់ដឹងដែរ ។ ដឹងឃើញតែ តាឌុច ហើយ តាហ៊ី ហើយនិង តាចាន់ អ៊ី នៅក្នុងមន្ទីរហ្នឹង ។ សូមអស់យោបល់ ។

**ស៖** បាទ, សូមអរគុណ ។ លោកជាអ្នកយាម តើលោកដែលទទួលបញ្ជាអីផ្ទាល់ពីរតា ឌុច ឬទេ?

**ឆ៖** បាទ, លោក! គឺថាពេលនេះខ្ញុំ ភារកិច្ចខ្ញុំមិនដែលបានទទួលបញ្ជាពី បងឌុច ទេ អត់ទេ ។ ទទួលបញ្ជាតែពីប្រធានក្រុមរបស់ខ្ញុំ ដែលថាពេលខ្ញុំយាមកាមនេះ ។ សូមអស់យោបល់ ។

**ស៖** សូមអរគុណ ដែលលោកថាមិនដែលបានទទួលបញ្ជាផ្ទាល់ពី តាឌុច ហើយទទួលបញ្ជាតែពីប្រធានក្រុមរបស់លោក ។

ពេលនោះ បានសេចក្ដីថាពេលយាមនៅស-២១ តើលោកពេញចិត្តនឹងការងាររបស់លោក ឬទេដែលលោកយាមអ៊ីចឹង ហើយលោកពេញចិត្តនឹងការងារយាមហ្នឹងឬទេ? សូមលោកបញ្ជាក់ ។

**ឆ៖** បាទ, លោក! ខ្ញុំសូមបញ្ជាក់លោកឲ្យច្បាស់ថា ពេលនៅកន្លែងនេះ បើថាក្នុងចិត្តរបស់ខ្លួនគឺថាមិនពេញចិត្តទេ ក្នុងការកាប់សម្លាប់ ក្នុងការចាប់មនុស្សនេះ គឺថាអត់ពេញចិត្តទេ ។ ចិត្តខាងក្នុង គឺថាអត់ពេញចិត្ត បើខាងក្រៅ គឺថាបើយើងមិនពេញចិត្ត គឺច្បាស់តែចាប់ដាក់គុក ។ សូមអស់យោបល់ ។

**ស៖** សូមអរគុណលោកដែលឆ្លើយថាលោកមិនពេញចិត្តនឹងការងារដែលយាមនៅស-២១ទេដូចអ្នកមុនៗដែរ ។ សូមអរគុណ ។ ឥឡូវនេះនៅពេលហ្នឹង តើលោកមានការសោកស្ដាយចំពោះការងារយាមអ្នកទោសនៅស-២១ ឬទេ? តើលោកមានការសោកស្ដាយទេ?

**ឆ៖** បាទ,លោក! គឺថាអ្នកធ្លាប់នៅជាមួយគ្នា បាយចានជាមួយគ្នា តែងតែសោកស្ដាយហើយ។ បើនិយាយរួមទៅ គ្នាមិនដឹងជាទោសពៃរ៍អីផង ចាប់គ្នាដាក់គុក ។ បើតាមការបញ្ជាក់របស់ខ្ញុំ គឺថាគ្មាន

ត្រូវនឹងចាប់ដាក់គុកផង ។ នេះប្រើគោហើយសម្លាប់គោទៀត មិនដឹងធ្វើម៉េចអ៊ីចឹង ។ សូមអស់យោបល់ហើយ ។

[១០:១៧:១១]

**ស៖** សូមអរគុណដែលលោកបានឆ្លើយថា លោកមិនបានពេញចិត្តនឹងការងារនៅស-២១ ទេ ។ អ៊ីចឹងខ្ញុំសូមសួរលោកបន្ថែមទៀត ថាបើលោកមិនពេញចិត្តទេ ហេតុអីក៏លោកមិនលួចរត់ចេញពីស២១ទៅ? សូមលោកបញ្ជាក់មើល ។

**ឆ៖** បាទ, លោក! ខ្ញុំសូមមានយោបល់ ។ ពេលដែលរត់រួចនេះ គឺថាមិនដឹងរត់ទៅណាទេ ខាងក្រៅរបង ខាងក្នុងរបង ហើយឲ្យខ្ញុំរត់ទៅណា ។ បើខ្ញុំរត់រួច ឪពុកម្តាយខ្ញុំ គឺថាបងប្អូនខ្ញុំនៅស្រុកហ្នឹង គឺច្បាស់ជាងាប់ហើយ គ្មាននៅទេ ស្រាវជ្រាវចាប់យកមកដាក់គុកហ្នឹង ទាល់អស់ ។ សូមអរគុណ ។

**ស៖** សូមអរគុណ ។ តើបុគ្គលិកដែលយាមនៅស-២១ ឬក៏បុគ្គលិកទូទៅដែលលោកធ្លាប់ គ្រាន់តែគេមិននិយាយ តើគេពេញចិត្តហ្នឹងការងាររបស់គេ ហើយគេរត់មិនរួចដូចលោកអ៊ីចឹងដែរឬយ៉ាងម៉េច? សូមលោកជួយបញ្ជាក់ ។

**ឆ៖** បាទ, ពេលនេះ គឺថាខ្ញុំស្មានក្នុងចិត្តគេអត់ត្រូវទេ ។ គឺក្នុងម្នាក់ៗ គឺថាអត់ទុកចិត្តគ្នាទេ បើទុកគ្នាវិញ គឺថាមិនបានដល់ប៉ុណ្ណឹងទេ ។ សូមអស់យោបល់ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ ។ សូមឲ្យលោកប្រធានបង្វែរទៅឲ្យលោកស្រីមេធាវីអន្តរជាតិមេត្តាសួរបន្ត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីមេធាវីការពារក្តីអន្តរជាតិ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

សូមអរគុណលោកប្រធាន។ មេធាវីការពារក្តីពុំមានសំណួរបន្ថែលមសម្រាប់សាក្សីរូបនេះទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះផ្តល់ឱកាសដល់ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់នូវសក្ខីកម្មរបស់សាក្សីរូបនេះ ប្រសិនបើជនជាប់ចោទមានបំណង ។ សូមអញ្ជើញ ។

[១០:២០:០០]

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ខ្ញុំសូមបញ្ជាក់ថា ខ្ញុំអត់ដែលស្គាល់ មិត្តម៉េត ទេ ។ នៅពេលដែលតទល់គ្នា ដែលលោកចៅក្រមស៊ើបអង្កេត លោកនាំទៅ ខ្ញុំដឹងថា មិត្តម៉េត ប្អូនមិត្ត ម៉េង ។ ដោយឃើញសម្បុរសំបក រាងរៅប្រហាក់ប្រហែលគ្នា ខ្ញុំទទួលស្គាល់ ថាពិតជាបុគ្គលិករបស់ស-២១ មែន ។ ហើយនៅកងពិសេស ផ្នែកយាមគុកនៅខាងក្រៅ ។ នឹកពេលឃើញមុខ មិត្តម៉េត ខ្ញុំរន្ធត់ នឹកសោកស្តាយជីវិតមិត្តម៉េង ហើយនិងប្រពន្ធឈ្មោះ នាង ពឿន ដែលស្លាប់នៅស-២១ ។ ហើយនឹកអាណិតអាសូរដល់ម៉េត ដែលធ្លាក់ខ្លួនពីកងការពារនៅកងពិសេស ទៅជាមនុស្សដែលគេតាមដាន គេស៊ើបអង្កេតនៅ ស-២១-- នៅឯស្រែ ។ នេះអារម្មណ៍ចំពោះមិត្ត ម៉េត គឺអ៊ីចឹង ។

ទីពីរ ខ្ញុំសូមបញ្ជាក់អំពីសក្ខីកម្មរបស់ មិត្តម៉េត ។ សក្ខីកម្មរបស់ មិត្ត ម៉េត ជារួម គឺត្រឹមត្រូវ ។ដោយឡែកអំពីបញ្ហាដែរថា ដែលខ្ញុំចូលទៅធ្វើទារុណកម្មអ្នកទោសនៅកន្លែងហ្នឹង មិត្តទុយ ។ ខ្ញុំមិនដោះសារទេ គ្រាន់តែសូមបញ្ជាក់ការពិត តើវាយ៉ាងម៉េច? ក្នុងឋានៈខ្ញុំជាប្រធានមន្ទីរស-២១ ឧក្រិដ្ឋកម្មដែលខ្ញុំបាទយល់ថាធ្ងន់បំផុត គឺបទឧទ្ទេសនាមនយោបាយដែលខ្ញុំបំពាក់បំប៉នទៅគេ ។

ឧទាហរណ៍ បទឧទ្ទេសនាមថ្ងៃ១៨ កុម្ភៈ ១៩៧៦ ដែលខ្ញុំយកពួកអ្នកតស៊ូក្រុងមក ហើយកំចាត់ទស្សនៈត្រឹមត្រូវរបស់ពួកគេ ដាក់ទស្សនៈឧក្រិដ្ឋឲ្យគេវិញ ។ ទស្សនៈត្រឹមត្រូវគឺអី? តើមនុស្សដែលចាប់មក គ្នាខ្មាំងមែន ឬមិនមែន? នេះទស្សនៈត្រឹមត្រូវរបស់គេ ។ ឯចំណែក ខ្ញុំយកទស្សនៈឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជាទៅដាក់ឲ្យគេ ។ មនុស្សទាំងអស់ណាដែលបក្សចាប់មកហើយ ត្រូវចាត់ទុកជាខ្មាំង បើមិត្តឯងមិនចាត់ទុកជាខ្មាំងទេ មិត្តឯងសួរចម្លើយមិនចេញទេ ។ នេះឧក្រិដ្ឋកម្មដែលធ្ងន់ធ្ងរបំផុតលើសអ្វីទាំងអស់ដែលខ្ញុំទទួលទៅលើជាងអាយុជីវិតមនុស្សជាងមួយម៉ឺននាក់ គឺនៅត្រង់ហ្នឹង ធ្ងន់ជាងគេ ។

បន្ទាប់មកទៀត ឧក្រិដ្ឋកម្មមួយទៀត ដែលធ្ងន់បន្ទាប់ពីនោះ គឺខ្ញុំសរសេរចារឯកសារ មនុស្សនៅរស់ មនុស្សនៅមានសេរីភាព ។ ខ្ញុំសរសេរឯកសារទៅជូនមេ មេជាអ្នកសម្រេចមែន ប៉ុន្តែឯកសារហ្នឹងវាចេញពីដៃខ្ញុំ ទៅជូនមេ ។

ដូច្នេះ ឧក្រិដ្ឋកម្មទៅលើមនុស្សដែលនៅមានសេរីភាពនោះ វាធ្ងន់ជាងឧក្រិដ្ឋកម្មទៅលើមនុស្សដែលគេសម្រេចចាប់ចងរួចមកហើយ ។ នេះឧក្រិដ្ឋកម្មទៅលើមនុស្សជាងមួយម៉ឺននាក់ វាស្ថិតនៅលើ

បញ្ហាពីរនេះជាសំខាន់ ។

បញ្ហាទីបី ឧក្រិដ្ឋកម្មទាំងអស់នៅស-២១ ជាធ្វើទារុណកម្មសួរមផ្លើយបែបណាក៏ដោយ ជាការកងពិសេសនាំយកអ្នកទោសពីភ្នំពេញយកទៅកម្ទេចនៅជើងឯកក៏ដោយ វាស្ថិតនៅក្របខ័ណ្ឌដែលខ្ញុំគ្រប់គ្រង អ្នកឯងមិនធ្វើតាមបញ្ជាខ្ញុំ អ្នកឯងអត់បានទេ ។

ដូច្នេះ សរុបមកឧក្រិដ្ឋកម្មទាំងអស់នៅ ស-២១ ខ្ញុំអត់វាទេ ខ្ញុំទទួល ។ ក៏ប៉ុន្តែដោយឡែក នៅក្នុងអង្គភាពណាក៏ដូចអង្គភាពណា ក្នុងសង្គមណាក៏ដូចក្នុងសង្គមណា មនុស្សម្នាក់ៗបំពេញការងារតែមុខនាទីរបស់ខ្លួន។ អ្នកយាមអត់បំពេញការងាររបស់អ្នកសួរបានទេ លើសសមត្ថភាពខ្លួន ខុសមុខជំនាញ។ អ្នកសួរជ្រែកខ្លួនទៅយាមផងមិនបានទេ ។ ដូច្នេះ ថ្នាក់ដឹកនាំរបស់មន្ទីរស-២១ ទាំងមូលជ្រែកខ្លួនទៅសួរផ្ទាល់អត់បានទេ ទោះបីចង់យ៉ាងណាក៏ដោយ ក៏ទៅមិនបានដែរ ។ នេះខ្ញុំសូមបញ្ជាក់ជាទូទៅគឺអ៊ីចឹង ខ្ញុំមិនរារែកខ្លាចថា អ៊ូ! ជាប់ឧក្រិដ្ឋកម្មទៅវ៉ៃអ្នកទោសដោយផ្ទាល់ដៃនេះ វាឧក្រិដ្ឋកម្មធ្ងន់ មិនមែនទេ ។ ខ្ញុំអត់ខ្លាចទេ ឧក្រិដ្ឋកម្មទាំងអស់ ខ្ញុំទទួល ។ ក៏ប៉ុន្តែនេះ គ្រាន់តែសូមបញ្ជាក់ ។ ខ្ញុំទៅមែនកន្លែងសួរ នៅពេលដែលបង ម៉ម ណៃ គាត់ទទួលភារកិច្ចសង្ខេបចម្លើយ ខ្ញុំទៅ ។ នៅពេលដែលខ្ញុំធ្វើការនៅកន្លែងខ្ញុំហាត់ ខ្ញុំទៅសំកុកនោះបួនប្រាំមីនុត ទៅតម្រង់ចង្កេះនៅហ្នឹងឯង ប៉ាវអ៊ីកាច់ដែលគាត់ទុកឲ្យខ្ញុំ រួចហើយខ្ញុំត្រឡប់មកវិញ អាហ្នឹងមែនញឹកញាប់ ។ ដល់ក្រោយមក នៅកន្លែងហ្នឹង បង ម៉ម ណៃ ហ្នឹង មានឯកឧត្ដម ចៅ សេង ដែលខ្ញុំទុកនៅទុំង មួយខែពីរខ្ញុំទៅអើតគាត់មួយម្ដង អាហ្នឹងមានមែន ។

ដោយឡែកកន្លែង មិត្តប៉ុន ខ្ញុំតាមខ្ញុំចាំ ខ្ញុំទៅពីរដង ។ ម្ដងនោះ គឺខ្ញុំឲ្យ មិត្តប៉ុន ក្រោយពីសួរចម្លើយបង តួច ភឿន រួចហើយ ។ បង តួច ភឿន វិស្វករ ហើយជាអ្នកកំពង់ធំដូចខ្ញុំដែរ ផ្ទះគាត់នៅអាចារ្យលក្ខណ៍ ក្បែរផ្ទះដែលខ្ញុំទៅស្នាក់នៅកំពង់ធំ ។ ដល់សួរបង តួច ភឿន ហើយអស់ក្រមរដំបៅ ដែលគេវ៉ៃគេអ៊ីៗខ្លះហើយ ខ្ញុំឲ្យ មិត្តប៉ុន រៀបចំ បង តួច ភឿន ឲ្យខ្ញុំទៅជួបគាត់។ គោលបំណងខ្ញុំចង់ដឹងថាតើហេតុដូចម្ដេចបានជា ខៀវ សំផន គោរព ប៉ុល ពត ខ្លាំងម្ល៉េះ? ព្រោះគេអ្នកជើងស្រុកបារាំងដូចគ្នា ។ មិត្ត ប៉ុន ក៏រៀបចំឲ្យខ្ញុំ ខ្ញុំទៅបង តួច ភឿន គាត់ពន្យល់ថា អ្ហ៎! ខៀវ សំផន នេះ មនុស្សក្នុងបន្ទប់គោរពកោតខ្លាចបង ប៉ុល ហ្នឹងខ្លាំងណាស់ ។ ដូច្នេះ ចម្លើយបង តួច ភឿន គាត់មិនឆ្លើយនឹងសំណួរខ្ញុំថាហេតុដូចម្ដេចទេ? គាត់បែបជាអធិប្បាយអំពីយ៉ាងដូចម្ដេចទៅវិញ ។ នេះលើកទីមួយដែលខ្ញុំទៅបន្ទប់សួរចម្លើយរបស់មិត្ត ប៉ុន ។

ទីពីរ នៅពេលដែល មិត្តប៊ុន គេសួរចម្លើយជនជាតិអង់គ្លេសម្នាក់ ដែលមកជាមួយនឹងយុវជនណូវែលហ្សេឡង់ម្នាក់ ។ ជនជាតិអង់គ្លេសនោះឈ្មោះ-- ភ្លេចបាត់ទៅទៀតហើយ សុំទោស ។ ជនជាតិអង់គ្លេសនោះ មកជាមួយជនជាតិ ណូវែលហ្សេឡង់ ដល់ឥឡូវ មិត្តប៊ុន គេមកប្រាប់ខ្ញុំថា អ្ហឺ! អង់គ្លេសនោះ សុភាពរាបសាណាស់បង បងឯងទៅមើលមួយភ្លែតទៅ ដូចខ្មែរយើងអ៊ីចឹង ។ ជនជាតិណូវែលហ្សេឡង់ នោះ ខ្ញុំទៅចាំ ឈ្មោះ យុវជន អាល់មីល ។ ដល់ទៅខ្ញុំទៅ ឃើញមែនគាត់ស្លូតបូតរាបសាអ៊ីចឹងមែន ខ្ញុំទៅមើលឃើញ ។ នេះខ្ញុំទៅពីរដង កន្លែងមិត្ត ប៊ុន ។

ដោយឡែកកន្លែងមិត្ត ទុយ ខ្ញុំអត់ទៅទេ ខ្ញុំដឹង ខ្ញុំធ្វើមេគេ មិនមែនខ្ញុំភ្លាប់មិនបានទេ។ មិត្តទុយប្រើហិង្សាធ្ងន់ណាស់ទៅលើអ្នកទោស ក៏ប៉ុន្តែ ខ្ញុំបើមិនមែនចេះតែខុសជើងយកដៃ ខុសជើងយកជើងខុសដៃយកដៃទេ ។ ប៉ុន្តែ ខ្ញុំតាមចាំ ខ្ញុំទៅម្តងកន្លែង មិត្តទុយ នៅពេលដែលមានលេខាស្រុកទឹកផុស ទៅចាប់មក មិត្តនោះ ឈ្មោះ ចៅ វ៉ាន ឈ្មោះដើម ចៅ វ៉ាន ហៅ ឃឹម ។

[១០:២៧:៥២]

សូមបញ្ជាក់ប្រវត្តិរូប ចៅ វ៉ាន បន្តិច ។ ចៅ វ៉ាន នោះ គេជាអ្នកតស៊ូចាស់ គេអាយុច្រើនជាងខ្ញុំពីរបីឆ្នាំ បីបួនឆ្នាំ ជំនាន់ ដាំ ផេង ។ ចៅ វ៉ាន នេះ ជាមិត្តភក្តិរបស់ សឺន វិសុទ្ធ ហៅ នី កន ប្អូនពៅរបស់មេខ្ញុំ ប្អូនពៅរបស់លោកគ្រូ សុន សេន ។ នៅពេលដែល ចៅ វ៉ាន ត្រូវគេចាប់ មេខ្ញុំតែតាំងពីជើងមេឃមក ប្រាប់ឲ្យខ្ញុំទៅធ្វើនយោបាយបញ្ចុះបញ្ចូល ចៅ វ៉ាន ឲ្យសារភាពឲ្យស្រួលទៅ ខ្ញុំក៏សុខចិត្តទៅ ។

តាមខ្ញុំចាំ ចៅ វ៉ាន មានទាំងសរសេរថា ខ្ញុំទៅជួបគាត់ ហើយគាត់រង់នៅចាំខ្ញុំ នៅក្នុងចម្លើយសារភាពរបស់គាត់ទៀតផង ។ ក៏ប៉ុន្តែ វាជាចម្លើយសារភាពខ្ញុំមិនលើកយកមកជូនអង្គសវនាការទេ ក៏ប៉ុន្តែខ្ញុំជឿថា មាននៅក្នុងសេចក្តីសារភាពរបស់ ចៅ វ៉ាន ពីរឿងខ្ញុំទៅជួបគាត់ ។ ចៅ វ៉ាន នោះ ហៅ ឃឹម ។ សូមបញ្ជាក់បន្តិចទៀតថា ឃឹម នេះ ជាឈ្មោះបដិវត្តន៍របស់ ដាំ ផេង ។ ចៅ វ៉ាន ក៏ពួកម៉ាក ដាំ ផេង, សឺន វិសុទ្ធ ហៅ កន ក៏ពួកម៉ាក ដាំ ផេង មិត្តម្នាក់ទៀត ក៏ពួកម៉ាក ដាំ ផេង ប្រើឈ្មោះ ឃឹម ទាំងអស់គ្នា ។ សរុបមក ខ្ញុំទៅកន្លែង មិត្តទុយ ម្តង នៅពេលដែលទៅជួប ចៅ វ៉ាន ហៅ ឃឹម ឯកសារនៅមាន ។ ក៏ប៉ុន្តែ ជាទូទៅខ្ញុំមិនទៅ ឯកសារក៏នៅមាន ។

ខ្ញុំសូមលោកប្រធានអនុញ្ញាតឲ្យគេបញ្ចាំងឯកសារជាកំណត់ហេតុរបស់ មិត្តទុយ ។ លេខ 000 77513 នៅលើអេក្រង់ដើម្បីឲ្យទាំងអស់គ្នាបានឃើញ អំពីមតិខ្ញុំដែលជួយ មិត្តទុយ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍ ដាក់បញ្ចាំនូវឯកសារ ដែលមានលេខ ERN00077513 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

មន្ត្រីតុលាការសម្របសម្រួលជាមួយនឹងខាងផ្នែកសោតទស្សន៍ ។ យ៉ាងម៉េច អាចធ្វើបានទេ?

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ខ្ញុំសូមអានខ្លួនឯង ។ នេះជាមតិ ខ្ញុំកសាងមិត្ត ទុយ ។ គាត់បង២១ ហ្នឹង គឺសំដៅខ្ញុំ មានមតិជួយគាត់ៗ ។ ខ្ញុំមានមតិជួយគាត់ គឺថាពួកពិសេសនេះ មានមិត្ត ប៉ុន ជាមនុស្សទីមួយ ។ គាត់មិនសរសេរមិត្ត ប៉ុន តាមពាក្យខ្ញុំនិយាយទេ គាត់សរសេរ បងប៉ុន ។ នេះ ការចាត់តាំងរបស់ខ្ញុំពេលនោះ ។ បានន័យថា ខ្ញុំអត់បានចុះទៅទេ បានជាមិត្ត ទុយ ត្អូញ ហើយខ្ញុំចាត់តាំងមិត្ត ប៉ុន ឱ្យទៅជំនួស ។ នេះមិត្ត ទុយ ក៏ត្អូញ ។ សូមអានបន្ទាត់ទីពីរ ។ ពេលណាទេ៖

បងៗខាងលើចុះទៅជាប់ គួរណាស់មានបញ្ហា រញ៉េរញ៉ៃ ។ នេះគឺមតិខ្ញុំ ដែលជួយមតិមិត្ត ទុយ ។ នេះគឺមកពីទស្សនៈបម្រើមហាជន ជាកម្មករ កសិករ សមូសហាភាព យើងមិនទាន់មានទស្សនៈរឹងប៉ឹងខ្លាំងក្លានៅឡើយ ។ នេះការដែលខ្ញុំជួយមិត្តទុយ មតិមិត្ត ទុយ ។

ខ្ញុំសូមមិននិយាយតវែងទៅទៀតទេ ឯកសារនេះ វាជាឯកសាររបស់ស-២១ ។ ដូច្នេះ វាបញ្ជាក់ថាខ្ញុំអត់បានចុះទៅទេ ហើយជួយពង្រឹងមតិមិត្ត ទុយ ពង្រឹងគោលជំហរមិត្ត ទុយ កុំឱ្យពឹងផ្អែកលើគេ ក៏ប៉ុន្តែឥឡូវ មិត្ត ទុយ នៅ-- កន្លងមកមិត្ត ទុយ មានទស្សនៈមួយទៀត គឺពឹងផ្អែក ។ ផុតពីពឹងផ្អែកលើខ្ញុំ ពឹងផ្អែកលើមិត្ត ប៉ុន ។ ខ្ញុំសូមឱ្យបញ្ចាំងតទៅទៀត មួយទំព័រចុងក្រោយ ។ មួយទំព័រក្រោយនេះតទៅទៀត គឺលេខទំព័រ 00077514 ទំព័របន្ទាប់ហ្នឹងៗ ។

[១០:៣៣:២៤]

មូលហេតុទីពីរ មួយ, ពីរ, បី, បួន, ប្រាំ, ប្រាំមួយ, ប្រាំពីរ ។ បន្ទាប់ទីប្រាំពីរនេះ មូលហេតុទីពីរ ។ ផ្អែកព្រួសពេលឃើញមិត្ត ប៉ុន ទៅ ។ ដល់ផ្អែក យើងបាត់អស់ហើយ ទិសបម្រើប្រជាជន ដូច្នេះទម្លាប់បង ទុយ គឺអ៊ីចឹង ឱ្យតែឃើញអ្នកពីខាងលើទៅ គាត់ផ្អែកព្រួសទៅលើគេ ។

សរុបមក នេះជាសភាពការណ៍ធ្វើការងាររបស់មិត្ត ទុយ ។ ខ្ញុំជឿហើយ ខ្ញុំក៏ដឹងដែរ មិត្ត ម៉េត មានយោបល់ពីរឿងមិត្ត ទុយ ធ្វើទារុណកម្មធ្ងន់ធ្ងរ ។ ខ្ញុំជឿ ខ្ញុំក៏ដឹងខ្លួនឯង តែមិនដឹងធ្វើយ៉ាងម៉េច ក៏ប៉ុន្តែមិត្ត ទុយ អន្ទងអន្ទោលចាំខ្ញុំ ។

ឯកសារនេះវាបញ្ជាក់ថា ខ្ញុំអត់បានទៅទេ ។ នេះកន្លែងមិត្ត ទុយ ។ ទោះបីជាខ្ញុំមានឯកសារបញ្ជាក់យ៉ាងនេះក៏ដោយ ខ្ញុំនៅតែទទួលស្គាល់ថា មិត្ត ម៉េត ជាយុវជនម្នាក់របស់មន្ទីរស-២១ ដែលមានរងទុក្ខធ្ងន់ធ្ងរបំផុត ។ បងហើយនិងបងថ្លៃត្រូវចាប់ សួរចម្លើយ និងកម្ទេច ខ្លួនឯងធ្លាក់ខ្លួនពីកងពិសេសទៅជាអ្នកអប់រំសារថ្មីនៅព្រៃស ។

ខ្ញុំសូមសម្តែងសន្តានចិត្ត ដ៏ជ្រាលជ្រៅចំពោះមិត្ត ម៉េត នៅក្នុងពេលនេះ ដោយគោរព ។

**ប្រធានអង្គជំនុំ៖**

ការស្តាប់សក្ខីកម្មរបស់សាក្សី សោម ម៉េត ឃើញថាដល់ទីបញ្ចប់ហើយ ។ អង្គជំនុំជម្រះអរគុណដល់លោក សោម ម៉េត ដែលលោកបានអញ្ជើញមកចូលរួមផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមការកោះហៅ ហើយអង្គជំនុំជម្រះក៏បានយល់ដឹងផងដែរថា នៅខណៈពេលដែលលោកមកឆ្លើយឲ្យការណ៍នូវចំពោះមុខអង្គជំនុំជម្រះ គឺមានស្ថានភាពលំបាកប្រឈមជាច្រើនទៅនឹងសំណួររបស់អង្គជំនុំជម្រះ ក៏ដូចជាសំណួរភាគីដែលមានសិទ្ធិចូលរួមនៅក្នុងដំណើរការនីតិវិធីនៅក្នុងរឿងក្តីនេះ ដូចអ្វីដែលលោក សោម ម៉េត បានបញ្ជាក់អំពីចឹងគឺពេលនេះ គឺលទ្ធភាពរបស់លោកក្នុងការផ្តល់សក្ខីកម្មហ្នឹង គឺមិនដូចកាលពីលោកបានផ្តល់សក្ខីកម្មនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យចៅក្រមស៊ើបអង្កេតនោះទេ ។

ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា លោក សោម ម៉េត បានប្រឹងប្រែងអត់ធ្មត់ ព្យាយាមក្នុងការឆ្លើយទៅនឹងសំណួរទាំងឡាយដែលពាក់ព័ន្ធទៅនឹងអង្គហេតុ តាមតម្រូវការនៃអង្គសវនាការទាំងមូល ។ ហើយអង្គជំនុំជម្រះអស់សំណួរត្រូវសួរដល់លោកទៀតហើយ ដូច្នេះ អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកត្រឡប់ទៅកាន់លំនៅដ្ឋានវិញ ។

មន្ត្រីតុលាការសម្របសម្រួលជូនលោក សោម ម៉េត ទៅជួបប្រាស្រ័យទាក់ទងជាមួយនឹងខាងការិយាល័យគាំពារសាក្សី និងអ្នកជំនាញ ដើម្បីរៀបចំចាត់បញ្ជូនគាត់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញបន្ទាប់ពីសម្រាកនេះ ។

ហើយឥឡូវនេះ ដល់ម៉ោងត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការនីតិវិធីសវនាការតទៅទៀត ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:៣៧ នាទីដល់ម៉ោង ១១:០១ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ កិច្ចនីតិវិធីបន្តនេះ គឺស្តាប់សក្ខីកម្មសាក្សីដែលមិនត្រូវបានកោះហៅឲ្យចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដោយចាត់ឲ្យក្រឡាបញ្ជីអាននូវខ្លឹមសារនៃកំណត់ហេតុសាក្សីទាំងនោះ ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ។

ក្រឡាបញ្ជី ឌុច ផារី អាននូវកំណត់ហេតុសក្ខីកម្មសាក្សី ម៉ក់ ស៊ីធីម ឯកសារ D28/8 ហើយបន្ទាប់មកគឺ D54 ។

**លោក ឌុច ផារី៖**

ឯកសារលេខ 28/8 នេះគឺជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ ស៊ីធីម កើតឆ្នាំ ១៩៥៧ ។ កំណត់ហេតុនេះបានធ្វើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧ ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សួរ-ឆ្លើយ៖

ស.ស ជាអក្សរកាត់របស់អ្នកស៊ើបអង្កេតឈ្មោះ ស៊ឹម សុរិយ៉ា ។ សូមនិយាយពីគ្រួសាររបស់លោកមុនឆ្នាំ១៩៧៥?

ម.ស.ធ ជាអក្សរកាត់របស់សាក្សីឈ្មោះ ម៉ក់ ស៊ីធីម ។ គ្រួសារខ្ញុំមានជីវភាពល្មមហូបគ្រប់គ្រាន់ ។

ស.ស៖ ហេតុផលអ្វីដែលនាំឲ្យលោកចូលបដិវត្តន៍?

ម.ស.ធ៖ ក្រោយ១៧ មេសា ខ្ញុំនៅជាកុមារមិនទាន់ចេះ ស្លៀកខោត្រឹមត្រូវទេ ។ គេឲ្យទៅរែកបាយនៅវាលចារ រួចទៅបានចូលកុមារ ។ ពីរខែក្រោយមកគណៈស្រុកឈ្មោះ អ៊្លង នៅជំនាន់បដិវត្តន៍យកខ្ញុំទៅស្រុកពីរយប់ និងយកទៅសាលាលេខប្រាំពីរយប់ យកទៅប្រាំមួយឡានកាត់ចិន ។ អ្នកនាំទៅគឺ ចាន់ សម្រែង ដល់ភ្នំពេញឲ្យខ្ញុំចិញ្ចឹមជ្រូកនៅបឹងទំពុន ។ ប្រហែលប្រាំខែដល់ចុង៧៥ បន្ទាប់មកគេ

ឲ្យខ្ញុំមកបឹងត្របែកនៅកាប់ព្រៃធ្វើប្រាំង ដាំបន្លែ រៀនអក្សរសាស្ត្រខ្មែរ ។ ខ្ញុំរៀនហ្វឹកហ្វឺននៅតាខ្មៅ គឺឆ្នាំ៧៦ រៀនយុទ្ធសាស្ត្រយោធា និងដាំបន្លែ ។ អ្នកដែលបង្រៀនខ្ញុំមិនបានចាំឈ្មោះទេ រៀនអស់រយៈពេលប្រាំបីខែ ។ ហាត់ដោះអាវុធ បោកគ្រាប់បែក វារមីន ក្រោយមកបិទវគ្គ តែខ្ញុំមិនបានស្គាល់អ្នកទៅបិទវគ្គទេ ។ ក្រោយមកខ្ញុំទៅព្រៃស លើកទំនប់ ដាំផែថាវ ខ្ញុំមិនបានចាំមេទេ ។ អស់ប្រហែលបីខែ ។ ក្រោយមកចូលរៀនពេទ្យរយៈពេលបីខែ រៀននៅមុខរោងកុនជិតផ្សារថ្មី។ ឈ្មោះ ដាំ ជាអ្នកដែលបង្រៀន។

[១១:០៦:០១]

ស.ស៖ ដែលឃើញ ឌុច មកមើលទេ?

ម.ស.ធ៖ មិនដែលទេ ។

ស.ស៖ តើរៀនពេទ្យដូចម្តេចខ្លះ?

ម.ស.ធ៖ រៀនមើលថ្នាំពេទ្យ និងចាក់ថ្នាំ ។

ស.ស៖ មានស្គាល់អ្នកដែលរៀនជាមួយទេ?

ម.ស.ធ៖ មានម្នាក់ឈ្មោះ ព្រំ សុខ ជាពេទ្យ ។ ក្រោយ៧៩ គាត់ក្លាយជាជំនិតរបស់ ឌុច បច្ចុប្បន្ននៅក្បាលឆាយ ស្រុកកំណើតនៅទីនោះ ។

ស.ស៖ តើលោកធ្លាប់ដឹងទេថា មានអ្នកដែលធ្វើពេទ្យនៅរស់ដល់សព្វថ្ងៃទៀតទេ?

ម.ស.ធ៖ មានម្នាក់ឈ្មោះ ដន បច្ចុប្បន្ននៅ ឃុំថ្កុងពពក ស្រុកសាមគ្គីមានជ័យ គាត់ពិការជើងមួយចំហៀង ។

ស.ស៖ ចុះក្រៅពីនេះ?

ម.ស.ធ៖ មានពេទ្យ ទ្រី ជាចាម ជាពេទ្យសាមញ្ញដូចខ្ញុំ បច្ចុប្បន្ននៅរស់ស្រុកកំពង់ត្រឡាច ខាងលិចផ្នូល់ទទឹង ។ ពេទ្យ ហួរ និងពេទ្យ ទ្រី ដែលជាប្រធានបានជាប់គុកពីរថ្ងៃ ពេលនោះវៀតណាមចូល តែមិនដឹងស្លាប់ ឬរស់ទេ ។

ស.ស៖ ចុះក្រៅពីរៀនពេទ្យ?

ម.ស.ធ៖ គឺគេឲ្យទៅតាខ្មៅ រៀនស្លថ្នាំ និងបោះពុម្ពជាថ្នាំពេទ្យ ។ អ្នកដែលចាប់ទៅឈ្មោះ ដាំ ហើយ ដាំ ក្រោមបញ្ជារបស់ ឌុច ។ ខ្ញុំទៅរៀនប្រហែលប្រាំបី ទៅប្រាំបួនខែក្នុងឆ្នាំ៧៧ ។ អ្នកដែលបង្រៀន គឺ ដាំ ។

ស.ស៖ តើឃើញ ឌុច ឬប្រធានធំៗទៅមើលទេ?

ម.ស.ធ៖ មិនដែលបានឃើញទេ ។

ស.ស៖ ចុះក្រៅពី៨ខែហ្នឹងមកទៀត?

ម.ស.ធ៖ ក្រោយមកខ្ញុំចូលបម្រើអ្នកទោសនៅទួលស្លែងរហូត៧៩ អត់ស្គាល់អ្នកយាមខ្ញុំមកទេ ។ ក្នុងនោះមានគ្នាប្រហែល១៥នាក់ ទាំងប្រធាននិងអនុប្រធាន ។ មានម្នាក់ទៀតដែលធ្វើពេទ្យជាមួយខ្ញុំឈ្មោះ ថា តែមិនដឹងរស់ ឬស្លាប់ ។

ស.ស៖ តើលោកដឹងមូលហេតុអ្វីបានជាឈ្មោះ ទ្រី បានត្រូវគេចាប់?

ម.ស.ធ៖ ខ្ញុំមិនដឹងមូលហេតុអ្វីទេ ចំណែក ហួរ ជាប្រធានក្រុមពេទ្យធម្មតា ជាអ្នកចែកថ្នាំឲ្យខ្ញុំចែកបន្ត ។ ផ្ទះពេទ្យកន្លែងដែលខ្ញុំធ្វើការ គឺនៅពីមុខ ស-២១ ។

ស.ស៖ អ្នកទោស ពេលដែលលោកព្យាបាល តើមានស្ថានភាពបែបណាដែរ?

ម.ស.ធ៖ ពេលដែលគេសួរចម្លើយរួច អ្នកទោសខ្លះបែកខ្នង ដកក្រចក ដែលខ្ញុំត្រូវព្យាបាលឲ្យជា ប្រសិនបើជាមនុស្សសំខាន់ ។ អ្នកដែលសួរចម្លើយនាំមកដើម្បីព្យាបាល ។ អ្នកសួរចម្លើយនោះប្រាប់ខ្ញុំថា មិត្តឯងត្រូវព្យាបាលឲ្យជា ព្រោះខ្ញុំមិនទាន់បានសួរចម្លើយចប់នៅឡើយទេ ។ ពេលព្យាបាល ពេលខ្លះ ខ្ញុំឃើញមានអ្នកទោសស្លាប់ខ្លះដែរ ។ មួយថ្ងៃៗ មួយថ្ងៃមួយ ចួនកាលពីរឬបីថ្ងៃមួយ ។ ហើយខ្ញុំជាអ្នកយកទៅកប់នៅតាមអគារក្រៅរបងគុក ។

ស.ស៖ លោកមានដែលទៅព្យាបាលអ្នកទោសនៅក្រៅរបងស-២១ ទេ?

ម.ស.ធ៖ ខ្ញុំទៅព្យាបាលប្រធានវរៈ និងប្រពន្ធប្រធានវរៈ ។

ស.ស៖ លោកធ្លាប់ទៅព្យាបាលអ្នកទោសពេលដែលគេកំពុងសួរចម្លើយផ្ទាល់តែម្តងទេ?

ម.ស.ធ៖ មិនដែលទេ ។ ភាគច្រើនគេដាក់ត្រងការយកដល់កន្លែងតែម្តង ។

ស.ស៖ លោកដែលព្យាបាលអ្នកទោសដែលគេបូមឈាមហើយដែរឬទេ?

ម.ស.ធ៖ ខ្ញុំទៅព្យាបាលតែនៅក្នុងអគារទាំងបីប៉ុណ្ណោះ មិនដែលចេញក្រៅទេ ។

ស.ស៖ តើលោកមានអ្វីសម្គាល់ដែលថាមានការបូមឈាម?

ម.ស.ធ៖ ខ្ញុំធ្លាប់ព្យាបាលអ្នកទោសដែលគេបូមឈាម ។ មានអ្នកបូមឈាម ព្រោះពេទ្យ ហួរ ដែលនៅជាមួយក្រុមខ្ញុំប្រាប់ ។ អ្នកទោសដែលគេបូមឈាមហើយ មានលក្ខណៈស្លេកស្លាំង ។ អ្នកទោសដែលត្រូវគេបូមឈាម ដែលខ្ញុំបានឃើញ មានប្រហែលសាមសិបទៅសែសិបនាក់ ។

ស.ស៖ តើគេបូមឈាមនៅទីណា?

ម.ស.ធ៖ ខ្ញុំមិនដឹងទេ តែខ្ញុំឃើញប្លោកឈាមខូចចោលក្បែរផ្ទះថ្មដែលខ្ញុំនៅ ។

[១១:១២:២៧]

ស.ស៖ តើ ឌុច ធ្លាប់មកមើលកន្លែងដែលលោកព្យាបាលឬទេ?

ម.ស.ធ៖ ខ្ញុំមិនដែលបានឃើញទេ ជួបតែពេលគាត់ទៅហូបបាយពេលល្ងាច ។

ស.ស៖ តើលោកដឹងថា ឌុច ជាប្រធានគុកដែរឬទេ?

ម.ស.ធ៖ ឌុច ជាប្រធានគ្រប់គ្រងអង្គភាពរួមទាំងពេទ្យ ទ្រី, ពេទ្យ ហួរ ផងដែរ ។

ស.ស៖ លោកធ្លាប់ជួប ឌុច នៅកន្លែងរៀនសូត្រស្វ័យទិតៀនទេ?

ម.ស.ធ៖ ខ្ញុំមិនដែលបានឃើញទេ ។ មានតែប្រធានកងរយ កងហា ជាអ្នកណែនាំ និងប្រធានពេទ្យ ។ ប្រធានពេទ្យ និងក្រុមពេទ្យ ក្នុងមួយអាទិត្យប្រជុំម្តង ។

ស.ស៖ តើលោកដែលស្គាល់ប្រធានក្រុមការពារទេ?

ម.ស.ធ៖ ហ៊ី ជាប្រធានកងការពារ ។ មានក្រុមសួរចម្លើយ តែមិនស្គាល់ប្រធានក្រុម។ ចំណែកក្រុមចុះចាប់ ខ្ញុំមិនស្គាល់ ឃើញតែឡានមក ។

ស.ស៖ តើលោកដែលធ្លាប់បានព្យាបាលជនជាតិវៀតណាមទេ?

ម.ស.ធ៖ មិនដែលព្យាបាលទេ សូម្បីតែឃើញក៏មិនដែល តែបើចិនមាន ។

ស.ស៖ ពេលព្យាបាលលោកមានឃើញកុមារ ឬស្ត្រីមានផ្ទៃពោះទេ?

ម.ស.ធ៖ អ្នកទោសដែលមានជាគ្រួសារ និងក្មេងគេមិនដាក់ខ្នោះទេ ។ គេដាក់ក្នុងបន្ទប់ធំ បិទទ្វារជិត ។

ស.ស៖ តើពេលព្យាបាល តើលោកធ្លាប់ឃើញ ឌុច មកបញ្ជាទេ?

ម.ស.ធ៖ ចំពោះខ្ញុំ ខ្ញុំមិនដែលបានឃើញ ឌុច មកបញ្ជាទេ ។

ស.ស៖ តើធ្លាប់ព្យាបាលចំមនុស្សដែលទៅពីស្រុកជាមួយលោក ឬអ្នកធ្វើការជាមួយដែរឬទេ?

ម.ស.ធ៖ មានតែពួកគាត់ចាប់ពី ពីរឬបីថ្ងៃមុន៧៩ តែមិនទាន់បានព្យាបាល ។

ស.ស៖ តើលោកធ្លាប់ដែលឃើញអ្នកទោសដែលគេបូមឈាមហើយត្រូវស្លាប់ដោយព្យាបាលមិនទាន់ទេ?

ម.ស.ធ៖ មិនដឹងទេ ព្រោះមុខជំនាញខុសគ្នា ។

ស.ស៖ តើលោកធ្លាប់ឃើញថា ការធ្វើទារុណកម្មបែបណាតាមរយៈការព្យាបាលនោះ?

ម.ស.ធ៖ ខ្ញុំធ្លាប់តែឃើញអ្នកទោសដែលត្រូវសួរចម្លើយដោយយកខ្សែភ្លើង-- ដោយឆក់ខ្សែភ្លើង ដោយអ្នកទោសប្រាប់ខ្ញុំ ។ ខ្ញុំដាក់ថ្នាំ *វីតាមីន បេខូ បេអង* ។

ស.ស៖ តើលោកគិតថា ថ្នាំនិងការព្យាបាលមានប្រសិទ្ធភាពឬទេ?

ម.ស.ធ៖ មិនមានប្រសិទ្ធភាពទេជាទូទៅ តែបើថ្នាំរាគអាចទប់បានខ្លះ ។

ស.ស៖ លោកគិតថាហេតុអ្វីបានជាខ្មែរក្រហមមិនយកថ្នាំបារាំងមកប្រើ?

ម.ស.ធ៖ ព្រោះថ្នាំបារាំងភាគច្រើនដែលនៅសល់ គឺហួសកាលប្រើប្រាស់ និងមិនដែលមានថ្នាំឲ្យ មកប្រើទេ ។

ស.ស៖ តើលោកធ្លាប់ព្យាបាលអ្នកទោសមានចំនួនច្រើនជាងគេនៅពេលណា?

ម.ស.ធ៖ គឺនៅពេលមានសង្គ្រាមមុនយួនវាយចូល ។

ស.ស៖ មានអ្វីដែលប្លែកក្រៅពីអ្វីដែលខ្ញុំបានសួរទេ?

ម.ស.ធ៖ គ្មានអ្វីប្លែកទេ ព្រោះខ្ញុំជាអ្នកព្យាបាលត្រូវតែព្យាបាលឲ្យជា តែបើមិនជាគេនឹងយកខ្ញុំទៅសម្លាប់ គឺប្រធានពេទ្យ ទ្រី និងហួរ ជាអ្នកប្រាប់ដូចនេះ ។

ស.ស៖ មុនពេលវៀតណាមចូលពីរឬបីថ្ងៃ មានកម្មាភិបាលណាមកណែនាំទេ?

ម.ស.ធ៖ គឺគ្មានអ្នកណាណែនាំអ្នកណាទេ គឺនាំគ្នារត់ខ្ចាត់ខ្ចាយតែម្តង ។

ស.ស៖ តើឆ្នាំណាដែលលោកមកដល់ភូមិស្រុកនេះវិញ?

ម.ស.ធ៖ ប្រហែលជិតមួយឆ្នាំពេលមកដល់នៅរដូវស្ទូង ។

ឯកសារចម្លងនៃកំណត់ហេតុមួយច្បាប់ ត្រូវបានប្រគល់ឲ្យសាក្សីនេះ ។

អានឲ្យស្តាប់ហើយ សាក្សីមិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ។”

“ឯកសារលេខ D54 នេះគឺជាកំណត់ហេតុនៃការតទល់មុខគ្នានៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ វេលាម៉ោងប្រាំបួននិងម្ភៃនាទី ដែលមានវត្តមានមេធាវីការពារក្តី លោក ការ សាវុត្ថ និងលោក ហ្វ្រង់ស្វ័រ រូ ។ ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ។ សាក្សី ហ៊ឹម ហ៊ុយ, ប្រាក់ ខន, សួស ធី, គង់ ផៃ, ម៉ម ណៃ, វ៉ាន់ ណាត, ម៉ក់ ស៊ីធឹម, សោម ម៉េត ដែលបានស្បថរួចហើយស្របតាមវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ។

ការតទល់មុខគ្នា៖

សួរ សំណួររបស់លោកសហចៅក្រមស៊ើបអង្កេត ម៉ាកសែល ឡឺម៉ុងដ៍៖ សាក្សីទាំងអស់ តើលោកបានមានដែលបានឃើញការសម្លាប់ជាឈុតនៅខែមករា ឆ្នាំ១៩៧៩ដែរឬទេ?

សាក្សី សួស ធី, ប្រាក់ ខន, ហ៊ីម ហ៊ុយ, សោម ម៉េត, ម៉ក់ ស៊ីធឹម, ម៉ម ណៃ៖ យើងខ្ញុំមិនដឹងពីបញ្ហានេះទេ ។

សួរ សំណួររបស់លោកសហចៅក្រមស៊ើបអង្កេត ម៉ាកសែល ឡឺម៉ុងដ៍៖ លោក ម៉ក់ ស៊ីធឹម តើលោកនៅតែបញ្ជាក់អះអាងចម្លើយរបស់លោក ដែលបានធ្វើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧ ទាក់ទងទៅនឹងការបូបឈាមដែរឬទេ?

ឆ្លើយ សាក្សី ម៉ក់ ស៊ីធឹម៖ ខ្ញុំជាគ្រូពេទ្យនៅស-២១ ហើយខ្ញុំជាអ្នកព្យាបាលអ្នកជំងឺ ។ ខ្ញុំមិនបានឃើញការបូមឈាមដោយផ្ទាល់ភ្នែកទេ ប៉ុន្តែខ្ញុំបានឃើញអ្នកទោសដែលគេទើបតែបូមឈាមហើយហើយដែលស្លេកស្លាំង ។ ខ្ញុំក៏បានឃើញស្បោងឈាមដែលគេមិនបានប្រើប្រាស់ហើយបោះចោលនៅក្រោមជណ្តើរផងដែរ ។

សួរ សំណួររបស់លោកសហចៅក្រមស៊ើបអង្កេត ម៉ាសែល ឡឺម៉ុងដ៍៖ លោក សួស ធី តើលោកនៅតែបញ្ជាក់អះអាងចម្លើយរបស់លោក ដែលបានធ្វើនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧ ទាក់ទងទៅនឹងការបូមឈាមរបស់ជនរងគ្រោះដែលត្រូវបានដាក់បញ្ចូលក្នុងបញ្ជីនៃអ្នកដែលត្រូវយកទៅកម្ទេចដែរឬទេ?

[១១:២១:៥០]

ឆ្លើយ សាក្សី សួស ធី៖ បាទ ខ្ញុំនៅតែទទួលស្គាល់សេចក្តីប្រកាសនោះដដែល ។

ឆ្លើយ ជនត្រូវចោទ៖ ខ្ញុំសូមសួរសំណួរទៅសាក្សី ម៉ក់ ស៊ីធឹម ថាតើគាត់បានឃើញស្បោងឈាមចំនួនប៉ុន្មាន?

ឆ្លើយ សាក្សី ម៉ក ស៊ីធឹម៖ ប្រមាណជាសាមសិបទៅសែសិបថង់ ។ ប៉ុន្តែ ខ្ញុំមិនច្បាស់ទេ ។

សួរ សំណួររបស់លោក អាឡិច បេ៊ត៖ ជនត្រូវចោទតើលោកបដិសេធសេចក្តីប្រកាសរបស់លោកប្រាក់ ខន ដែលធ្វើនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៧ ដែលបានបញ្ជាក់ថា ឈាមត្រូវបានគេបូបដើម្បីបញ្ជូនទៅមន្ទីរពេទ្យ ១៧ មេសា និងមន្ទីរពេទ្យមុនីវង្ស?

ឆ្លើយ ជនត្រូវចោទ៖ ប្រសិនបើមានការបូមឈាមមែន ខ្ញុំមិនគិតថា ថង់ឈាមទាំងនោះត្រូវបាន

បញ្ជូនទៅមន្ទីរពេទ្យមុនីវង្ស មន្ទីរពេទ្យរបស់កងពល៧០៣ ឬមន្ទីរពេទ្យ១៧ មេសា មន្ទីរពេទ្យរដ្ឋនោះទេ ពីព្រោះស-២១ មានមន្ទីរពេទ្យផ្ទាល់ខ្លួនដែរ មន្ទីរពេទ្យ៩៨ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សុន សេន ។

ឆ្លើយ សាក្សី ប្រាក់ ខន៖ ព័ត៍មាននេះខ្ញុំបានទទួលពីពេទ្យដែលជាអ្នកបូមឈាម ។ គាត់បានប្រាប់ខ្ញុំថា មន្ទីរពេទ្យ១៧ មេសា និងមន្ទីរពេទ្យមុនីវង្ស។

ឆ្លើយ សាក្សី ម៉ក់ ស៊ីធីម៖ ចំពោះខ្ញុំ ខ្ញុំមិនដឹងអំពីការបញ្ជូនថង់ឈាមនេះទៅមន្ទីរពេទ្យណានោះទេ ។

អានឱ្យស្តាប់ហើយជនត្រូវចោទ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ។"

**ប្រធានអង្គជំនុំ៖**

បន្ទាប់ពីស្តាប់ការអាននូវចម្លើយកំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ក់ សុធីម ហើយនិង កំណត់ហេតុតទល់គ្នាផ្នែកពាក់ព័ន្ធជាមួយនឹងសាក្សី ម៉ក់ ស៊ីធីម រួចមក តើតំណាងសហព្រះរាជអាជ្ញាមានអ្វីចង់កត់សម្គាល់លើខ្លឹមសារនៃកំណត់ហេតុទាំងពីរនេះដែរឬទេ? គឺកំណត់ហេតុទីពីរ ផ្នែកពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់សាក្សី ម៉ក់ ស៊ីធីម?

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ ។ តំណាងសហព្រះរាជអាជ្ញាគ្មានអ្វីកត់សម្គាល់ទៅលើកំណត់ហេតុសួរទាំងពីរនេះទេ ។ អរគុណ ។

**ប្រធានអង្គជំនុំ៖**

ខាងមេធាវីតំណាងអ្នកដើមបណ្តឹងរដ្ឋប្បវេណី តើមានអ្វីកត់សម្គាល់នូវឯកសារទាំងពីរដែលអានដោយក្រឡាបញ្ជីសវនាការអម្បាញ់មិញដែរឬទេ?

**លោក អាឡាំង វ៉ែនណឺ៖**

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីពុំមានការកត់សម្គាល់ទេ ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តី តើមានអ្វីត្រូវកត់សម្គាល់នូវកំណត់ហេតុដែលអានដោយក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះដែរឬទេ?

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។ ចំពោះកំណត់ហេតុដែលបានកត់សម្គាល់ គឺខ្ញុំសង្កេតឃើញថា ពេទ្យនៅស-២១ ដែល ម៉ក់ ស៊ីធឹម ជាពេទ្យនៅស-២១នេះ គាត់បានបញ្ជាក់យ៉ាងច្បាស់ដែលធ្វើឲ្យយើងកត់សម្គាល់បានថា មានពេទ្យប្រាំមួយនាក់ ទាំង ម៉ក់ ស៊ីធឹម គឺមាន ព្រុំ សុខ មានដន មានពេទ្យ ទ្រី មានពេទ្យ ហួរ មានពេទ្យថា និង ម៉ក់ ស៊ីធឹម នេះ ។ មានប្រាំមួយនាក់ហើយសុទ្ធតែជាប្រុសៗ នេះជាការកត់សម្គាល់របស់ខ្ញុំ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្ដីអន្តរជាតិ តើមានអ្វីចង់កត់សម្គាល់បន្ថែមលើមេធាវីការពារក្ដីជាតិដែរឬទេ?

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

ខ្ញុំពុំមានការកត់សម្គាល់បន្ថែម ដូចដែលអ្វីដែលលោកមេធាវីខ្ញុំបានលើកឡើងនោះទេ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះផ្ដល់ឱកាសដល់ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់នៅលើកំណត់ហេតុសក្ខីកម្មសាក្សី ម៉ក់ ស៊ីធឹម ហើយនិងកំណត់ហេតុតទល់គ្នាផ្នែកពាក់ព័ន្ធជាមួយនឹងសាក្សី ម៉ក់ ស៊ីធឹម ។ សូមអញ្ជើញ ។

[១១:២៧:៣៨]

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ខ្ញុំសូមញែកបញ្ហាដែលខ្ញុំកត់សម្គាល់នេះជាពីរកំណាត់ ។ ទីមួយអំពីឧក្រិដ្ឋបូមឈាមនៅស-២១ ។ ឧក្រិដ្ឋកម្មនេះខ្ញុំបានបញ្ជាក់ច្បាស់ជូនអង្គសវនាការរួចហើយ ។ អ្នកបញ្ជា គឺមេខ្ញុំលោកគ្រូ សុន សេន ហើយវាបន្តតាំងពីសម័យ ណាត នៅធ្វើជាប្រធាន ស-២១ រហូតមក ក៏ប៉ុន្តែវាដំណើរការច្រើននៅពេលដែលខ្ញុំធ្វើប្រធាន ។

ចំនួនជនរងគ្រោះដែលយកទៅបូមឈាម ក៏យើងបានបញ្ជាក់ដេញដោលនៅក្នុងសវនាការរួចអស់ហើយ ជាពិសេសជាមួយនឹង ប្រាក់ ខន មិត្តខន ។ គឺជនរងគ្រោះមានចំនួនប្រហែលជាមួយរយនាក់តាមខ្ញុំបញ្ជាក់ ។ ឯចំណែក ប្រាក់ ខន លែងប៉ាននិយាយថា មួយពាន់នាក់ហើយ ។ ដូច្នេះ បញ្ហាបូមឈាមខ្ញុំឃើញវាច្បាស់គួរសមហើយ ។ ឯចំណែកឈាមដែលខូច ដែល ម៉ក់ ស៊ីធឹម បញ្ជាក់ធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលដែរ សាម-សែសិបប្លោក មិនដឹងជាមូលហេតុអីបានឈាមខូច ។ នេះខ្ញុំនៅតែមិនអស់ចិត្ត ។ ដូច្នេះ មិន

ទាន់មានទម្ងន់អីធ្វើឲ្យខ្ញុំទទួលសក្ខីកម្ម ម៉ក់ ស៊ីធឹម បញ្ហានេះទេ ។

ទីពីរ ចំពោះបុគ្គល ម៉ក ស៊ីធឹម ខ្លួនឯង តើគាត់ជាបុគ្គលិករបស់ស-២១ មែន ឬមិនមែន? បញ្ហានេះក៏ខ្ញុំនៅតែមិនទាន់ដាច់ស្រេច ។ សក្ខីកម្មរបស់គាត់ដូចជាមិនមានទម្ងន់អីឲ្យខ្ញុំជឿបានថា គាត់ជាបុគ្គលិករបស់មន្ទីរស-២១ ។ ខ្ញុំសូមលើកបញ្ហាខ្លះដែលគាត់និយាយទៅវាដូចជាច្របូកច្របល់ ។ គាត់ប្រកាសថាគាត់កើតនៅក្នុងឆ្នាំ១៩៥៧ ហើយដល់ក្រោយ១៧ មេសា គាត់មិនដឹងចេះស្លៀកខោស្រួលបួលផង ដូច្នេះ វាខ្មាស់គ្នាទៅហើយសក្ខីកម្មនេះ ។ ហើយចំនួនពួកកុមារខាង-- ពួកក្មេងជំទង់ដែលខ្ញុំសុំមកពីកំពង់ឆ្នាំងមានតែចំនួនពីសែសិបទៅហាសិបនាក់ប៉ុណ្ណោះ មិនមែនច្រើនដល់រាប់រយទេ នេះបញ្ហាទីពីរ ។

បញ្ហាទីបី គាត់ស្គាល់តែគ្នាគាត់ប៉ុន្មាននាក់នុ៎ង ។ អ្នកកំពង់ឆ្នាំងពិតប្រាកដអត់ឮថាស្គាល់អ្នកណាឯចំណែក ពួកបុគ្គលិកស-២១ ពិតប្រាកដ ក៏អត់ទាន់ឮស្គាល់អ្នកណា ។ សរុបមក ខ្ញុំនៅតែមិនទាន់ដាច់ចិត្តនឹងទទួលស្គាល់ថា លោក ម៉ក់ ស៊ីធឹម នេះជាបុគ្គលិកស-២១ ។ ឯចំណែកពេទ្យទ្រី ដែលលោក ម៉ក់ ស៊ីធឹម មានប្រសាសន៍ហ្នឹង មិនមែនទ្រីប្រធានពេទ្យស-២១ របស់ខ្ញុំពិតប្រាកដទេ ។ ទ្រី នេះ ទ្រី ចាមនៅខាងទឹកផុសឯណោះ ។ ឯចំណែក ទ្រី របស់ខ្ញុំខាងស-២១ នេះ គឺ ទ្រី ជាគេរតំណែលពី៧០៣ទុកឲ្យ ។ គេជាខ្មែរនៅតាមដងទន្លេខាងស្អាងព្រែកតូចកោះធំ ។ ហ្នឹងខ្ញុំសូមបញ្ចប់ត្រឹមនេះបញ្ហាហ្នឹង ។ សូមគោរព ។

[១១:៣១:១៥]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត ចាត់លោកស្រី សែ កុលវុឌ្ឍី ក្រឡាបញ្ជីសវនាការអានន្ទូវកំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ តយ តេង ឯកសារដែលមានលេខ D28/12 ហើយការអាននេះគឺឲ្យជំនួសនូវឈ្មោះអ្នកស៊ើបអង្កេតដោយពាក្យថា “សំណួរ” ហើយនិងឈ្មោះកាត់នៃអ្នកឆ្លើយដោយ “ចម្លើយ” ដើម្បីងាយស្រួលដល់ភាគី ក៏ដូចជាសាធារណជនដែលបានស្តាប់ និងងាយយល់ពីខ្លឹមសារនៃឯកសារ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

ឯកសារលេខ D28/12 នេះគឺជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីតយ តេង ឈ្មោះបដិវត្តន៍ ឌី តេង កើតឆ្នាំ១៩៥៨ ។ កំណត់ហេតុនេះត្រូវបានធ្វើនៅថ្ងៃទីដប់ប្រាំពីរ ខែមករា ឆ្នាំពីរពាន់ប្រាំបី វេលាម៉ោងដប់ និងហាសិបនាទី ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត

នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សួរ- ឆ្លើយ

សំណួរ៖ សូមរៀបរាប់ដោយសង្ខេបអំពីប្រវត្តិរបស់លោកមុនឆ្នាំ១៩៧០ រៀននៅសាលាណាខ្លះ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ តើលោកធ្វើអ្វីខ្លះ?

ឆ្លើយ៖ កាលពីតូច ខ្ញុំរៀននៅសាលាបឋមសិក្សាកោះខ្សាច់ទន្លា ឃុំចុងកោះ ឃុំទឹកវិល ស្រុកស្អាង ខេត្តកណ្ដាល រៀនដល់ថ្នាក់ទី១១ ពេលឈប់រៀនខ្ញុំនៅផ្ទះជាមួយឪពុកម្ដាយ ។ ឆ្នាំ១៩៧៣ បានចូលធ្វើកងទ័ពខ្មែរក្រហម ដោយមានឈ្មោះ អ៊ុក តែម ជាបងជីដូនមួយ ជាអ្នកនាំចូល ។

[១១:៣៣:៥៨]

ខ្ញុំនៅក្នុងក្រុមកុមារអាយុប្រហែល១២ឆ្នាំ នៅក្នុងកងពលលេខ១២ មានភារកិច្ចដញ្ជូនបាយស្លុកទៅសមរភូមិនៅផ្លូវជាតិលេខ២ នៅស្រុកកណ្ដាលស្ទឹង ។

សំណួរ៖ ក្រោយ១៧ មេសា ១៩៧៥ តើលោកធ្វើអ្វីខ្លះ? នៅអង្គភាពណាខ្លះ?

ឆ្លើយ៖ ក្រោយ១៧ មេសា ១៩៧៥ គេឲ្យទៅធ្វើស្រែនៅម្តុំអូរបែកក្អម ពេលនោះខ្ញុំស្ថិតនៅក្នុងវរសេនាតូចលេខ៣១ កងពលលេខ១២ ។ បន្ទាប់មកទៀតគេឲ្យខ្ញុំនៅចាក់អង្រែលើ ហើយឲ្យទៅធ្វើស្រែនៅព្រែកសំរោង បន្ទាប់មកនៅបឹងទំពុន និងធ្វើស្រែនៅស្ទឹងព្រែកត្នោត ។ ប្រហែលនៅដើមឆ្នាំ១៩៧៨ គេបានបញ្ជូនខ្ញុំមកធ្វើការនៅស-២១ មានឈ្មោះ ណាង ជាប្រធានកងរយអនុសេនាធំជាអ្នកបញ្ជូនខ្ញុំមក ។

សំណួរ៖ តើគេប្រគល់ភារកិច្ចអ្វីខ្លះនៅស-២១? តើប្រធានស-២១ ឈ្មោះអ្វី?

ឆ្លើយ៖ គេឲ្យខ្ញុំយាមប្រចាំការនៅខាងក្រៅបរិវេណមន្ទីរឃុំឃាំងស-២១ ប្រចាំការនៅទិសខាងកើតចម្ងាយពី២០០ទៅ៣០០ម៉ែត្រពីអគារគុក ។ ប្រធានក្រុមរបស់ខ្ញុំឈ្មោះហ៊ុយ (ហ៊ឹម ហ៊ុយ), ប្រធានស-២១ ឈ្មោះ ឌុច និងអនុប្រធានឈ្មោះ ហ៊ ។

សំណួរ៖ សូមលោកពន្យល់អំពីរបៀបរបបយាមរបស់លោកយ៉ាងណាខ្លះ?

ឆ្លើយ៖ ពេលថ្ងៃគេឲ្យខ្ញុំទៅធ្វើស្រែខាងលិចវត្តព្រែកជ្រៃក្បែរព្រៃស ។ ពេលយប់គេឲ្យយាមម្នាក់ពីរម៉ោង ដោយផ្លាស់ប្តូរគ្នារហូតទាល់ភ្លឺ ។ ពេលថ្ងៃ មានក្រុមផ្សេងទៀតយាមប្រចាការ ។ ក្រុមរបស់ខ្ញុំស្នាក់នៅផ្ទះមួយ នៅខាងកើតលូទឹកស្អុយ ។

សំណួរ៖ តើហ៊ុយ ធ្លាប់បានប្រជុំញឹកញាប់ដែរឬទេ? ប្រជុំបែបណាខ្លះ?

ឆ្លើយ៖ យូរៗទើបគេប្រជុំណែនាំម្តង ។ គេណែនាំឲ្យយើងប្រុងប្រយ័ត្នការពារអ្នកទោសកុំឲ្យរត់រួច ហើយប្រធានក្រុមដែលរស់នៅជាមួយខ្ញុំគាត់ឈ្មោះ ទ្រី ។

សំណួរ៖ ក្រៅពីភារកិច្ចយាមនៅទីនោះ តើប្រធានក្រុមមានដែលចាត់ឲ្យលោកទៅធ្វើការងារអ្វីផ្សេងទៀតដែរឬទេ?

ឆ្លើយ៖ ក្រៅពីការងារយាម និងធ្វើស្រែ គេពុំដែលចាត់ឲ្យខ្ញុំធ្វើអ្វីទៀតទេ ។

សំណួរ៖ តើលោកដែលមានឃើញឡានចេញចូលនៅក្នុងគុកទួលស្លែងដែរឬទេ?

[១១:៣៧:២៦]

ឆ្លើយ៖ ខ្ញុំបានឃើញមានឡានចេញចូលដោយមានបិទឃ្លុបជិត ។ ក្រោយមកទើបខ្ញុំដឹងថា រថយន្តទាំងនោះដឹកអ្នកទោស ។ រថយន្តចូល គឺដឹកអ្នកទោសដាក់នៅកន្លែងឃុំឃាំង។ ចំណែករថយន្តដឹកចេញខ្ញុំមិនដឹងថាដឹកទៅកន្លែងណាទេ ។

សំណួរ៖ តើលោកដែលឮគេថានាំយកមនុស្សទៅសម្លាប់ដែរឬទេ?

ឆ្លើយ៖ ខ្ញុំដឹងដែរ គេយកមនុស្សទៅដាក់គុក រួចយកទៅសម្លាប់ ប៉ុន្តែមិនដឹងថា យកទៅសម្លាប់នៅទីណា ។

សំណួរ៖ តើលោកធ្លាប់បានឃើញមនុស្សបញ្ជូនមកទីនោះដែរឬទេ?

ឆ្លើយ៖ ចំពោះការចាប់មនុស្ស ខ្ញុំមិនដឹងថា គេចាប់មកពីកន្លែងណាទេ ខ្ញុំគ្រាន់តែឃើញគេដឹកចូលមកទីនោះ ។

សំណួរ៖ តើនៅស-២១ មានបុគ្គលិក ឬកម្មាភិបាលដែលត្រូវគេចាប់ខ្លួនឬទេ?

ឆ្លើយ៖ ខ្ញុំបានដឹងថា មានគេចាប់អ្នកធ្វើការនៅទីនោះ ។ ខ្ញុំពុំបានចាំឈ្មោះទេ ប៉ុន្តែក្រុមរបស់ខ្ញុំពុំមានត្រូវបានចាប់ខ្លួនទេ ។

សំណួរ៖ តើលោកធ្លាប់ដែលឃើញ ឌុច ដែរឬទេ?

ឆ្លើយ៖ ខ្ញុំបានធ្លាប់ឃើញគាត់ដើរ ចួនកាលគាត់ជិះម៉ូតូ ប៉ុន្តែខ្ញុំមិនដឹងថាគាត់ទៅណា ឬក៏ចេញពីកន្លែងណាទេ ។

សំណួរ៖ តើលោកត្រូវបានគេផ្លាស់ប្តូរឲ្យទៅធ្វើការនៅអង្គភាពផ្សេងឬទេ?

ឆ្លើយ៖ ខ្ញុំត្រូវបានផ្លាស់ឲ្យទៅធ្វើស្រែនៅព្រៃស ដោយសារខ្ញុំមានពាក់ព័ន្ធជាមួយបងប្អូនជីដូនមួយឈ្មោះ អ៊ុក តែម ជាប្រធានកងវរសេនាធំ ក្នុងកងពលេលេខ៧០៣ ត្រូវបានគេចាប់ខ្លួន ។ បន្ទាប់

មកឈ្មោះ អ៊ុក សាវ៉ាន់ និងឈ្មោះ អ៊ុក សារឿន អ្នកទាំងពីរធ្វើពេទ្យនៅ ព៩៨ ជាបងប្អូនរបស់គាត់ ត្រូវគេចាប់ខ្លួនជាបន្តបន្ទាប់ ។ ព័ត៌មានថាចាប់ អ៊ុក តែម នេះខ្ញុំបានដឹងដោយសារឈ្មោះ ឌុច គាត់ប្រកាសនៅក្នុងអង្គប្រជុំរៀនសូត្រនយោបាយ ។

សំណួរ៖ តើលោកមានដឹងថាគេយកមនុស្សទៅសម្លាប់នៅបឹងជើងឯកឬទេ? តើលោកដឹង តើគេសម្លាប់មនុស្សតាមរបៀបណាខ្លះ?

[១១:៤០:៣០]

ឆ្លើយ៖ ខ្ញុំបានដឹងថា មានគេយកមនុស្សទៅសម្លាប់នៅបឹងជើងឯក ដោយសារអ្នកនៅក្នុងក្រុមរបស់ខ្ញុំនិយាយប្រាប់ ប៉ុន្តែរបៀបសម្លាប់មនុស្សយ៉ាងណា ឬធ្វើទារុណកម្មយ៉ាងណានោះ ខ្ញុំមិនបានដឹងទេ ។

សំណួរ៖ ពេលលោកយាមនៅស-២១ តើក្រុមណាជាអ្នកបញ្ជូនមនុស្សទៅសម្លាប់នៅបឹងជើងឯក?

ឆ្លើយ៖ ខ្ញុំមិនបានដឹងទេ ពិតមែនតែខ្ញុំធ្វើការនៅស-២១ ប៉ុន្តែការងារដោយឡែកៗពីគ្នា ។

សំណួរ៖ តើលោកធ្លាប់បានឮពីការធ្វើទារុណកម្មអ្នកទោសដែរឬទេ? របៀបធ្វើទារុណកម្មយ៉ាងណាខ្លះ?

ឆ្លើយ៖ ខ្ញុំធ្លាប់បានឮអ្នកទោសស្រែកដោយការឈឺចាប់នៅផ្ទះខាងក្រៅបរិវេណគុក ជាកន្លែងដែលគេសួរចម្លើយអ្នកទោសនៅពេលដែលខ្ញុំទៅស្រោចទឹកបន្លែនៅក្បែរនោះ ។ ខ្ញុំគ្រាន់តែដឹងថា អ្នកទោសត្រូវគេវាយ អ្នកទោសខ្លះទៀតត្រូវគេដាក់ឲ្យឆក់ខ្សែភ្លើង ។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ ។

សំណួរ៖ តើលោកដែលធ្លាប់ឃើញគេបណ្តើរអ្នកទោសទៅសួរចម្លើយឬទេ? តើអ្នកទោសមានសភាពយ៉ាងណា?

ឆ្លើយ៖ ខ្ញុំធ្លាប់បានឃើញអ្នកទោសគេបណ្តើរដៃដាក់ខ្នោះទៅក្រោយនិងចងមុខ ។ ពេលសួរចម្លើយរួច ខ្ញុំធ្លាប់បានឃើញគេនាំអ្នកទោសចេញមកវិញ ប៉ុន្តែ ខ្ញុំមិនបានចំណាំថា អ្នកទោសមានរបួសស្នាម ឬយ៉ាងណាទេ ពីព្រោះខ្ញុំឃើញពីចម្ងាយដែរ និងលួចមើលមួយភ្លែតៗប៉ុណ្ណោះ ។

សំណួរ៖ តើលោកធ្លាប់ស្គាល់ឈ្មោះអ្នកសួរចម្លើយឬទេ?

ឆ្លើយ៖ ខ្ញុំមិនបានស្គាល់ទេ ពីព្រោះនៅអង្គភាពផ្សេងគ្នា ។

សំណួរ៖ តើគេធ្លាប់ដែលប្រជុំរួមគ្នាទូទាំងមន្ទីរដែរឬទេ?

ឆ្លើយ៖ អត់ទេ មានតែប្រជុំតាមផ្នែកៗប៉ុណ្ណោះ ។

សំណួរ៖ តើនៅព្រៃស គេឲ្យធ្វើអ្វីខ្លះ? អ្នកដែលគេបញ្ជូនទៅទីនោះជាមនុស្សប្រភេទណា និង មានចំនួនប្រហែលប៉ុន្មាននាក់?

ឆ្លើយ៖ នៅព្រៃស គេឲ្យធ្វើស្រែ លើកភ្លឺ ជីកប្រឡាយ ។ អ្នកដែលរស់នៅទីនោះគឺជាមនុស្ស ដែលពាក់ព័ន្ធជាមួយសីលធម៌ និន្នាការនយោបាយ ដែលមានបងប្អូនជាទាហាន លន់ នល់ ជាដើម ។ កន្លែងនោះ គឺជាកន្លែងលត់ដំមនុស្ស ។ សរុបមនុស្សដែលរស់នៅទីនោះមានប្រហែលពីររយនាក់ មាន ស្រី មានប្រុស មានបែងចែកជាក្រុមៗ ក្នុងមួយក្រុមមានគ្នាប្រហែលម្ភៃទៅម្ភៃប្រាំនាក់ជាដើម ។

[១១:៤៤:00]

សំណួរ៖ អ្នកណាជាប្រធាននៅព្រៃស?

ឆ្លើយ៖ ឈ្មោះ ហ៊ុយ ជាប្រធានព្រៃស ។

សំណួរ៖ តើរបៀបរបបធ្វើការនៅកន្លែងនោះធ្វើយ៉ាងណាខ្លះ?

ឆ្លើយ៖ ពេលព្រឹកចេញធ្វើការពីព្រលឹម រហូតដល់ម៉ោងដប់ពីរថ្ងៃត្រង់ទើបហូបបាយ ក្រោយពី ហូបបាយរួច ខ្ញុំធ្វើការបន្តទៀតរហូតដល់ម៉ោងប្រាំ ទៅប្រាំមួយល្ងាច ។ ក្រោយពីពេលបាយល្ងាចរួច គេ ប្រជុំណែនាំតាមក្រុមនីមួយៗអប់រំឲ្យខិតខំធ្វើការងារ ។ ពេលយប់មានគេយាមការពារយ៉ាងហ្មត់ចត់ ។ ពេលយប់គេមិនឲ្យទៅធ្វើការទេ ពីព្រោះខ្លាចលួចរត់ចេញ ។

សំណួរ៖ តើការហូបចុកយ៉ាងណាដែរ? មានរបបប៉ុន្មានពេលក្នុងមួយថ្ងៃ?

[១១:៤៥:០៣]

ឆ្លើយ៖ ការហូបចុកមានការខ្វះខាតច្រើន ។ បាយមានលាយគល់ចេក និងគល់ល្ហុង មួយថ្ងៃមាន របបពីរពេល គឺថ្ងៃត្រង់ និងពេលល្ងាច ។ ជួនពេលខ្លះមានហូបបបរពេល ហូបបាយមួយពេល ។

សំណួរ៖ តើមានការធ្វើទារុណកម្មទេ ចំពោះអ្នកនៅព្រៃស?

ឆ្លើយ៖ ពុំមានទេ ប៉ុន្តែចំពោះអ្នកដែលធ្វើការយឺតយ៉ាវ ឬឈឺជាដើម ត្រូវគេស្តីបន្ទោសថា ខ្ជិល និងគំរាមតែប៉ុណ្ណោះ ។

សំណួរ៖ តើលោករស់នៅព្រៃសបានរយៈពេលប៉ុន្មានទើបបែកភ្នំពេញ?

ឆ្លើយ៖ បានប្រហែលពីរខែ ទើបបានរំដោះភ្នំពេញក្នុងឆ្នាំ១៩៧៩ ។

ឯការថតចម្លងនៃកំណត់ហេតុមួយច្បាប់ត្រូវបានប្រគល់ឲ្យសាក្សីនេះ ។

អានឲ្យសាក្សីស្ដាប់ហើយ សាក្សីមិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ។”

**ប្រធានអង្គជំនុំ៖**

អានកំណាត់ហេតុទីពីរ D50/3 ។

**លោកស្រី សែ កុលវុឌ្ឍី៖**

ឯកសារលេខ D50/3 នេះគឺជាកំណត់ហេតុ នៃការស្ដាប់ចម្លើយសាក្សី តយ តេង ឈ្មោះបដិវត្តន៍ ឌី តេង កើតឆ្នាំ១៩៥៨ កំណត់ហេតុនេះ ត្រូវបានធ្វើនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ វេលាម៉ោងដប់ព្រឹក ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សួរ-ឆ្លើយ៖

សួរ៖ តើនៅឆ្នាំណាដែលលោកត្រូវបានគេបញ្ជូនពីស-២១ ឲ្យទៅនៅជើងឯក? ពេលបញ្ជូនទៅនោះមានគ្នាប៉ុន្មាននាក់ និងមានភារកិច្ចធ្វើអ្វីខ្លះ?

ឆ្លើយ៖ ខ្ញុំមិនបានចាំឆ្នាំច្បាស់ទេ ។ ប្រហែលជាឆ្នាំ១៩៧៨ ពេលនោះគេបញ្ជូនមកគ្នាដប់នាក់ ។ នៅជើងឯក ពុំអ្នកផ្សេងទៀតទេ គឺមានតែក្រុមរបស់ខ្ញុំ ។ នៅពេលនោះ គេឲ្យក្រុមខ្ញុំជីករណ្ដៅដែលរណ្ដៅនីមួយៗ មានទំហំបីម៉ែត្របួនជ្រុង ជម្រៅប្រហែលពីរម៉ែត្ររណ្ដៅទាំងនោះជីកនៅពេលថ្ងៃ ជីកដោយកម្លាំងពលកម្មផ្ទាល់ដោយចប និងបង្គី ។

សួរ៖ តើអ្នកណាជាអ្នកណែនាំឲ្យក្រុមរបស់លោកជីករណ្ដៅនេះ?

ឆ្លើយ៖ ឈ្មោះ ហ៊ុយ បានណែនាំឲ្យជីករណ្ដៅនេះ ។ លុះត្រាតែមានការណែនាំឲ្យជីកទើបក្រុមខ្ញុំចាប់ផ្ដើមជីក ។ ពេលខ្លះគេមកប្រាប់ឲ្យជីកពីរ ឬបីរណ្ដៅរយៈពេលបី ឬបួនថ្ងៃ ។ រណ្ដៅនីមួយៗអាចជីកហើយក្នុងរយៈពេលពីរ ឬបីថ្ងៃទៅតាមស្ថានភាពដីទន់ ឬរឹង ។

[១១:៤៨:៤៩]

សួរ៖ ចូរលោកបញ្ជាក់អំពីការដឹកអ្នកទោសពីស-២១ មកជើងឯកនេះ មុនពេលសម្លាប់តើគេធ្វើយ៉ាងណាខ្លះ?

ឆ្លើយ៖ អ្នកទោសគេដឹកពីស-២១ មកតាមខ្ញុំមានឈ្មោះ ស្រ៊ីម ជាតៃកុងឡាននិងឈ្មោះ ហ៊ុយ និងក្រុមរបស់គាត់មកជាមួយឡានពេលដឹកមកម្ដងៗ ។ ពេលដឹកមក គឺពេលយប់ប្រហែលជាម៉ោងប្រាំពីរក្នុងមួយឡានមានអ្នកទោសប្រហែលម្ភៃនាក់ ។ ពេលដឹកមកដល់គេនាំអ្នកទោសចុះពីឡានយកទៅដាក់

ក្នុងបន្ទប់ក្នុងផ្ទះឈើមួយ ដោយមានម៉ាស៊ីនភ្លើងនៅក្នុងផ្ទះនោះ ។ បន្ទាប់មក គេនាំអ្នកទោសម្តងមួយៗ ទៅសម្លាប់នៅតាមរណ្តៅដែលនៅចម្ងាយពីផ្ទះនោះប្រហែលមួយរយម៉ែត្រ ។ ក្រុមអ្នកនាំមនុស្សយក ទៅសម្លាប់នោះមានឈ្មោះ សារឹម និងពីរបីនាក់ផ្សេងទៀតដែលខ្ញុំមិនស្គាល់ឈ្មោះ ។ ក្រុមនេះ គឺមក ជាមួយនឹងឡានដែលដឹកអ្នកទោស ។ ចំណែកខ្ញុំ និងក្រុមរបស់ខ្ញុំជាអ្នកការពារ និងរាប់ចំនួនអ្នកទោស ពេលយកមកដល់ និងយកទៅសម្លាប់ ។

[១១:៥០:១៧]

សួរ៖ តើអ្នកទោសដែលនាំមកជើងឯកគេមានដាក់ខ្នោះ និងចងមុខដែរឬទេ?

ឆ្លើយ៖ អ្នកទោសទាំងនោះ ត្រូវបានគេដាក់ខ្នោះដៃ និងបានចងមុខតាំងពីគេនាំចេញពីទួលស្លែង មកម្ល៉េះ ។

សួរ៖ សូមលោករៀបរាប់អំពីរបៀបសម្លាប់ដែលលោកបានឃើញនៅពេលនោះយ៉ាងម៉េចខ្លះ?

ឆ្លើយ៖ ដំបូងគេមកអង្គុយនៅចម្ងាយពីមាត់រណ្តៅប្រហែលជាមួយម៉ែត្រ គេឲ្យអង្គុយទន្ទឹមគ្នា ម្តងពីរឬបីនាក់ រួចគេយកបំពង់ទីបវាយកញ្ចឹងក ពេលអ្នកទោសដួលគេដោះខ្នោះដៃចេញ ។ ពេលនោះ គេយកកាំបិទទៅសម្លាប់បន្ថែម តែខ្ញុំមិនដឹងថាគេវះពោះ ឬក៏អារ-កទេ ។ ដោយគ្រាន់តែឃើញក្រោយ ពេលសម្លាប់គេយកកាំបិតឆ្នោត ដែលមានឈាមប្រឡាក់យកមកលាងចេញប៉ុណ្ណោះ ។ នៅក្បែររណ្តៅ គេមានប្រើចង្កៀងប្រេងកាតពីរសម្រាប់បំភ្លឺ ។

[១១:៥១:៣៩]

សួរ៖ ពេលគេវាយអ្នកទោស តើអ្នកទោស-- សម្លាប់អ្នកទោសដែលមានស្រែកដែរឬទេ?

ឆ្លើយ៖ ពេលដែលគេវាយសម្លាប់អ្នកទោសក្រុមរបស់ខ្ញុំនៅការពារពីខាងក្រោយប្រហែល ១០០ ម៉ែត្រ ការពារក្រែងអ្នកទោសរត់រួច ។ ខ្ញុំមិនដែលឮអ្នកទោសស្រែកទេ ។ ខ្ញុំនៅស្ងួរតែស្នូរវាយភ្លូសៗតែ ប៉ុណ្ណោះ ។

សួរ៖ លោកមានមុខងារជាអ្នកទទួលខុសត្រូវរាប់អ្នក-- ចំនួនអ្នកទោសមុនពេលយកទៅសម្លាប់ ដើម្បីឲ្យដឹងអ្នកស្លាប់មែនលុះត្រាតែយើងនៅជិតទើបបានដឹង ។ សូមលោបញ្ជាក់ពីចំណុចនេះ ។

ឆ្លើយ៖ ពេលគេយកអ្នកទោសចេញពីបន្ទប់ក្នុងផ្ទះ ខ្ញុំឈរនៅមាត់ទ្វាររាប់ចំនួនអ្នកទោសនៅពេល នោះ ។ ពេលគេសម្លាប់រួចហើយ គេឲ្យក្រុមរបស់ខ្ញុំទៅកាយដីលុបរណ្តៅទាំងនោះ ។

សួរ៖ ពេលក្រុមលោកទៅកាយដីលប់រណ្តៅទាំងនោះ តើលោកបានឃើញអ្នកទោស អ្នកស្លាប់

ទាំងនោះត្រូវគេអារ-ក ឬវះពោះ?

ឆ្លើយ៖ ខ្ញុំមិនឃើញ មិនច្បាស់ទេ ពីព្រោះពេលយប់ តែមើលឃើញមានឈាមនៅលើមាត់រណ្តៅ ។

សួរ៖ តើក្នុងរណ្តៅនីមួយៗមានសាកសពប៉ុន្មាននាក់? ហើយពេលដែលក្រុមលោកទៅកប់ម្តងៗច្រើនជាងគេមានប៉ុន្មានរណ្តៅ?

ឆ្លើយ៖ ក្នុងរណ្តៅនីមួយៗមានសាកសពប្រហែលជាងដប់នាក់ ហើយរណ្តៅដែលច្រើនជាងគឺមានបីរណ្តៅ ។ ពេលវាយម្តងៗជាធម្មតាមានតែមួយឬពីររណ្តៅតែប៉ុណ្ណោះ ។

[១១:៥៣:៥៤]

សួរ៖ ក្នុងចំណោមអ្នកទោសដែលយកទៅសម្លាប់នៅជើងឯកមានក្មេងនិងស្ត្រីដែរឬទេ?

ឆ្លើយ៖ ពុំមានកូនក្មេងទេ មានតែបុរស និងស្ត្រីប៉ុណ្ណោះ ។

សួរ៖ តើអ្នកអាចពន្យល់បានទេថា នៅក្នុងរណ្តៅមួយមានតែលលាដ៍ក្បាលកូនក្មេង?

ឆ្លើយ៖ ខ្ញុំមិនដឹងដែរ ។ ខ្ញុំមិនធ្លាប់ឃើញមានអ្នកទោសកូនក្មេងមកទេ ។

សួរ៖ នៅពេលនោះ តើមានអ្នកទោសជាឈ្លើយសឹកជាថៃ វៀតណាម និងជនបរទេសដទៃទៀតដែរឬទេ?

ឆ្លើយ៖ គ្មានទេ មានតែខ្មែរទាំងអស់ ។

[១១:៥៤:៤១]

សួរ៖ តើលោកមានធ្លាប់ឃើញ ឌុច ទៅជើងឯកឬទេ?

ឆ្លើយ៖ ទេ ខ្ញុំមិនដែលឃើញគាត់ទេ ។ ខ្ញុំដឹងថាគាត់ទទួលខុសត្រូវស-២១ តែខ្ញុំមិនស្គាល់គាត់ច្បាស់ទេ ។ ទោះគាត់ទៅជើងឯកក៏ខ្ញុំមិនស្គាល់ដែរ ។

សួរ៖ តើលោកមានធ្លាប់ស្គាល់មនុស្សម្នាក់ឈ្មោះ ហ៊ឹ ឬទេ?

ឆ្លើយ៖ បាទ ខ្ញុំធ្លាប់ស្គាល់គាត់ ព្រោះគាត់ធ្លាប់ទៅជើងឯកចំនួនពីរដង ។

សួរ៖ នៅពេលដែលគាត់ទៅជើងឯក តើគាត់ដែលណែនាំលោកឬទេ?

ឆ្លើយ៖ គាត់មិនដែលនិយាយណែនាំខ្ញុំផ្ទាល់ទេ ។ គាត់មកនិយាយជាមួយ ហ៊ុយ ហើយ ហ៊ុយណែនាំខ្ញុំបន្ត ហើយប្រាប់ថា ត្រូវប្រយ័ត្នក្នុងការឃាមកាម ។

សួរ៖ ក្រៅពីហ៊ុយ ហើយនិង ហ៊ឹ តើមានដឹកនាំផ្សេងទៅជើងឯកដែរឬទេ?

ឆ្លើយ៖ ទេ ពុំដែលមានទេ ។

សួរ៖ តើក្នុងមួយខែគេដឹកអ្នកទោសទៅជើងឯកប៉ុន្មានដង?

ឆ្លើយ៖ មិនទៀងទាត់ទេ ។ ជួនកាលក្នុងមួយខែពីរទៅបីដង ។

សួរ៖ តើលោកហើយនិងក្រុមលោកនៅជើងឯកជាប្រចាំ នៅរហូតដល់បែកភ្នំពេញឬយ៉ាងណា?

ឆ្លើយ៖ ទេ ខ្ញុំត្រូវបានដកទៅនឹងព្រៃស ចំនួនពីរខែមុន ថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ មុនថ្ងៃបែកភ្នំពេញ ។

សួរ៖ តើលោកធ្លាប់ឃើញ ហ៊ីម ហ៊ុយ សម្លាប់អ្នកទោសដោយផ្ទាល់ដៃដែរឬទេ? ហើយដែលមានរូបលោកនៅទីនោះដែរ តើលោកយល់យ៉ាងណា?

ឆ្លើយ៖ ទេ ខ្ញុំមិនដែលឃើញទេ ។

សួរ៖ ប៉ុន្តែ ហ៊ីម ហ៊ុយ បាននិយាយថា គាត់ធ្លាប់បានសម្លាប់អ្នកទោសផ្ទាល់ដៃនៅជើងឯកដែរឬទេ?

ឆ្លើយ៖ ទេ រឿងហ្នឹង ខ្ញុំមិនដឹងទេ តែបើ ហ៊ីម ហ៊ុយ និយាយថាអ៊ីចឹងស្រេចលើខ្លួនគាត់ទៅចុះ ។ ចំពោះខ្ញុំ ខ្ញុំអត់ដឹងទេ ។ ខ្ញុំសូមស្បថថា ខ្ញុំនិយាយតែការពិត ។

[១១:៥៧:១៥]

សួរ៖ តើ ហ៊ីម ហ៊ុយ មានអាកប្បកិរិយាបែបណាតាមដែលលោកធ្លាប់បានឃើញ?

ឆ្លើយ៖ គាត់កាចគួរសមដែរ គាត់និយាយខ្លាំង ។ គាត់និយាយមកគួរឲ្យខ្លាច យើងខ្លាចគាត់ ប៉ុន្តែគាត់មិនមែនជាមនុស្សឃោរឃៅទេ ។

សួរ៖ តើលោកអាចប៉ាន់ប្រមាណអំពីចំនួនរណ្តៅកប់សាកសពនៅជើងឯក មានប្រហែលប៉ុន្មានរណ្តៅ?

ឆ្លើយ៖ តាមខ្ញុំស្មានមានប្រហែលតែម្ភៃទៅសាមសិបរណ្តៅតែប៉ុណ្ណោះ ពីព្រោះខ្ញុំចាំមិនច្បាស់ដែរ ។ ហើយក៏មិនបានកត់ត្រាទុកដែរ ។

សួរ៖ ពេលទៅដល់នៅជើងឯកដំបូង តើលោកមានបានកត់សម្គាល់ឃើញថា តើមានរណ្តៅសាកសពដែលកប់ថ្មីមានពីមុនពេលដែលលោកមកនៅទីនោះឬទេ?

ឆ្លើយ៖ ខ្ញុំមិនដែលឃើញរណ្តៅសាកសពថ្មីៗពីមុនមកទេ ។ មានតែផ្នូរ ឬម៉ុងចំនួនពីរ ឬបីតែប៉ុណ្ណោះដែលសល់ពីដើមមក ។

ស្លួរ៖ តើកន្លែងនោះ ជាកន្លែងកប់ខ្មោចពីមុនដែរឬយ៉ាងណា?

ឆ្លើយ៖ ខ្ញុំមិនដឹងទេ តែខ្ញុំឃើញតែផ្នូរបីទេ ដែលនៅក្បែរគ្នា ។

ស្លួរ៖ នៅក្នុងចំណោមក្រុមអ្នកដែលរស់នៅជើងឯកជាមួយលោក តើមាននៅចាំឈ្មោះអ្នកទាំងនោះដែរឬទេ? ហើយអ្នកទាំងនោះរស់នៅទីណា?

ឆ្លើយ៖ ខ្ញុំចាំតែឈ្មោះ ឈួន ម្នាក់ទេ ក្រៅពីនេះខ្ញុំភ្លេចអស់ហើយ ។ ឈ្មោះ ឈួន ខ្ញុំមិនដឹងថាគាត់រស់ឬស្លាប់ទេ ហើយក៏មិនដឹងថាគាត់មានទីលំនៅ នៅស្រុកណាដែរ ។

ស្លួរ៖ តើអារម្មណ៍របស់លោកកាលពីរស់នៅជើងឯកនោះយ៉ាងណាដែរ?

ឆ្លើយ៖ នៅទីនោះ ខ្ញុំមានអារម្មណ៍ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លះចំពោះខ្លួនឯងយល់ថា នៅពេលខាងមុខខ្លួនខ្ញុំ នឹងទៅជាយ៉ាងណាដែរ ។ ពេលនោះបើខ្ញុំមិនធ្វើតាមគេក៏មិនបានដែរ ប្រៀបបីដូចជារស់នៅជាមួយសត្វខ្លាអ៊ីចឹង ។

ស្លួរ៖ ក្នុងចំណោមអ្នកទោសដែលបានយកមកសម្លាប់នៅជើងឯក តើលោកធ្លាប់បានជួបអ្នកដែលលោកធ្លាប់បានស្គាល់ពីមុនមកដែរឬទេ?

ឆ្លើយ៖ ខ្ញុំមិនដែលធ្លាប់បានជួបអ្នកដែលធ្លាប់ស្គាល់ទេ ។

ឯកសារថតចម្លងនៃកំណត់មួយច្បាប់ត្រូវបានប្រគល់ឲ្យសាក្សីនេះ ។

អានឲ្យស្តាប់ហើយ សាក្សីមិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ។”

[១២:០០:២៦]

**ប្រធានអង្គជំនុំ៖**

បន្ទាប់ពីបានស្តាប់ នូវការអានកំណត់ហេតុស្តាប់សក្ខីកម្មសាក្សីឈ្មោះ តយ តេង នូវឯកសារទាំងពីរ គឺ D28/12 និង D50/3 តើតំណាងសហព្រះរាជអាជ្ញាមានអ្វីចង់កត់សម្គាល់នៅលើខ្លឹមសារនៃសក្ខីកម្មរបស់សាក្សីរូបនេះដែរឬទេ?

**លោក តាន់ សេណារ៉ុង៖**

តំណាងសហព្រះរាជអាជ្ញាពុំមានយោបល់ ហើយនិងសេចក្តីសង្កេតណាមួយទៅលើកំណត់ហេតុទាំងពីរនេះទេ ។

**ប្រធានអង្គជំនុំ៖**

ចុះខាងមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី តើមានអ្វីចង់កត់សម្គាល់លើខ្លឹមសារនៃកំណត់

ស្ដាប់ចម្លើយសាក្សី តយ តេង ទាំងពីរកំណាត់ហេតុដែលអាន ដោយក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះដែរឬទេ?

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទជាមេធាវីឱ្យដើមបណ្ដឹងរដ្ឋប្បវេណីមានការកត់សម្គាល់ទៅលើឯកសារទាំងពីរនេះ គឺកត់សម្គាល់ឃើញថាចម្លើយរបស់សាក្សីឈ្មោះ តយ តេង នេះគឺមានភាពជាក់លាក់ និងច្បាស់លាស់ណាស់ ថាគាត់ជាបុគ្គលិករបស់មន្ទីរស-២១ គាត់បានដឹង គាត់បានឃើញ បានឮនឹងត្រចៀករបស់គាត់ផ្ទាល់ អំពីអ្នកទោសទាំងឡាយដែលត្រូវបានសួរចម្លើយ ធ្វើទារុណកម្មធ្ងន់ធ្ងរ មុននឹងយកទៅសម្លាប់ ។ ហើយជាពិសេស គឺគាត់បានចូលខ្លួន ឬក៏ត្រូវបានបញ្ជូនក្រុមរបស់គាត់ឱ្យទៅធ្វើការនៅវាលពិឃាដជើងឯកថែមទៀត ព្រមទាំងបានជីករណ្ដៅកប់សាកសព និងបានដឹងអំពីរបៀបនៃការសម្លាប់មនុស្ស ដោយការចងមុខ ចងដៃទៅក្រោយ អង្គុយលត់ជង្គង់មាត់រណ្ដៅមុននឹងវាយសម្លាប់ថែមទៀតផង ។

ដូច្នេះ សក្ខីកម្មទាំងនេះ គឺមានភាពច្បាស់លាស់ណាថា អំពើធ្វើទារុណកម្ម និងការកាប់សម្លាប់គឺមានពិតប្រាកដដូចគាត់បានថ្លែងនៅក្នុងកំណាត់ទាំងពីរនេះមែន ។ សូមអរគុណ ។

[១២:០២:៣៨]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត តើខាងមេធាវីការពារក្ដី តើមានអ្វីចង់កត់សម្គាល់លើកំណាត់ហេតុនៃការស្ដាប់ចម្លើយសាក្សីទាំងពីរ កំណាត់ហេតុអម្បាញ់មិញ ដែលអានដោយក្រឡាបញ្ជីដែរឬទេ?

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំឯកភាពទៅនឹងការកត់សម្គាល់របស់លោក ហុង គីមសួន ដែលថាសាក្សីរូបនេះ បាននិយាយយ៉ាងច្បាស់លាស់ហើយ ។ ហើយខ្ញុំក៏បន្ថែមថាជាពិសេសសាក្សីរូបនេះក៏បានឆ្លើយបញ្ជាក់បន្ថែមដែរ ថាមិនដែលឃើញជនជាប់ចោទទៅជើងឯកទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះផ្ដល់ឱកាសដល់ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់លើសក្ខីកម្មដែលផ្ដល់ដោយសាក្សី តយ តេង ទាំងពីកំណាត់ហេតុ ដែលបានអានដោយក្រឡាបញ្ជីសវនាការ ។

យ៉ាងម៉េចទៅលោកមេធាវី លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ?

**លោក អានីស អះម៉េដ៖**

ខ្ញុំមិនចង់ស្កាត់ទេ ប៉ុន្តែ សូមឲ្យលោកចៅក្រមពិចារណា ។ មេធាវីការពារក្តីប្រហែលជាស្នើសុំបញ្ជាក់ថា គាត់មិនជំទាស់ទៅលើការអានឯកសារចម្លើយនេះទេ ហើយក៏មិនជំទាស់ថាមិនចាំបាច់កោះហៅសាក្សីរូបនេះដែរ ។ ដូច្នេះហើយ ខ្ញុំសូមស្នើថាវិធាន៨៤.១ ជនជាប់ចោទមានឱកាសក្នុងការកោះហៅសាក្សីណាដែលគាត់មិនទាន់បានពិនិត្យដេញដោលមុនអង្គសេចក្តី ។ ដូច្នេះហើយ តាមវិធាន៨៤.១ សូមឲ្យខាងសវនាការសួរទៅកាន់មេធាវីការពារក្តីថា គាត់ពិតជាមិនជំទាស់ ហើយគាត់ពិតជាមិនចង់កោះហៅសាក្សីរូបនេះមកទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំមិនយល់ពីបំណងរបស់លោកទេ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ និយាយឲ្យបានច្បាស់លាស់ ហើយងាយយល់ដើម្បីឲ្យអ្នកដទៃទៀតយល់ ជាពិសេសប្រធានអង្គជំនុំជម្រះហ្នឹងបានយល់ច្បាស់លាស់ អំពីបំណងរបស់លោកផង ហើយលោកត្រូវដឹងអំពីមូលហេតុទាំងឡាយនៃការសម្រេចមិនយកសាក្សីនោះមកចំពោះមុខអង្គជំនុំជម្រះ គឺជាការសម្រេចរបស់អង្គជំនុំជម្រះ ។

[១២:០៥:៣៥]

**លោក អានីស អះមេដ៖**

លោកចៅក្រម ខ្ញុំសូមអភ័យទោស បើសិនជាមិនមានបញ្ជាក់ច្បាស់លាស់ ។ ខ្ញុំសូមលើកឡើងដូច្នេះថា ខ្ញុំមិនចោទសួរទៅលើសេចក្តីសម្រេចរបស់អង្គសវនាការ ទាក់ទងទៅនឹងការកោះហៅសាក្សីនោះទេ ។ ដោយសារតែចៅក្រម លោកចៅក្រមចង់ដឹងអំពីជំហររបស់ភាគី ដូច្នេះខ្ញុំស្នើសុំអង្គសវនាការឲ្យធ្វើការស្នើសុំការសង្កេតរបស់មេធាវីការពារក្តីថា ពួកគាត់គឺមិនជំទាស់ គាត់មិនជំទាស់ទៅនឹងការមិនកោះហៅសាក្សីរូបនេះមកចូលមកក្នុងតុលាការនោះទេ ។

ខ្ញុំស្នើសុំចំណុចនេះ តែអាស្រ័យទៅលើវិធាន៨៤.១ តាមវិធាននេះ ប្រសិនបើអនុញ្ញាតនោះ គឺខ្ញុំសូមអានថា “ជនជាប់ចោទ មានសិទ្ធិក្នុងការកោះសាក្សីដាក់បន្ទុកលើខ្លួន ដែលជនជាប់ចោទមិនមានលទ្ធភាពពិនិត្យដេញដោលមុនសវនាការជំនុំជម្រះ” ។ ដូច្នេះហើយ ដោយសារតែជនជាប់ចោទមិនបានដេញដោលសាក្សីនៅក្នុងដំណាក់កាលមុនអង្គសេចក្តី ដូច្នេះគាត់មិនធ្វើការសង្កេតផ្តល់ការសង្កេតទៅលើសាក្សីរូបនេះ។ ដូច្នេះ ដើម្បីឲ្យច្បាស់ទៅលើកំណត់ហេតុ និងដើម្បីកុំឲ្យមានការជំទាស់តវ៉ាទៅលើវិធាន៨៤.១ ដែលថាជនជាប់ចោទ គាត់អាចធ្វើការដេញដោលសាក្សី ។ អ៊ីចឹងចង់ដឹងថា តើខាងជនជាប់ចោទ

និងខាងមេធាវីការពារក្តី គាត់ពិតជាមិនជំទាស់ក្នុងការដែលយើងមិនកោះហៅសាក្សីរូបនេះមកនៅទីនេះទេ ។ ដូច្នេះហើយ ខ្ញុំសង្ឃឹមថា អ្វីដែលខ្ញុំបានបញ្ជាក់នេះ គឺច្បាស់លាស់ចំពោះអង្គសវនាការ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន ខ្ញុំជឿថាបញ្ហាចោទនេះ គឺបានលើកឡើងច្រើនដងច្រើនសាមកហើយ លើកទីមួយនោះ គឺក្នុងកិច្ចប្រជុំរៀបចំសវនាការ នៅពេលនោះគឺយើងបាននិយាយអំពីការប្រមូលផ្តុំបញ្ជីសាក្សី ហើយបន្ទាប់មកយើងបានលើក បាននិយាយថា យើងបានដកសាក្សីមួយចំនួននៅក្នុងបញ្ជី ដែលយើងសម្រេចថា អានចម្លើយទៅវិញ ។ ហើយមេធាវីការពារក្តីក៏បានបញ្ជាក់ថា គាត់យល់ស្របផងដែរថាមិនចាំបាច់ឲ្យសាក្សីចូលខ្លួនមកក្នុងសវនាការនោះទេ ។

[១២:០៨:១៩]

ដូច្នេះហើយ មេធាវីការពារក្តីក៏គាត់មិនជំទាស់ថា គាត់មិនផ្តល់ការសង្កេតរបស់គាត់នោះដែរ ។ ប៉ុន្តែ នៅពេលនេះ លោកបានលើកឡើងទៅលើចំណុចនេះ ។ ខ្ញុំជឿថាការពិសប្តាហ៍មុន យើងបានទទួលការបញ្ជាក់ពីមេធាវីការពារក្តីហើយ ថាមេធាវីការពារក្តីគាត់សម្រេច ហើយក៏មិនជំទាស់ទៅលើការមិនកោះហៅសាក្សីនោះដែរ ។

ដូច្នេះហើយ ខ្ញុំហាក់ដូចជាមិនយល់ទៅលើសេចក្តីសន្និដ្ឋាន ដែលលើកឡើងដោយសហព្រះរាជអាជ្ញានៅពេលនេះជាក់លាក់នោះទេ ។ យើងដឹងហើយថា យើងត្រូវអនុវត្តតាមវិធានរបស់យើង ហើយយើងដឹងថា មេធាវីការពារក្តីក៏គាត់មិនច្រានចោល ហើយជំទាស់ទៅលើការអនុវត្តវិធាននេះដែរ ។

**លោក អានីស អះមេដ៖**

សូមបញ្ជាក់ ហើយខ្ញុំមិនមានការជំទាស់ទេ ។ សូមអង្គសវនាការជ្រាបទៅលើចំណុចនេះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះច្រានចោលនូវការកត់សម្គាល់ របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដោយកិច្ចការនេះជារឿងរបស់មេធាវីការពារក្តី ហើយសិទ្ធិរបស់គាត់មានពេញលេញ ។ អ៊ីចឹង មេធាវីការពារក្តីមិនបានធ្វើការជំទាស់អ្វីទេនឹងការដែលអង្គជំនុំជម្រះ មិនបានសម្រេចមិនកោះហៅសាក្សី តយ តេង

មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ ហើយអម្បាញ់មិញនេះ គឺខាងអ្នកមេធាវីការពារក្តីបាន ធ្វើការកត់សម្គាល់រួចហើយលើ ខ្លឹមសារនេះសក្ខីកម្មរបស់សាក្សីរូបនោះ ។

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់ឱកាសដល់ទៅជនជាប់ចោទដើម្បីធ្វើការកត់សម្គាល់លើសក្ខី-កម្មរបស់សាក្សីឈ្មោះ តយ តេង នៅលើខ្លឹមសារនៃកំណត់ហេតុ ដែលអានដោយក្រឡាបញ្ជីសវនាការ អម្បាញ់មិញនេះទាំងពីរឯកសារ ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! មុនថ្ងៃ៧ មករា ១៩៧៩ ខ្ញុំមិនដែលស្គាល់មុខមិត្តតេង ទេ ។ នៅពេល ដែលជួបមិត្តតេង គឺនៅពេលដែលខ្ញុំត្រូវបញ្ជូន-- ខ្ញុំត្រូវចៅក្រមស៊ើបអង្កេតជូនទៅជើងឯក ដើម្បីធ្វើការ បង្ហាញ ។ នៅពេលនុ៎ងដែលខ្ញុំដឹងថា មិត្តតេង ជាប្អូនជីដូនមួយរបស់មិត្ត តែម ហើយនិងមិត្តសារឿន ។ ទាំងពីរនាក់នេះសុទ្ធតែថ្នាក់វរសេនាធំ ។ ដល់គេចាប់បងជីដូនមួយទៅ គេក៏បញ្ជូនមិត្តតេង គេអឺ ស-២១ បញ្ជូនមិត្ត តេង ទៅពីកងពិសេសទៅនៅជើងឯកប្រចាំការនៅនុ៎ង ។ គ្នាគេបើតាមខ្ញុំចាំ ហើយដែល មិត្តហ៊ី រាយការណ៍មានប្អូននាក់ ទទួលភារកិច្ចដីករណ្តៅ លប់ ហើយនិងយាមការពារកន្លែងនុ៎ងកុំ ឲ្យអ្នកណាចូលទៅឆាឆៅ ។

[១២:១១:៤២]

ដូច្នេះ តេង-- តយ តេង នេះ គឺពិតជាបុគ្គលិករបស់មន្ទីរស-២១ ខ្ញុំអត់ប្រកែកមួយម៉ាត់ទេ ។ ដោយឡែកខ្លឹមសារនៃសក្ខីកម្មរបស់គេ ខ្ញុំទទួលស្គាល់ជាមូលដ្ឋាន។ នេះខ្ញុំសូមបញ្ចាក់ប៉ុណ្ណេះ ។ សូម គោរព ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលត្រូវពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសា អាហារថ្ងៃត្រង់ អង្គសវនាការនឹងលើកទៅបន្តនៅរសៀលនេះ ចាប់ពីម៉ោងមួយនិងសាមសិបនាទី ។ ហើយនីតិវិធីនៃសវនាការរសៀលនេះ គឺបន្តនៃការអាននូវកំណត់ហេតុសាក្សីដែលអង្គជំនុំជម្រះបាន សម្រេច មិនកោះហៅសាក្សីទាំងនោះមកផ្តល់សក្ខីកម្មដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ ។

អនុរក្សមន្ទីរឃុំឃាំង ឲ្យនាំជនជាប់ចោទទៅកាន់បន្ទប់សម្រាក ហើយឲ្យនាំគាត់មកកាន់សាល សវនាការវិញនៅរសៀលនេះ ហើយឲ្យបានមុនម៉ោងមួយកន្លះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង១២:១៣នាទី ដល់ម៉ោង ១៣:៣៥នាទី]*

[១៣:៣៥:១៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ ជាកិច្ចបន្តនេះចាត់លោក ឌុច ផារី ក្រឡាបញ្ជីសវនាការឱ្យឡើងអាននូវកំណត់ហេតុស្តាប់ចម្លើយសាក្សី សោម សំអុល ឯកសារដែលមានលេខ D78/6 ។

**លោក ឌុច ផារី៖**

ឯកសារលេខ D78/6 ។ នេះគឺជាកំណត់ហេតុនៃការ--

**ប្រធានអង្គជំនុំ៖**

ឈប់ៗ កុំអាលអាន ។

សូមអញ្ជើញ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

អរគុណលោកប្រធាន ។ ខ្ញុំគិតថា មានឯកសារ D48/1 ហើយអ៊ីចឹងហើយឯកសារហ្នឹងត្រូវបានអានហើយ ។ តើឯកសារទាំងអស់នេះនឹងត្រូវយកអានពេលក្រោយ ជាពិសេសទាក់ទងទៅនឹងកថាខណ្ឌ ដែលទាក់ទងទៅនឹង មាស ប៉េងគ្រី ។ ខ្ញុំសុំឱ្យអង្គជំនុំជម្រះ មេត្តាបំភ្លឺត្រង់ចំណុចនេះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ បានជម្រាបជូនដល់ភាគី និងសាធារណជន អំពីនីតិវិធីនៃការប្រព្រឹត្តិទៅនៅក្នុងការអាននូវកំណត់ហេតុនូវសាក្សីដែលអង្គជំនុំជម្រះបានសម្រេចថា មិនចាំបាច់កោះហៅគាត់ឱ្យផ្តល់ចម្លើយនៅចំពោះមុខអង្គជំនុំជម្រះ កាលពីម្សិលមិញយ៉ាងច្បាស់លាស់រួចហើយ ។ នៅក្នុងនោះគិតទាំងកិច្ចការពាក់ព័ន្ធនឹងក្រឡាបញ្ជីសវនាការ ត្រូវអាននូវកំណត់ហេតុតទល់នឹងកំណត់ហេតុចុះដល់ពិនិត្យទីកន្លែងកើតហេតុ ដែលជាកិច្ចការក្រោយគេសម្រាប់កិច្ចការថ្ងៃនេះ ។ អ៊ីចឹង ច្បាស់លាស់ហើយពីបញ្ហានេះនៅក្នុងការសេចក្តីជូនដំណឹងព័ត៌មាន ដោយខ្ញុំប្រធានអង្គសវនាការសាលាដំបូង បានជម្រាបជូនដល់

អង្គសវនាការទាំងមូលកាលពីព្រឹកម្សិលមិញ ។

សូមអញ្ជើញលោក ឌុច ផារី ។

**លោក ឌុច ផារី៖**

ឯកសារលេខ D78/6 ។ នេះគឺជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម សំអុល ឈ្មោះបដិវត្តន៍ឈ្មោះ ឃួន សំ កើតនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៥៧ ។ កំណត់ហេតុនេះ បានធ្វើនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨ វេលាម៉ោងដប់ប្រាំនិងដប់នាទី ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

[១៣:៣៩:៤៧]

សំណួរ៖ តើលោកស្គាល់ទួលស្លែងនៅពេលណា? តាមរយៈអ្វី? ហើយនៅពេលនោះលោកមានតួនាទីជាអ្វី?

ចម្លើយ៖ ខ្ញុំធ្វើជានីរសាររបស់ក្រសួងការបរទេស ចាប់ផ្តើមចុងឆ្នាំ១៩៧៦ ប្រធានក្រុមនីរសារឈ្មោះ វឿន មិនដឹងស្លាប់ ឬរស់ទេសព្វថ្ងៃ ។ ខ្ញុំបានស្គាល់មន្ទីរស-២១ ដោយសារប្រធានខ្ញុំឈ្មោះ វឿន បានឲ្យខ្ញុំនាំសំបុត្រដែលមានចារលើខ្នងថា “ជូនសមមិត្ត ឌុច ប្រធានមន្ទីរស-២១” ផ្ទះរបស់ ឌុច នោះគឺនៅខាងក្រៅរបងមន្ទីរ នៅទល់មុខផ្ទះខ្ពស់មួយដែលគេនិយមហៅថា ស្រះស្រង់ ។ ខ្ញុំបានហុចសំបុត្រទៅឲ្យ ឌុច ផ្ទាល់ ហើយមានមានឈ្មោះ ឆេន និងឈ្មោះ ថាន់ ជាអ្នកចុះសំបុត្រទទួល មានចុះលេខ ។ បន្ទាប់មកខ្ញុំកាន់កូនក្រដាសតូចមួយ ដែល ឌុច សរសេរថា បានទទួលសំបុត្រលេខប៉ុន្មាន ។ ខ្ញុំមិនដែលនាំសំបុត្រពីមន្ទីរស-២១ ត្រឡប់ទៅក្រសួងការបរទេសវិញទេ ។

ខ្ញុំឃើញឈ្មោះ ឆេន នាំសំបុត្រនិងឯកសារទៅកាន់ក្រសួងការបរទេស ។ ឯកសារទាំងនេះដឹកតាមម៉ូតូសេអិល កម្រាស់ប្រហែលជាពីរតឹកជាង ចួនតិច ចួនច្រើន ។ ពេលខ្លះ ខ្ញុំបានសួរ ឆេន ហើយគាត់ឆ្លើយថា ឯកសារទាំងនេះយកទៅឲ្យអ៊ំពិនិត្យ ។ ឌុច ធ្លាប់បានប្រាប់ខ្ញុំ កុំឲ្យប្រាប់អ្នកណាផ្សេង អំពីការនាំសំបុត្រមកឲ្យគាត់ បើមិនដូច្នេះទេ គាត់នឹងរាយការណ៍ប្រាប់ អៀង សារី ឲ្យចាប់ខ្លួនខ្ញុំ ។ ខ្ញុំឃើញ ឆេន យកឯកសារទៅប្រហែលជាមួយអាទិត្យម្តងៗ ។ ភាគច្រើនជាឯកសារសរសេរដៃ ចម្លើយសារភាពរបស់អ្នកទោស ។ តាមខ្ញុំដឹង ឆេន បានស្លាប់នៅភ្នំក្រវាញក្នុងឆ្នាំ១៩៧៩ ពេលធ្វើសង្គ្រាមជាមួយវៀតណាម ។ ក្រោយមកខ្ញុំឃើញមានចាប់បុគ្គលិកក្រសួងការបរទេសជាបន្តបន្ទាប់ ។ មុននេះបន្តិចតាំងពីឆ្នាំ១៩៧៦ ខ្ញុំបានដឹងពីស-២១ ដោយសារនៅពេលដែលខ្ញុំកំពុងរៀនថតកុននៅប១ ខ្ញុំធ្លាប់

ឃើញ ប៉េង មកពីស-២១ មកចាប់មនុស្សនៅក្បែរៗខ្ញុំ ។

សំណួរ៖ សូមលោករៀបរាប់ពីពេលដែលលោកទៅធ្វើការនៅព្រំដែនវៀតណាម?

ចម្លើយ៖ នៅក្នុងឆ្នាំ១៩៧៧ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅទល់ដែន អស់រយៈពេលប្រហែលពីរខែ ។ នៅក្នុងរ:ពេលនោះ ខ្ញុំបានឃើញកងពលរបស់ តាល្វៃ និង តាណាត បានរល់ចូលទៅមុខក្នុងទឹកដីវៀតណាម ។ ខ្ញុំបានឃើញទាហានកងពលនេះ ចាប់បានទាហានវៀតណាម ពាក់ឯកសណ្ឋានខៀវៗ មានស្រី និងជនស៊ីវិលផង តែភាគច្រើនជាទាហាន ។ សរុបទាំងអស់មានប្រហែលសែសិបនាក់ ស្ត្រីមានប្រហែលបី ឬបួននាក់ប៉ុណ្ណោះ ។

[១៣:៤៣:៤៨]

ខ្ញុំដឹងថា អ្នកដែលទទួលយកអ្នកទោសសង្គ្រាមទាំងនេះ នឹងត្រូវបញ្ជូនអ្នកទោសសង្គ្រាមមកមន្ទីរស-២១ ដោយសារខ្ញុំស្គាល់អ្នកដែលទៅយកនោះគឺក្រុមរបស់ ឆេន គឺឈ្មោះ ថាន់, ប៉េង និង ហ៊ី ។ ខ្ញុំបានឃើញទាហានកងពលទាំងនោះ តែងបាញ់សម្លាប់ឈ្លើយសឹកនៅពេលយប់ គឺទុកតែអ្នកដែលមានស័ក្តិខ្ពស់ ។ ខ្ញុំដឹងរឿងនេះ ដោយសារខ្ញុំបានឃើញទូរលេខ និងបានឮអំពីការបញ្ជារបស់ថ្នាក់លើតាមទូរលេខពីភ្នំពេញមក ។ ខ្ញុំដឹងថាថ្នាក់លើ តែមិនដឹងថាអ្នកណា ។ មិនយូរប៉ុន្មាន ក្រោយពីការបញ្ជានោះ ឈ្លើយសឹកក៏បានដឹកទៅស-២១ ។ ឈ្លើយសឹកទាំងនោះ ត្រូវបានដឹកតាមឡានរបស់ចិន និងឡាន*ឡង់វ៉ូវ័រ* ដែលមានដាក់ផ្លាក ស-២១ នៅពីក្រោយ ។

សំណួរ៖ តើលោកធ្លាប់ឃើញ ឌុច ចូលរួមប្រជុំជាមួយថ្នាក់លើដែរឬទេ?

ចម្លើយ៖ នៅឆ្នាំ១៩៧៧ ខ្ញុំធ្លាប់បានឃើញ ឌុច ចូលរួមប្រជុំនៅក្រសួងប១ ជាមួយ អៀង សារី, ប៉ុល ពត, សុន សេន, នួន ជា និង តាម៉ុក ។ ហើយ ឌុច តែងតែមកប្រជុំជាញឹកញាប់ ប្រហែលជាពីរបីថ្ងៃម្តង ជាមួយថ្នាក់លើ រហូតដល់ពេលបែកឆ្នាំ១៩៧៩ ។ ពេលខ្លះ ឌុច មកជួបតែពីរនាក់ ជាមួយសុន សេន ឬ តាម៉ុក និងប្រធានភូមិភាគផ្សេងៗ ។ ខ្ញុំដឹងរឿងនេះ ពីព្រោះខ្ញុំនៅខាងក្រោម ហើយឃើញថ្នាក់លើទៅប្រជុំខាងលើ ។ ខ្ញុំតែងតែឃើញ ឌុច កាន់សឺមីឯកសារមកដូចគ្នា និងឯកសារដែល ឆេន ដឹកម៉ូតូមក ប្រហែលជាចម្លើយសារភាព ។

សំណួរ៖ តើលោកនៅចាំថា មានបុគ្គលិក ប១ ណាខ្លះត្រូវបានចាប់ខ្លួននៅមន្ទីរស-២១?

ចម្លើយ៖ ខ្ញុំនៅចាំឈ្មោះ មិត និង ឈ្មោះ រឿន ស្រុកកំណើតនៅខេត្តតាកែវ មកពីកងពល៣១០ ត្រូវបានចាប់ខ្លួន ដោយសារមេរបស់គាត់ក៏ត្រូវចាប់ខ្លួនរួចហើយដែរ ។

សំណួរ៖ តើលោកគិតថា មេរបស់ ប១ មិនបានដឹង ឬមិនបានយល់ស្របជាមួយការចាប់ខ្លួនបុគ្គលិក ប១ យកទៅមន្ទីរ ស-២១ ដែរឬទេ?

ចម្លើយ៖ ខ្ញុំគិតថា មេរបស់ ប១ ប្រាកដជាដឹង ពីព្រោះសុទ្ធតែមានឯកសារយកមកឆ្លងយោបល់ពីរបីថ្ងៃមុនចាប់ ហើយមានប្រជុំផង ។ ដូចខ្ញុំបានរៀបរាប់ខាងលើ ។

សំណួរ៖ តើលោកបានដឹងអ្វីខ្លះពីការរៀបការរបស់ ឌុច?

ចម្លើយ៖ ខ្ញុំបានចូលរួម ខ្ញុំឃើញអ្នកចូលរួមមានឈ្មោះ សុន សេន, នួន ជា និង អៀង ធីរិទ្ធ ។ កន្លែងរៀបការនេះ គឺនៅផ្ទះរបស់ ឌុច ទល់មុខស្រះស្រង់ ។ ដូច្នេះ ខ្ញុំគិតថា ឌុច ជាមនុស្សសំខាន់ ដោយសារមានអ្នកធំៗចូលរួមពិធីរៀបការរបស់គាត់ ហើយខ្ញុំគិតថា ទាំងអស់គ្នាពិតជាបានដឹងអំពីមន្ទីរ ស-២១ និងការងាររបស់ ឌុច ព្រោះ ឌុច ដូចជាបើកចំហដែរ ។ ខ្ញុំមិនបានដឹងអំពីគុកផ្សេងៗទៀតទេ ពីព្រោះខ្ញុំមិនដែលត្រូវបានអនុញ្ញាតឲ្យទៅលេងផ្ទះនៅមូលដ្ឋានទេ ។

សំណួរ៖ តើលោកធ្លាប់ដឹងអំពីចរិតរបស់ ឌុច ដូចម្តេចខ្លះ តាមរយៈការងាររបស់លោក?

ចម្លើយ៖ ខ្ញុំសង្កេតឃើញថា គាត់ពេញចិត្តនឹងការងាររបស់គាត់ ដោយសារពេលខ្ញុំជួប ឃើញគាត់ញញឹមរាក់ទាក់ និងធ្វើការស្វាហាប់ ។ ពេលខ្លះប្រាប់ខ្ញុំឲ្យប្រញាប់មកកន្លែងវិញ កុំឲ្យនិយាយលេងយូរ ។ ខ្ញុំឃើញគាត់ភាគច្រើនជិះម៉ូតូ សេអ៊ីុល ដែលគាត់ឲ្យនីរសារជិះ ពេលខ្លះគាត់ជិះឡានហ្ស៊ីប ។

ឯកសារច្បាប់ដើម ឬថតចម្លងនៃកំណត់ហេតុមួយច្បាប់ ត្រូវបានប្រគល់ឲ្យសាក្សីនេះ ។

អានឲ្យស្តាប់ហើយ សាក្សីមិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ។

[១៣:៤៩:៣៧]

**ប្រធានអង្គជំនុំ៖**

ជាបន្ត លោក ឌុច ផារី ឡើងធ្វើ-- អាននូវសេចក្តីសង្ខេបកំណត់ហេតុសាក្សីមួយរូបទៀត ជ័យ សូភារ៉ា ដែលជាខ្លឹមសារសង្ខេបពីកំណត់ហេតុស្តាប់ចម្លើយសាក្សីរូបនោះ ដែលមានឯកសារ D83/1 ។

**លោក ឌុច ផារី៖**

ឯកសារលេខ D83/1 ។

នេះ គឺជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជ័យ សូភារ៉ា៖

លោក ជ័យ សូភារ៉ា គឺជាអនុប្រធាននៃអគ្គនាយកដ្ឋានសារមន្ទីរ ទទួលបន្ទុកសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ នៅការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០០៨ ។ ឯកសារយោងលេខ D82/3 លោកបានរៀបរាប់អំពីការប្រមូលការរៀបចំ និងតម្កល់ឯកសារទាំងឡាយ រួមមានចម្លើយសារភាព ហ្វីល រូបថត និងអ្វីៗផ្សេងទៀត ដែលបានប្រទះឃើញនៅជុំវិញបរិវេណមន្ទីរស-២១ និងតំបន់ដែលនៅជុំវិញបរិវេណនោះ"។

**ប្រធានអង្គជំនុំ៖**

បន្ទាប់ពីការអាននូវកំណត់ហេតុចំនួនពីរ គឺកំណត់ស្តាប់ចម្លើយសាក្សី សោម សំអុល ហើយនិងខ្លឹមសារនៃសង្ខេបចម្លើយសាក្សី ជ័យ សូភារ៉ា ។ តើតំណាងសហព្រះរាជអាជ្ញាមានអ្វីចង់កត់សម្គាល់លើឯកសារទាំងពីរនេះទេ?

ខ្ញុំសូមជម្រាបថា ឯកសារទាំងពីរនេះដាច់ដោយឡែកពីគ្នា ។ ប៉ុន្តែ ដោយសារខ្លឹមសារនៃកំណត់ហេតុទាំងពីរនេះមានលក្ខណៈខ្លី ហើយមួយទៀត គឺធ្វើការសង្ខេបដោយសារខ្លឹមសារ គឺសរុបមកមានតែប៉ុណ្ណឹងទេ ។ តើលោកខាងសហព្រះរាជអាជ្ញាមានអ្វីចង់កត់សម្គាល់ដែរឬទេ?

[១៣:៥២:១០]

**លោក តាន់ សេណារ៉ុង៖**

សូមអរគុណលោកប្រធានអង្គជំនុំជម្រះ តំណាងសហព្រះរាជអាជ្ញាពុំមានអ្វីកត់សម្គាល់ទៅលើកំណត់ហេតុទាំងពីរនេះទេ ។

**ប្រធានអង្គជំនុំ៖**

ចុះខាងផ្នែកមេធាវីអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី តើមានអ្វីកត់សម្គាល់លើការអាននូវខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី សោម សំអុល ហើយនិងខ្លឹមសារសង្ខេបនៃសាក្សី ជ័យ សូភារ៉ា ដែរឬទេ?

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនមានយោបល់អ្វីទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ចុះខាងមេធាវីការពារក្តីមានអ្វីកត់សម្គាល់លើខ្លឹមសារនៃចម្លើយ-- ឯកសារស្តាប់ចម្លើយសាក្សីទាំងពីរដែលអាន និងសង្ខេបដោយក្រឡាបញ្ជីសវនាការអំឡុងព្រឹកមិញនេះដែរឬទេ?

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន យើងខ្ញុំជាមេធាវីការពារមិនមានអ្វីកត់សម្គាល់ទៅលើឯកសារទាំងពីរនេះទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាចុងក្រោយនេះ គឺអង្គជំនុំជម្រះផ្តល់ឱកាសដល់ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់នូវលើខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងពីរ ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! សេចក្តីសង្ខេបរបស់លោក ជ័យ សូភារ៉ា ខ្ញុំបាទផ្ទាល់អត់មានយោបល់ទេ។ ដោយឡែកចំពោះករណីសាក្សី ចេក សំ ដែលមានឈ្មោះដើមហៅថា សោម សំអុល ឬក៏ឈ្មោះមួយទៀតហៅថា ភួន សំអុល ខ្ញុំសូមជូន អានជូននូវសំណួររបស់លោកចៅក្រម ម៉ាសែល ឡឺម៉ុងដ៏ ហើយនិងចម្លើយរបស់ខ្ញុំ ។ នៅក្នុងកំណត់ហេតុ D47 ដូចតទៅ៖

សំណួររបស់លោកសហចៅក្រមស៊ើបអង្កេត ម៉ាសែល ឡឺម៉ុងដ៏ លោកបាននិយាយថា៖ លោកគ្មានការទាក់ទងជាមួយមេដឹកនាំជាន់ខ្ពស់ទេ ក្រៅពី សុន សេន និង នួន ជា ។ ប៉ុន្តែ មានសាក្សីម្នាក់ឈ្មោះ ចេក សំ ដែលជាអតីតនីរសាររបស់ក្រសួងការបរទេស ដែលមានសម្ភាសន៍ដោយ *ឌីស៊ីខេម* លេខ ERN 00054752 ដល់ 0054814 ចុះថ្ងៃទី១២ កក្កដា ២០០២ ។ បាននិយាយថា “នៅក្នុងពិធីរៀបការរបស់លោក មានការចូលរួមអំពីសំណាក់ នួន ជា, សុន សេន, អៀង សារី និងខៀវ សំផន រួមជាមួយនឹងអ្នកថតខ្សែភាពយន្តជាជនជាតិចិនផងដែរ ។ តើនេះជាការពិតមែនឬទេ? និងបើពិតមែនហេតុអ្វីបានជាមេដឹកនាំជាន់ខ្ពស់ទាំងនេះចូលរួមក្នុងពិធីរៀបការរបស់លោក?”

[១៣:៥៦:០៨]

ឆ្លើយ៖ ខ្ញុំសូមឆ្លើយថា ចម្លើយនេះមិនត្រឹមត្រូវទេ មេដឹកនាំជាន់ខ្ពស់ទាំងនោះ មិនមានវត្តមាននៅក្នុងពិធីរៀបការរបស់ខ្ញុំនៅថ្ងៃ២០ ធ្នូ ១៩៧៥ នោះទេ ហើយក៏មិនមានវត្តមានក្រុមអ្នកថតកុនជនជាតិចិនដែរ ។ ខ្ញុំមិនដឹងថា ហេតុអ្វីបានជាឈ្មោះ ចេក សំ នោះនិយាយបែបនេះនោះទេ ។ ខ្ញុំគិតថា បុគ្គលនេះមិនមែនជានីរសាររបស់ក្រសួងការបរទេសនោះ ប៉ុន្តែ ប្រហែលជាបុគ្គលិកម្នាក់របស់ស-២១ ។ ខ្ញុំបានសរសេរកំណត់ដៃមួយអំពីចំណុចនេះ ដែលខ្ញុំប្រគល់ជូនលោកចៅក្រម ដើម្បីដាក់ជាឧបសម្ព័ន្ធនៃកំណត់ហេតុនេះ ។

តទៅទៀតនេះ ខ្ញុំសូមអានអំពីកំណត់ដៃ ដែលខ្ញុំជូនសហចៅក្រមជាឧបសម្ព័ន្ធ ។ កំណត់ដៃនេះមានលេខ00164353 ។ ខ្ញុំសូមអានម្តងទៀត ERN ម្តងទៀត 00164353 ។ ប្រធានបទទីពីរ “ទំនាក់ទំនងរបស់ស-២១ ជាមួយអចិន្ត្រៃយ៍មជ្ឈិម”៖

កថាខណ្ឌទី១៖ ខាងស-២១ មានតែខ្ញុំ ឌុច ជាប្រធានទេ ដែលអាចរាយការណ៍ឯកសារសន្តិបាលជូនអចិន្ត្រៃយ៍បាន ។ ខាងអចិន្ត្រៃយ៍ក៏មានតែ សុន សេន ហើយធំពីលើ សុន សេន ទៀត គឺ នួន ជា ដែលមានភារកិច្ចជាប្រចាំគ្រប់គ្រងស-២១ ខាងការងារសន្តិបាល ។

កថាខណ្ឌទី២៖ ចេក សំ ខ្ញុំចាប់អារម្មណ៍ថាជាបុគ្គលិក ស-២១ ពេលនោះ គាត់ជាក្មេងជំទង់ម្នាក់ ក្នុងចំណោមក្មេងជំទង់មួយក្រុម ដែលខ្ញុំសុំមកពីកំពង់ឆ្នាំង ។ ថ្ងៃរៀបការខ្ញុំ គ្មាន នួន ជា, អៀង សារី, សុន សេន និង ខៀវ សំផន ចូលរួមទេ ។ ពេលនោះ ក៏គ្មានអ្នកបច្ចេកទេសភាពយន្តចិន មកថតភាពយន្តដែរ ។

សូមបន្ថែម៖

១) ខ្ញុំរៀបការនៅថ្ងៃ២០ ធ្នូ ១៩៧៥ នៅមន្ទីរយោធាភូមិភាគបស្ចិម បន្ទាយលង្វែក (មិត្តរុំ ប្រពន្ធខ្ញុំជាប្រធានមន្ទីរកាត់ដេរ ជាអង្គភាពមួយរបស់យោធាភូមិភាគដែរ) ។

២) គណៈអធិបតីមាន បង សាន (អនុលេខាគណៈកម្មាធិការយោធាភូមិភាគបស្ចិម) ។ មិត្តរុំ សមាជិកគណៈកម្មាធិការយោធាភូមិភាគបស្ចិម, ណាត លេខា ស-២១ ។

៣) មាតាបិតាកូនប្រុសកូនស្រី គឺម្តាយបង្កើតរបស់ខ្ញុំ ។ ម្តាយធម៌ខ្ញុំ និងស្ត្រីវ័យចាស់ម្នាក់ ។

[១៣:៥៩:៣០]

៤) ភ្ញៀវដែលអាចស្គាល់ នួន ជា, អៀង សារី, សុន សេន, ខៀវ សំផន គឺ ម៉ម ណៃ ស-២១, មិត្ត វន ប្រធានមន្ទីរពេទ្យយោធាភូមិភាគបស្ចិម ឈ្មោះពិត ម៉ា ស៊ីវន, ភរិយាឧត្តមសេនី ស៊ូ សាម៉េត បញ្ជាការរងភូមិភាគប្រាំ បច្ចុប្បន្ន ។ កាលនោះ មានអ្នកថតរូបសខ្មៅតិចតួចទេ ។ មិត្តដែលថតរូបប្រហែលជាមិត្ត ស្រ៊ាង ស-២១ ។

ម៉ោងដប់ប្រាំពីរជាង ណាត នាំខ្ញុំ និងប្រពន្ធមកភ្នំពេញ ។ មកដល់ ណាត ហៅកម្មាភិបាលអនុសេនាធំ អនុសេនាតូចមកចូលរួម ដើម្បីឲ្យក្មេងៗទាំងអស់នេះស្គាល់មិត្ត គុណ ប្រពន្ធគាត់ និងមិត្តរុំ ប្រពន្ធខ្ញុំ ។ ព្រោះពេលគាត់រៀបការ ក្មេងៗអស់នេះគ្នាអត់បានចូលរួមទេ ។ នាំគ្នាដាំបបរមាន់នៅផ្ទះលេខពីរ ផ្ទះដែលខ្ញុំដាក់លេខពីរនេះ គឺភូមិគ្រឹះរបស់លោកតា វេជ្ជបណ្ឌិត ម៉ី សាម៉ឺឌី ក្នុងផែនទី ស-២១

របស់ខ្ញុំ ។ ទម្រាំផ្អិនម៉ោងម្ភៃបី ឬម៉ោងម្ភៃបួនទៅហើយ ។ សម័យនោះគ្មាននរណា គេឲ្យតម្លៃដល់ការរៀបការកម្មាភិបាលអីខ្លាំងពេកទេ សូម្បីតែបង សៀង ដែលជាលេខាគណៈកម្មាធិការឃោធាបស្ចិម សុខចិត្តនិយាយជាមួយនឹងមិត្តរុំ ថារវល់ ហើយគេចទៅកោះកុងបាត់ ។

សំណូមរបស់ខ្ញុំពេលនោះមានពីរ ហើយមិនប៊ានទាំងនិយាយឲ្យអ្នកណាដឹងផង ។ ទីមួយ ចង់ឲ្យគេរៀបការឲ្យខ្ញុំតែមួយគូរ ពេលនោះចាប់ផ្តើមមានការរៀបការម្តងៗច្រើនគូរ ។ ទីពីរ ចង់ឲ្យម្តាយខ្ញុំឡើងឲ្យពរខ្ញុំ និងប្រពន្ធខ្ញុំ។ គេមិនដឹងសំណូមពរខ្ញុំទេ តែគេធ្វើទៅខ្ញុំពេញចិត្ត ។ ថ្ងៃ២៩ កុម្ភៈ ២០០៨ ។

នេះជាសេចក្តីបញ្ជាក់របស់ខ្ញុំ ជូនចៅក្រមស៊ើបអង្កេត ដែលសូមអានជូនអង្គសវនាការនៅពេលនេះ ដោយគោរព ។ សូមចប់ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ ចាត់លោកស្រី សែ កុលវុឌ្ឍី អានន្ទូវឯកសារ D48/1 ហើយនិងឯកសារ D52 នូវផ្នែកដែលមិនទាន់បានអាន តាមសំណើសុំរបស់មេធាវីការពារក្តី ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី និងសាធារណជនថា កាលពីពេលកន្លងទៅនេះ យើងបានអានន្ទូវកំណត់ហេតុស្តាប់ចម្លើយ មាស ប៉េងគ្រី ឯកសារ D28/7 រួចហើយ។ ប៉ុន្តែ ដោយបញ្ហាបច្ចេកទេស យើងអាក់ខានមិនបានអានន្ទូវឯកសារដែលពាក់ព័ន្ធ ។ ដូច្នេះ ពេលនេះយើងអានន្ទូវខ្លឹមសារឯកសារ ដែលពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់សាក្សី មាស ប៉េងគ្រី នៅលើឯកសារចំនួនពីរជាបន្ត មុននឹងផ្តល់ឱកាសទៅភាគី ដើម្បីធ្វើការកត់សម្គាល់នូវសក្ខីកម្មរបស់សាក្សីរូបនេះ ។

អានន្ទូវផ្នែកដែលពាក់ព័ន្ធជាមួយនឹងសាក្សី មាស ប៉េងគ្រី បានហើយ ។

[១៤:០៣:៣៥

**លោកស្រី សែ កុលវុឌ្ឍី៖**

ឯកសារលេខ D48/1 នេះ គឺជាកំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

“នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨ វេលាម៉ោងប្រាំបីព្រឹក នៅទីកន្លែងមណ្ឌលប្រល័យពូជសាសន៍ជើងឯក ដែលស្ថិតនៅចម្ងាយដប់ប្រាំគីឡូម៉ែត្រ ខាងទិសនិរតីទីក្រុងភ្នំពេញក្នុងខេត្តកណ្តាល ដែលមានវត្តមានលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលចូលរួមដោយមេធាវីរបស់ខ្លួនលោក ការ សាវុត្ថ និងលោក ហ្វ្រង់ស្វ័រ រូ ។ សាក្សី មាស ប៉េងគ្រី, ហ៊ឹម ហ៊ុយ, ឈុន ផល និង តយ តេង ។

កថាខណ្ឌទី១៖ នៅពេលកោះហៅជនជាប់ចោទ ប្រកាសថា ស្គាល់តែ ហ៊ីម ហ៊ុយ ម្នាក់ប៉ុណ្ណោះ ក្នុងចំណោមសាក្សីទាំងបួន ។ សាក្សី មាស ប៉េងគ្រី បាននិយាយថា មិនដែលបានជួបជនត្រូវចោទទេ ប៉ុន្តែស្គាល់មុខរបស់ជននេះ ។

កថាខណ្ឌទី២៖ មាស ប៉េងគ្រី ប្រកាសថា ខ្លួនធ្លាប់មកទីនេះម្តង កាលពីឆ្នាំទៅ ដើម្បីថតកុនជាមួយ ហ៊ីម ហ៊ុយ ។ គាត់បញ្ជាក់ថា គាត់មានឱកាសមកទីកន្លែងជាច្រើនដង ដូចជា នៅទសវត្សរ៍ទី៨0 តាមការអញ្ជើញរបស់អ្នកសារព័ត៌មាន និងអង្គការក្រៅរដ្ឋាភិបាល ។

កថាខណ្ឌ៣.១៖ សាក្សី មាស ប៉េងគ្រី ពន្យល់ថា នៅពេលដំបូងគាត់បានមកដល់ជើងឯក គឺដើម្បីដឹកជញ្ជូនឈើយកមកសាងសង់ផ្ទះ ។ គាត់បានដឹកឈើមកដាក់រួច ក៏ត្រឡប់ទៅវិញ ។ ក្រោយមកការដឹកអ្នកទោសក៏ធ្វើដូចគ្នាអ៊ីចឹងដែរ ។ គាត់បានធ្វើដំណើរតាមផ្លូវដដែលដូចសព្វថ្ងៃនេះ ដែលសម័យនោះផ្លូវនេះមិនទាន់ចាក់កៅស៊ូនៅឡើយ ហើយពិបាកទៀត និងចូលតាមច្រកចូលបច្ចុប្បន្ននៃជើងឯក ហើយចតឡានរបស់គាត់នៅជិតកន្លែងទង់ជ័យបច្ចុប្បន្ន ។ បន្ទាប់ពីអ្នកយាមទទួលអ្នកទោសរួចហើយ គាត់ក៏ត្រឡប់ទៅវិញ ។ គាត់ថា បានមកជើងឯកបានតែមួយ ឬពីរដងប៉ុណ្ណោះ ។ តាមពិតទៅបន្ទាប់ឧប្បត្តិហេតុមួយ គាត់ត្រូវបានគេបញ្ជូនទៅព្រៃស តាមបញ្ជារបស់ ហ៊ីម ហ៊ុយ ដើម្បីទៅធ្វើស្រែ និងបញ្ឈប់ការដឹកជញ្ជូនទៅជើងឯក ។ គាត់ងងុយគេងពេលបើកឡានរបស់គាត់ ហើយក្រឡាប់នៅក្បែរវត្តស្ទឹង ប៉ុន្តែមិនមានអ្នកទោសណាម្នាក់នៅឡាននោះទេ ។ តាមយោបល់គាត់មានស្លាកលេខឡាន ប៉ុន្តែគាត់មិនចាំទេថា លេខប៉ុន្មាន ។

កថាខណ្ឌ៤.១៖ សាក្សី មាស ប៉េងគ្រី ចង្អុលបង្ហាញអំពីទីតាំងផ្ទះនេះ ហើយបញ្ជាក់ថា វាមានទំហំទទឹងបួនម៉ែត្រ និងបណ្តោយប្រមាណប្រាំបីម៉ែត្រ ក្នុងកម្ពស់ពីរជាន់ ជាន់ផ្ទាល់ដី និងជាន់ទីមួយ ។

[១៤:០៧:២៥]

កថាខណ្ឌ៥.៤៖ នៅជិតរណ្តៅដែលគេរកឃើញឆ្អឹងរបស់ក្មេង សាក្សីប្រកាសថា ទាំងអស់គ្នាមិនដែលឃើញមានក្មេងនៅជើងឯកទេ ។ មាស ប៉េងគ្រី បញ្ជាក់ផងដែរថា គាត់មិនដែលឃើញមានក្មេងទេ ។

បន្ទាប់ពីប្រតិបត្តិការសម្តែងឡើងវិញខាងលើ អ្នកចូលរួមទាំងអស់ចាកចេញពីទីកន្លែងនាវេលាម៉ោងដប់ពីរនិងដប់ប្រាំនាទី ដោយគ្មានឧប្បត្តិហេតុអ្វីឡើយ ។ ការសម្តែងឡើងវិញត្រូវបានថតជាសំឡេង និងជារូបដែលបានប្រគល់ឲ្យជនត្រូវចោទមួយច្បាប់ផងដែរ ។

ឯកសារដើមនៃកំណត់ហេតុនេះត្រូវបានតាក់តែងឡើងជាភាសាខ្មែរ និងបារាំង និងបកប្រែជាភាសាអង់គ្លេស ។”

ឯកសារលេខ D52 “នេះ គឺជាកំណត់ហេតុនៃការតទល់មុខគ្នានៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៨ វេលាម៉ោងប្រាំបួន និងហាសិបនាទី ដែលមានវត្តមានមេធាវីការពារក្ដីលោក ការ សាវុត្ថ និង ហ្វ្រង់ស្វ័រ រូ, ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ សាក្សី ហ៊ីម ហ៊ុយ, តយ តេង, ឈុន ផល, មាស ប៉េងគ្រី ដែលបានស្បថរួចហើយ ស្របតាមវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។

ការតទល់មុខគ្នា៖

សំណួរលោកសហចៅក្រមស៊ើបអង្កេត ម៉ាកសែល ឡឺម៉ុងដ៍៖ កាលពីរពីថ្ងៃមុននេះ លោកទាំងអស់បានទៅជើងឯកជាមួយយើង ដើម្បីធ្វើការរៀបចំឡើងវិញ ។ តើលោកនៅតែអះអាងអ្វី ដែលលោកបាននិយាយនៅទីនោះដែរឬទេ?

សាក្សី មាស ប៉េងគ្រី៖ បាទ, ខ្ញុំនៅតែបញ្ជាក់អះអាងដដែល ។

សំណួរ៖ ក្នុងចំណោមអ្នកដែលមានវត្តមាននៅទីនេះ តើលោកម្នាក់ៗ ស្គាល់អ្នកណាខ្លះ?

សាក្សី មាស ប៉េងគ្រី៖ ខ្ញុំស្គាល់តែ ហ៊ីម ហ៊ុយ ទេ ។ ខ្ញុំមិនស្គាល់ តយ តេង ទេ ប៉ុន្តែវាអាចថាគាត់ស្គាល់ខ្ញុំ ពីព្រោះខ្ញុំជាអ្នកបើកឡាន ។

[១៤:១០:០៨]

សំណួរ៖ តើនេះជាលើកទីមួយដែលលោកទាំងអស់ត្រឡប់ទៅជើងឯកវិញ ចាប់តាំងពីឆ្នាំ១៩៧៩មកឬ?

សាក្សី មាស ប៉េងគ្រី៖ ខ្ញុំធ្លាប់បានទៅមួយដងហើយ ដើម្បីថតកុន គឺនៅពេលយប់ ហើយ ហ៊ីម ហ៊ុយ ក៏នៅទីនោះដែរ ។

សំណួរ៖ តើលោកម្នាក់ៗមានតួនាទីអ្វីខ្លះនៅជើងឯក?

សាក្សី មាស ប៉េងគ្រី៖ ខ្ញុំជាអ្នកបើកឡាន លើកទីមួយ ដែលខ្ញុំទៅជើងឯក គឺដើម្បីដឹកឈើទៅសង់ផ្ទះមួយ បន្ទាប់មកខ្ញុំបានដឹកអ្នកទោសពីរដងទៅទីនោះ ។ ប៉ុន្តែ មិនមានលើកក្រោយទៀតទេ ពីព្រោះមានថ្ងៃមួយនោះ ខ្ញុំមានគ្រោះថ្នាក់ឡាន មានតែមនុស្សបួននាក់ទេនៅក្នុងឡាន គឺខ្ញុំ, ហ៊ីម ហ៊ុយ

និងអ្នកយាមពីរនាក់ ។ ហើយខ្ញុំត្រូវបានដកយកទៅព្រៃសវិញ ដើម្បីរៀនសូត្រឡើងវិញ ។

ទាក់ទងនឹងស្ថានភាពនៃការទៅដល់ជើងឯក ច្រកចូលពីមុន គឺដូចពេលបច្ចុប្បន្នដែរ ប៉ុន្តែ ផ្លូវពីមុនលំបាកជាង ។ ខ្ញុំបានចតឡានទៅកន្លែងមួយដែលជាដងទង់ជាតិឥឡូវ ហើយអ្នកទោសចុះពីរថយន្តរួចត្រូវបាននាំចូលទៅក្នុងផ្ទះឈើ ។ ខ្ញុំបានចង្អុលបង្ហាញលោកចៅក្រមរួចហើយ ពីទីតាំងនៃផ្ទះនោះដែលខ្ញុំគិតថា មានបណ្តោយប្រមាណប្រាំបីម៉ែត្រនិងទទឹងបួនម៉ែត្រ ហើយមានពីរជាន់ ។ គឺដើម្បីសង់ផ្ទះឈើនេះហើយ ដែលខ្ញុំបានដឹកឈើទៅជើងឯក ប៉ុន្តែ ខ្ញុំមិនចាំកាលបរិច្ឆេទទេ ។ ខ្ញុំធ្វើតាមបញ្ជារបស់ ហ៊ឹម ហ៊ុយ ដែលជាមេរបស់ខ្ញុំ ហើយគាត់ជាអ្នកបញ្ជាខ្ញុំរាល់លើក ។

សំណួរ៖ នៅពេលដែលយើងបានធ្វើដំណើរទៅដល់ដើមឈើដែលគេចាត់ទុកថាជាកន្លែងដែលគេប្រើសម្រាប់សម្លាប់កុមារ លោកម្នាក់ៗបានប្រកាសថា លោកមិនដែលបានចូលរួមក្នុងការសម្លាប់បែបនេះទេ ។ តើលោកនៅតែនិយាយអ៊ីចឹងដដែលឬ?

សាក្សី មាស ប៉េងគ្រី៖ ខ្ញុំក៏មិនដែលដែរ ។

សំណួរ៖ លោក មាស ប៉េងគ្រី ទាក់ទងនឹងការចាប់ខ្លួន ធ្វើឡើងដោយបុគ្គលរបស់ ស-២១ នៅក្រៅភ្នំពេញ ។ តើលោកនៅបញ្ជាក់អះអាងថា លោកបានធ្វើការដឹកជញ្ជូនអ្នកទោសពីបាត់ដំបងមក ស-២១ ជាមួយ ហ៊ឹម ហ៊ុយ ដដែលឬ?

សាក្សី មាស ប៉េងគ្រី៖ បាទ, គឺពិតហើយ ។

ឯកសារច្បាប់ដើមនៃការថតរូបភាពនិងសំឡេង ត្រូវបានបិទស្លាកបោះត្រានៅចំពោះមុខជនត្រូវនេះ និងមេធាវីរបស់ជននេះ និងត្រូវបានចុះហត្ថលេខាដោយយើងក្រឡាបញ្ជី សហព្រះរាជអាជ្ញា ជនត្រូវចោទ និងមេធាវីរបស់ជននេះ ។

ឯកសារច្បាប់ដើមមួយច្បាប់នៃការថតរូបភាព និងសំឡេងត្រូវបានប្រគល់ឲ្យជនត្រូវចោទនេះដោយមូលហេតុបច្ចេកទេស យើងមិនអាចប្រគល់នូវឯកសារច្បាប់ដើមមួយច្បាប់នៃការថតរូបភាព និងសំឡេងទៅឲ្យសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនាពេលនេះទេ ។ ប៉ុន្តែ យើងប្រគល់ឲ្យពួកគេនូវច្បាប់ថតចម្លងមួយច្បាប់នៃកំណត់ហេតុនេះ ។

នៅវេលាម៉ោងដប់ប្រាំពីរនិងសាមសិបនាទីល្ងាច យើងបានឲ្យក្រឡាបញ្ជីអានខ្លាំងៗនូវកំណត់ហេតុនៃការតទល់មុខគ្នាទៅតាមអ្វី ដែលបានកត់ត្រា ។

អានឲ្យស្តាប់ហើយជនត្រូវចោទ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមិនមានជំទាស់អ្វីទេ ហើយ

សុខចិត្តចុះហត្ថលេខា ។”

[១៤:១៤:៣៩]

**ប្រធានអង្គជំនុំ៖**

ផ្អែកលើកំណត់ហេតុនៃស្តាប់សក្ខីកម្មសាក្សី មាស ប៉េងគ្រី D28/7 ដែលបានអានកាលពីសប្តាហ៍មុន ដោយក្រឡាបញ្ជី សែ កុលវុឌ្ឍី ហើយឥឡូវនេះ គឺអានបំពេញបន្ថែមនូវឯកសារចុះពិនិត្យកន្លែងកើតហេតុ D48/1 ពាក់ព័ន្ធនឹងសក្ខីរបស់សាក្សី មាស ប៉េងគ្រី ហើយនិង D52 ពាក់ព័ន្ធនឹងសក្ខីកម្មរបស់គាត់នៅក្នុងកំណត់តទល់មុខគ្នា ដែលធ្វើឡើងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ។ តើតំណាងសហព្រះរាជអាជ្ញាមានអ្វីកត់សម្គាល់លើកសក្ខីកម្មរបស់សាក្សីរូបនេះ លើខ្លឹមសារ ទាំងឯកសារទាំងបីដែលបានជម្រាបជូនលើនេះដែរឬទេ?

**លោក តាន់ សេណារ៉ុង៖**

តំណាងសហព្រះរាជអាជ្ញាគ្មានការកត់សម្គាល់ទៅលើឯកសារទាំងបី ដូចលោកប្រធានអង្គជំនុំជម្រះបានលើកឡើងនោះទេ ។

**ប្រធានអង្គជំនុំ៖**

ចុះខាងមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី តើមានអ្វីចង់កត់សម្គាល់លើឯកសារទាំងបីដែលពាក់ព័ន្ធនឹងសក្ខីកម្មរបស់ មាស ប៉េងគ្រី ដែរឬទេ?

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនមានអ្វីកត់សម្គាល់ទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ចុះខាងមេធាវីការពារក្តី តើមានអ្វីកត់សម្គាល់លើឯកសារពាក់ព័ន្ធនឹងសក្ខីកម្មរបស់ មាស ប៉េងគ្រី ដែរឬទេ?

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន យើងខ្ញុំខាងមេធាវីការពារក្តី មិនមានអ្វីកត់សម្គាល់ទេ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាតទៅទីនេះអង្គជំនុំជម្រះផ្តល់ឱកាសដល់ជនជាប់ចោទដើម្បីធ្វើការកត់សម្គាល់នូវលើខ្លឹមសារនៃសក្ខីកម្មរបស់សាក្សី មាស ប៉េងគ្រី ទាំងបីឯកសារ គឺឯកសារចម្លើយដែលស្តាប់ចម្លើយសាក្សីរូបនេះ ដោយអ្នកស៊ើបអង្កេតនៃការិយាល័យស៊ើបអង្កេត និងឯកសារពាក់ព័ន្ធពីរទៀត គឺឯកសារចុះពិនិត្យដល់កន្លែងកើតហេតុ ហើយនិងឯកសារតទល់មុខគ្នា ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ដំបូងខ្ញុំសូមបញ្ជាក់ថា មុន៧មករា ១៩៧៩ ខ្ញុំអត់ស្គាល់ មាស ប៉េងគ្រី ទេ ។ ពេលដែលជួបមុខនៅជើងឯក មាស ប៉េងគ្រី ចាប់ផ្តើមនិយាយជាមួយនឹងខ្ញុំថា បងឯងមិនស្គាល់ខ្ញុំទេ ខ្ញុំតូចតាច ។ ខ្ញុំសង្កេតមើលអាកប្បកិរិយា មាស ប៉េងគ្រី ក៏ដូចជាសង្កេតមើលអាកប្បកិរិយារបស់ តយ តេង ដែរ ។ខ្ញុំសង្កេតតាំងពីក្បាលដល់ចុងជើង ខ្ញុំឃើញគេឲ្យសក្ខីកម្មបីនាក់ហ្នឹង វាព្រមគ្នាល្អណាស់ ។ ហ៊ឹម ហ៊ុយ, មាស ប៉េងគ្រី ហើយនិង តយ តេង ។ ដូច្នេះ ខ្ញុំទទួលថាគេពិតជាបុគ្គលិករបស់មន្ទីរស-២១ ទាំងបីនាក់ ។ អត់មានប្រកែកទេ ។

សរុបមក នេះការទទួលស្គាល់របស់ខ្ញុំ ចំពោះ មាស ប៉េងគ្រី ។ ដោយឡែក សក្ខីកម្មរបស់ មាស ប៉េងគ្រី ខ្ញុំអត់ប្រកែកទេ សុំទទួលថាត្រឹមត្រូវជាមូលដ្ឋាន ។ សុំចប់ ។

[១៤:១៨:២៤]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត លោកស្រី សែ កុលវុឌ្ឍី អាននូវកំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុក ប៊ុនសេង ។ ឯកសារ D78/7 ។

**លោកស្រី សែ កុលវុឌ្ឍី៖**

"ឯកសារលេខ D78/7 នេះគឺជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ប៊ុនសេង ឈ្មោះហៅក្រៅ សេង ។ កើតនៅថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៥៥ ។ កំណត់ហេតុនេះ ត្រូវបានធ្វើនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៨ វេលាម៉ោងដប់និងប្រាំនាទីព្រឹក ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សួរ-ឆ្លើយ៖

សំណួរ៖ *ឌីស៊ីខេម* (DC-Cam) ធ្លាប់សម្ភាសន៍បងប្រុស កាលពីខែមីនា ឆ្នាំ២០០៣?

ចម្លើយ៖ បាទ ។

សំណួរ៖ យើងនិងអាននូវខ្លឹមសារទាំងស្រុង នៅក្នុងកិច្ចសម្ភាសន៍នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ ២០០៣ របស់ *ឌីស៊ីខេម* ។ សម្ភាសន៍ដោយលោក ផាន់ សុជា ហើយបានសង្ខេបនូវចំណុចសំខាន់ៗ មួយចំនួន និងបានសួរបញ្ជាក់ថា តើបងប្រុសទទួលស្គាល់ខ្លឹមសារទាំងអស់ដដែលឬទេ?

ក្នុងឆ្នាំ១៩៧៣ បងប្រុសត្រូវបានគេបង្ខំឲ្យចូលទៅធ្វើទាហាន ហើយចូលហ្វឹកហ្វឺនផ្នែកទាហាន និងនយោបាយនៅវត្តជ្រោយសង្កែ ហើយបងបានលើកឡើងថា បងខ្លាចនិងមិនហ៊ានធ្វើសង្គ្រាមទេ ។ ចុងឆ្នាំ១៩៧៤ គេបានកែនឲ្យចូលរួមក្នុងទាហានឡើងវិញ ហើយពេលនោះបងបានចូលរួមវគ្គបណ្តុះបណ្តាលផ្នែកនយោបាយ ដែលពិភាក្សាអំពីសត្រូវផ្ទៃក្នុង អ្នកក្បត់ សត្រូវខាងក្រៅដែលមានវៀតណាម និងថៃ ។

ក្រោយភ្នំពេញត្រូវបានកាន់កាប់ ហើយប្រជាជនត្រូវបានជម្លៀសទីក្រុងភ្នំពេញបានក្លាយទៅជាកន្លែងគ្មានមនុស្ស ហើយបងបានចូលមកទីក្រុងភ្នំពេញជាមួយនឹងក្រុមធំមួយមកពីតំបន់២៥ ។ បងបានស្នាក់នៅខាងជើងវិមានឯករាជ្យ ដែលជាតំបន់ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ ណាត ដែលជាប្រធានកងពលលេខ១២ ។ ការងារជាដំបូងរបស់បង គឺការប្រមូលសម្ភារដូចជា សម្លៀកបំពាក់ដើម្បីដាក់ចូលក្នុងឃ្លាំង ។ បងត្រូវបានគេបញ្ជូនទៅបឹងជើងឯក ហើយទៅដល់ក្បែរព្រៃស ។ ពីរខែក្រោយមក ដើម្បីបំពាក់បំប៉ននផ្នែកនយោបាយ ដោយសារបងមានប្រវត្តិរូបមិនល្អ ហើយមានសាច់ញាតិគ្រួសារមានតួនាទីក្នុងសង្គមមុន ។ បងទទួលការហាត់លុតដំឡើងវិញ នៅបឹងជើងឯក ដូចជាការជីកប្រឡាយ លើកទំនប់ ។ នៅទីនោះ មានបីក្រុម៖ ក្រុមទីមួយ ក្រុមស្រួល ។ ក្រុមពីរ ក្រុមលំបាកមធ្យម និងក្រុមទីបី ក្រុមលត់ដំធ្ងន់ធ្ងរ ។ ដែលមួយចំនួនត្រូវបានគេដាក់ច្រវាក់នៅពេលយប់ ។ បងស្ថិតនៅក្រុមទីបី ចំនួនពីរសប្តាហ៍ មុនពេលដែលត្រូវបានបញ្ជូនទៅស-២៤ ។

[១៤:២២:៥០]

ស-២៤ នេះចំណុះឲ្យ ស-២១ ហើយមានទីតាំងនៅវត្តដុល រាប់បញ្ចូលដែនដីចាប់ពីព្រៃសរហូតដល់ភូមិចេក ។ វត្តក្តុលត្រូវបានបំផ្លាញ់ទាំងស្រុងក្រោមការដឹកនាំរបស់ក្រុម ហ៊ុយ ដែលទទួលខុសត្រូវចំពោះមុខ ឌុច ។ នៅឯស-២៤ ការងារត្រូវបានបែងចែកជាបីកម្រិត៖ ក្រុមសម្អាតដី, ក្រុមភ្ជួរដី និងមើលសត្វពាហនៈ ។ អ្នកដែលមិនបានលត់ដំខ្លួនឲ្យល្អ ត្រូវបានបញ្ជូនទៅស-២១ ដែលនឹងមិនត្រឡប់មកវិញឡើយ ។ បងបានអះអាងថា ស-២៤ ជាកន្លែងរៀនសូត្រឡើងវិញ ។ ចំណែកឯ ស-២១

គឺជាកន្លែងកាប់សម្លាប់ ។ បងនៅស-២៤ រហូតដល់បែកឆ្នាំ១៩៧៩ ។ បងប្រុសបានថ្លែងថា អ្នកដែលត្រឡប់មកពីការដ្ឋានវាលយន្តហោះកំពង់ឆ្នាំង ត្រូវបានគេបញ្ជូនទៅស-២១ ហើយត្រូវបានសម្លាប់ទាំងអស់ ។ ក្នុងឆ្នាំ១៩៧៨ បងប្រុសបានទៅរៀនសូត្រនយោបាយម្តងនៅស-២១ ដែលបងបានជួប ឌុច ។ ឌុច បានផ្តល់នូវការបណ្តុះបណ្តាលរយៈពេលមួយសប្តាហ៍នូវសាលាក្រៅស-២១ ។ ក្នុងពេលសិក្សានោះ បងបានឃើញអ្នកទោសមួយចំនួនត្រូវបានចាប់និងយកចេញទៅ ។ បងប្រុសមិនដឹងថា តើពួកគេត្រូវបានយកទៅទីណាទេ? តែក្រោយមកគេបានប្រាប់បងថា អ្នកនោះត្រូវបានគេបញ្ជូនទៅស-២១ ហើយកម្ទេចចោល ។

សំណួរ៖ សូមបងប្រុសរៀបរាប់អំពីស្ថានភាព និងអ្វីដែលបងជួបប្រទះនៅពេលដែលបងរស់នៅបឹងជើងឯក?

ចម្លើយ៖ ក្រោយពេលស្នាក់នៅក្បែរវិមានឯករាជ្យអស់រយៈពេលពីរខែ គេដកខ្ញុំទៅលត់ដំនៅបឹងជើងឯក ដែលស្ថិតនៅខាងកើតកន្លែងពិឃាដជើងឯក ។ មុនគេដកខ្ញុំ មេក្រុមខ្ញុំនៅកងពលលេខ១២ មិនចាំឈ្មោះមេក្រុម ឲ្យខ្ញុំហើយនិងទាហានទាំងអស់ធ្វើប្រវត្តិរូប ។ មេក្រុមខ្ញុំរាយការណ៍បន្តទៅកងអនុសេនាតូច ហើយគាត់រាយការណ៍ទៅកងពល ហើយក្រោយមកប្រធានក្រុមអានក្រដាសបានហៅឈ្មោះម្នាក់មួយៗ ហើយឲ្យចេញទៅ ។ ខ្ញុំនៅបឹងជើងឯកប្រហែលរយៈពេលពីរខែ ។ បឹងជើងឯកស្ថិតនៅក្រោមស-២១ ។ ខ្ញុំមិនដឹងថាអ្នកណាជាអ្នកគ្រប់គ្រងផ្ទាល់នៅបឹងជើងឯកឡើយ ។ ពេលនោះ ខ្ញុំឮសួរថាកងវរសេនាធំរាយការណ៍ទៅ ឌុច ជាប្រចាំខែ ។ នៅបឹងជើងឯក ខ្ញុំនៅក្នុងកងវរសេនាតូច ដែលមានអ្នកលត់ដំសរុបប្រហែលមួយរយនាក់ ដែលសុទ្ធតែមកពីកងពលលេខ១២ ។ អ្នកលត់ដំត្រូវបានបែងចែកជាបីក្រុម ។ ក្នុងមួយក្រុមៗ មានគ្នាប្រហែលសាមសិបនាក់ ។ នៅទីនោះ ខ្ញុំបានឃើញគេចាប់មនុស្សជារឿយៗ ។ អ្នកដែលចាប់ គឺមកពីស-២១ គឺមកតាមឡានតែមិនដឹងឡានចតនៅទៅណាទេ ព្រោះមកពេលយប់ ។ ខ្ញុំបានដឹងបញ្ហានេះ នៅឆ្នាំ១៩៧៩ ដោយពួកអ្នកធ្វើការនៅស-២១ បានប្រាប់ខ្ញុំ ។ ពេលគេចាប់គេមកចាប់ គេហៅឈ្មោះឲ្យចុះពីលើផ្ទះ ហើយគេចងដៃនិងរុំមុខ ។ ពួកដែលគេចាប់យកទៅ មិនដែលត្រឡប់មកវិញទេ ។ ខ្ញុំដឹងតាមរយៈគេខ្សឹបប្រាប់ថា គេហៅយកទៅសម្លាប់ ។ ក្នុងមួយលើកៗគេចាប់ប្រហែលពីរទៅបួននាក់ សរុបទៅប្រហែលជាប្រាំបួនទៅដប់នាក់ ។

នៅកន្លែងនោះមានអ្នកដែលត្រូវគេបានដាក់ចូលក្នុងកងលត់ដំពិសេសដែលត្រូវបានគេដាក់ច្រវាក់ជើងនៅពេលយប់ ដោយសារអ្នកទាំងនោះដើរលួចម្ហូបចំណីនៅពេលយប់ ។ នៅបឹងជើងឯក អ្នកលត់ដំ

ដេកនៅក្នុងរោង ចំណែកមេក្រុមដេកនៅមុខច្រកចូលរោង ។ អ្នកលត់ដំអាចដើរជុំវិញបរិវេណផ្ទះ តែមិនអាចដើរចេញក្រៅបរិវេណដែលបានកំណត់ ពីព្រោះខ្លាចគេឃើញ ហើយរាយការណ៍ទៅថ្នាក់លើ ។

នៅបឹងជើងឯក ការហូបចុកមិនទៀងទាត់ បើលត់ដំខ្លាំង ហូបតែបបរបីវែក តែបើលត់ដំល្មម អាចមានបាយហូប ។ ការងារចាប់ផ្តើមពីម៉ោងបីយប់ រួមជាមួយនឹងការជួបប្រជុំរហូតដល់ម៉ោងដប់មួយថ្ងៃទើបសម្រាក ។ ការហូបបាយ គឺហូបឆ្លាស់គ្នា ។ ការងារនៅពេលល្ងាចចាប់ផ្តើមពីម៉ោងពីរ និងបញ្ចប់នៅម៉ោងប្រាំល្ងាច ។ ចំពោះការងារយប់ចាប់ផ្តើមពីម៉ោងប្រាំពីរដល់ម៉ោងដប់ពីរយប់ ។ មានការប្រជុំធំ ដែលនិយាយជាសំខាន់ពីការខិតខំធ្វើការ ដើម្បីឲ្យមានបាយហូប និងការប្រជុំតាមក្រុមតូចៗ ដើម្បីទិតៀននិងស្វ័យទិតៀន ។ ពេលនៅទីនោះ ពួកស-២១ មកថតរូប និងយកប្រវត្តិរូបអ្នកដែលកំពុងលត់ដំ ។ ខ្ញុំបានឃើញរូបថតខ្ញុំ នៅគុកស-២១ នៅឆ្នាំ១៩៨៥ ។

សំណួរ៖ ក្រោយពីនៅបឹងជើងឯក តើបងប្រុសត្រូវបានគេបញ្ជូនទៅទីណាទៀត?

ចម្លើយ៖ ក្រោយពីបឹងជើងឯក គេបញ្ជូនខ្ញុំទៅវត្តហា ដើម្បីជីកប្រឡាយ ។

[១៤:៣០:០៧]

សំណួរ៖ សូមបងប្រុសរៀបរាប់អំពីស្ថានភាពនិងការជួបប្រទះរបស់បងនៅវត្តហា?

ចម្លើយ៖ វត្តហា ស្ថិតនៅជាប់គុកព្រៃស ខ្ញុំអត់ដែលចូលក្នុងព្រៃសទេ តែខ្ញុំដឹងថា នៅទីនោះក៏ជាកន្លែងលត់ដំដែរ ។ វត្តហាដល់វត្តក្កុល ស្ថិតនៅក្រោមស-២៤ ហើយស-២៤ ជាសាខារបស់ស-២១ ហ៊ុយ ជាប្រធានស-២៤ ។ ការិយាល័យរបស់ ហ៊ុយ នៅចន្លោះវត្តហា និងវត្តក្កុល ហើយនៅចន្លោះកន្លែងស្នាក់នៅរបស់កងយុវជននិងយុវនារី ។ ខ្ញុំនឹងគូរប្លង់ជូន ប្លង់នេះ នឹងដាក់ជាប់ជាមួយកំណត់ហេតុ។ ខ្ញុំបានឃើញ ហ៊ុយ សឹងរាល់ថ្ងៃ ពីព្រោះគាត់មកត្រួតពិនិត្យតំបន់នេះជារៀងរាល់ថ្ងៃ ខ្ញុំអត់បានឃើញ ឌុច ទេ ដោយខ្ញុំរវល់លត់ដំ ។ នៅទីនោះ មានអ្នកធ្វើការច្រើនណាស់ប្រហែលរាប់ពាន់នាក់ មានអ្នកលត់ដំនិងទាហានមកពីក្រុមផ្សេងៗមកជីកប្រឡាយដែរ ។ គេអត់ដាក់ខ្នោះពួកអ្នកលត់ដំទេ ប៉ុន្តែ គេតាមដានឃ្លាំមើលសកម្មភាព ។ ការងារនៅទីនោះធ្ងន់ធ្ងរ ហើយហូបមិនគ្រាន់ ។ ខ្ញុំមិនបាន ឃើញគេចាប់មនុស្សនៅវត្តហា ទេ តែឮគេប្រាប់ថា មានមនុស្សបាត់ខ្លួន ។

នៅឆ្នាំ១៩៧៨ ខ្ញុំបានឃើញទាហានមកពីភូមិភាគបូព៌ាតាមរថយន្តចំនួនរាប់រយ មកច្រើនដងក្នុងមួយឡានៗមានទាហានប្រហែលមួយរយនាក់ ។ ពួកគេមកស្នាក់នៅក្នុងស-២៤មួយយប់ ពួកគេត្រូវបានបញ្ជូនទៅស-២១ ។ ខ្ញុំបានដឹងព័ត៌មាននេះតាមរយៈសន្តិសុខស-២១ បានប្រាប់ខ្ញុំ នៅពេលរត់ចេញ

ពេលវៀតណាមវាយចូលភ្នំពេញឆ្នាំ១៩៧៩ ។ ពេលពួកគេស្នាក់នៅស-២៤ ខ្ញុំបានជួបទាហានដើរទៅរកបេះត្នោត ហើយទាហាននោះបានសួរខ្ញុំថា តើគេបញ្ជូនពួកខ្ញុំទៅណាទៀត? ខ្ញុំឆ្លើយថា ខ្ញុំមិនបានដឹងទេ ទាហាននោះបានប្រាប់ខ្ញុំថាពួកគេមកពីភូមិភាគបូព៌ាមកធ្វើប្រវត្តិរូប ។

សំណួរ៖ តើហេតុអ្វីបានជាបងដឹងថា ឌុច ជាមេរបស់ ហ៊ុយ?

ចម្លើយ៖ ខ្ញុំដឹងថា ឌុច ជាមេរបស់ ហ៊ុយ ដោយសារគេប្រកាសនៅពេលរៀនសូត្រ និងប្រជុំនៅស-២១ ។ អ្នកដែលទៅរៀនសូត្រ គឺជាមេកងនិងជនគំរូ ។ ខ្ញុំឃើញ ឌុច និង សុន សេន មកបង្រៀននិងបង្ហាញអំពីសកម្មភាពខ្មាំងផ្ទៃក្នុងនិងបរទេស ។

សំណួរ៖ តើ ហ៊ុយ មានភិនភាគយ៉ាងម៉េច?

ចម្លើយ៖ ហ៊ុយ មានមាឌធំ ខ្ពស់ សម្បុរខ្មៅ សក់រួញ និងមានពុកមាត់ ។

សំណួរ៖ តើបងប្រុសស្គាល់ប្រពន្ធរបស់ ហ៊ុយ ទេ?

ចម្លើយ៖ ខ្ញុំអត់ស្គាល់ទេ ។

សំណួរ៖ តើបងប្រុសដឹងថា ហ៊ុយ នៅរស់ ឬក៏ស្លាប់?

ចម្លើយ៖ ខ្ញុំបានឮថា ហ៊ុយ ត្រូវបានគេចាប់បញ្ជូនទៅស-២១ និងត្រូវបានសម្លាប់នៅទីនោះ ។

សំណួរ៖ សូមបងរៀបរាប់អំពីអ្វីដែលបងបានឃើញ ពេលបងរៀនសូត្រនៅស-២១?

ចម្លើយ៖ ក្នុងអំឡុងពេលរៀនសូត្រនៅស-២១ ខ្ញុំបានឃើញគេចាប់អ្នកទោសអូសឆ្លងថ្នល់ទៅអគារ អ្នកទាំងនោះត្រូវបានគេរុំមុខនិងចងស្លាបសេក ។ ពេលនោះខ្ញុំដឹងថា ទួលស្លែងគឺជាគុកដោយសារអ្នកទៅចូលរួមជាមួយខ្សឹបប្រាប់ ។

សំណួរ៖ តើបងស្គាល់ ឌុច ពីពេលណាមក?

ចម្លើយ៖ ខ្ញុំបានស្គាល់ ឌុច នៅពេលចូលរួមរៀន ប្រជុំរៀនសូត្រនៅស-២១ ។ ខ្ញុំបានស្គាល់គាត់កាន់តែច្បាស់ នៅពេលដែលខ្ញុំស្នាក់នៅជាមួយគាត់នៅលើភ្នំក្រវាញ ខេត្តពោធិសាត់ ក្រោយបែក ឆ្នាំ១៩៧៩ ។

សំណួរ៖ សូមបងរៀបរាប់អំពីការរត់ភៀសខ្លួនចេញពីស-២៤ នៅពេលវៀតណាមវាយចូលភ្នំពេញ?

ចម្លើយ៖ ពេលវៀតណាមចូល មានពួកសន្តិសុខស-២១ មកប្រាប់ឲ្យត្រៀមរត់ពីព្រោះវៀតណាមជិតចូលមកដល់ហើយ ។ ខ្ញុំបានដើរជាមួយពួកគេអស់រយៈពេលបីថ្ងៃទើបដល់ កំពង់ត្រឡាច រួច ហើយ

ទៅអមលាំង និងបានជួបតាម៉ុក នៅក្នុងព្រៃ ។ ជាចុងបញ្ចប់ខ្ញុំបានទៅដល់ភ្នំក្រវាញ ជាទីកន្លែងដែលខ្ញុំបានជួប ឌុច ។

សំណួរ៖ សូមបងរៀបរាប់អំពីអ្វីដែលបានឃើញនៅលើភ្នំក្រវាញ?

ចម្លើយ៖ មានអ្នកទោសចំនួនប្រាំមួយនាក់ ស្រីបី ប្រុសបី និងក្មេងម្នាក់ ត្រូវបានកូនចៅរបស់ ឌុច ចាប់យកទៅសួរចម្លើយ ។ ក្រោយពីអ្នកទោសម្នាក់ធ្វើត្រាប់តាមសត្វយំ ដែលមានសូរស្រដៀងសំឡេងថា ប៉ុល ពត ។ ឌុច បានបញ្ជាឲ្យចាប់អ្នកនោះយកទៅសួរចម្លើយ ហើយថា បើឆ្លើយ ឬមិនឆ្លើយបង្ខើយទៅ ។ ខ្ញុំឃើញអ្នកទោសម្នាក់ត្រូវបានគេធ្វើទារុណកម្ម ដោយញាត់ចន្លុះភ្លើងក្នុងមាត់ និងអារ-ក ។ ឌុច បានស្នាក់នៅក្បែរកន្លែងធ្វើទារុណកម្មនោះ ហើយបានឮគេធ្វើទារុណកម្មដែរ ។ ចំពោះអ្នកទោសដទៃទៀតប្រហែលត្រូវបានគេសម្លាប់នៅលើភ្នំ ។

សំណួរ៖ តើ ឌុច មានរាងរៅ និងមានចរិតដូចម្តេច?

ចម្លើយ៖ ឌុច មានមាឌល្អិតតូច គាត់ជាមនុស្សរួសរាយ តែម៉ឺងម៉ាត់ ហើយបើ ឌុច បញ្ជាគេត្រូវតែគោរព និងធ្វើតាម ។ នេះខុសពី ហ៊ុយ ដែលជាមនុស្សកាច ខ្ញុំមិនហ៊ានមើលមុខ ហ៊ុយ ទេ ។

សំណួរ៖ ក្រៅពី ឌុច និង សុន សេន តើបងប្រុសមានស្គាល់មេដឹកនាំណាផ្សេងទៀតទេ?

ចម្លើយ៖ ក្រៅពី ឌុច និង សុន សេន ខ្ញុំមិនដែលស្គាល់ ឬឮឈ្មោះ អៀង សារី, ខៀវ សំផន ឡើយ ។ ខ្ញុំទើបតែឮឈ្មោះ ប៉ុល ពត នៅពេលដែលខ្ញុំត្រូវបានគេបញ្ជូនទៅស-២៤ ។

សំណួរ៖ តើបងប្រុសមានដឹងថា ក្រុមលត់ដំរបស់បង និងអ្នកទោសដទៃទៀត នៅរស់រានមានជីវិតដែរឬទេ?

ចម្លើយ៖ ចំពោះអ្នកលត់ដំជាយុវជន ខ្ញុំដឹងថា មានអ្នកលត់ដំនៅស-២៤ ដូចខ្ញុំ ឈ្មោះ ដុស នៅរស់ សព្វថ្ងៃគាត់នៅភូមិពោធិ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល ។ មានសន្តិសុខស-២១ ឈ្មោះ ប៊ូ នៅមានជីវិតរស់នៅ សព្វថ្ងៃរស់នៅក្បែរភ្នំដំរីរមៀល ព្រំដែនកំពង់ស្ពឺនិងកំពត ។

មានសមាជិកកងនារីខ្លះនៅរស់ តែខ្ញុំមិនបានចាំឈ្មោះ និងចាំមុខទេ ពីព្រោះរឿងនេះវាកើតឡើងជាយូរយាណាស់មកហើយ ។

ឯកសារថតចម្លងនៃកំណត់ហេតុមួយច្បាប់ត្រូវបានប្រគល់ឲ្យសាក្សីនេះ នៅវេលាម៉ោងដប់ប្រាំពីរ និងសូន្យនាទី ថ្ងៃទីពីរ ខែមេសា ឆ្នាំ២០០៨ ។

អានឲ្យស្តាប់ហើយ សាក្សី មិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា និងផ្តិតស្នាម

មេដៃ ។”

**ប្រធានអង្គជំនុំ៖**

បន្ទាប់ពីបានស្តាប់នូវចម្លើយរបស់សាក្សី អ៊ុក ប៊ុនសេង ដែលអានដោយក្រឡាបញ្ជីសវនាការ តើសហតំណាង សហព្រះរាជអាជ្ញា តើមានអ្វីកត់សម្គាល់ទៅលើខ្លឹមសារនៃចម្លើយរបស់សាក្សីរូបនេះដែរឬទេ?

**លោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន ។ ទាក់ទងទៅនឹងសក្ខីកម្មនេះ មានការច្បាស់លាស់ណាស់ យើងមិនមានការសង្កេតអ្វីទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ខាងមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី តើមានអ្វីកត់សម្គាល់នូវខ្លឹមសារនៃចម្លើយ នៃសក្ខីកម្មរបស់សាក្សី អ៊ុក ប៊ុនសេង ដែរឬទេ?

**លោក អាឡាំង វ៉ែនណឺ៖**

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនមានមតិយោបល់លើចម្លើយនេះទេ ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចុះខាងមេធាវីការពារក្តី តើមានអ្វីកត់សម្គាល់លើខ្លឹមសារនៃសក្ខីកម្មរបស់សាក្សី អ៊ុក ប៊ុនសេង ដែរឬទេ?

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន យើងខ្ញុំមេធាវីមិនមានអ្វីជំទាស់នឹងសក្ខីកម្មរបស់លោក អ៊ុក ប៊ុនសេង នេះទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះផ្តល់ឱកាសដល់ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់ទៅលើខ្លឹមសារនៃសក្ខីកម្មរបស់សាក្សី អ៊ុក ប៊ុនសេង ដែលអានដោយក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ឯកសារ D78/7 ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ខ្ញុំមិនដែលស្គាល់លោក អ៊ុក ប៊ុនសេង ទេ ហើយឯកសារដែលនិយាយពី លោក អ៊ុក ប៊ុនសេង ក៏ទើបតែនឹងឃើញថ្មីៗនេះដែរ ។ ខ្ញុំមិនទាន់ឃើញសក្ខីកម្មអីឲ្យល្អមសមរម្យនឹងទទួលថា លោក អ៊ុក ប៊ុនសេង ជាមនុស្សម្នាក់ដែលទៅស្ថិតនៅស្រែព្រៃសទេ ។ ទន្ទឹមនោះ សក្ខីកម្មរបស់គាត់ពីរឿងគាត់បានមករៀនសូត្រជួបលោកគ្រូ សុន សេន វាជាភស្តុតាងមួយដែលបញ្ជាក់ថាប្រហែលជាអាចមិនមែនគាត់ នៅទីនោះ ព្រោះលោកគ្រូ សុន សេន អញ្ជើញទៅធ្វើសន្និបាតនៅស-២១ នៅឆ្នាំ១៩៧៧ នៅថ្ងៃ១៤ មេសា ខ្ញុំអត់មានប្រមូលយកសមាសភាពដែលអប់រំនៅស-២១ យកមកស្តាប់គាត់ទេ គឺសុទ្ធតែកម្មាភិបាល ស-២១ យកទៅស្តាប់ ។

សក្ខីកម្មទីពីរ ដែលធ្វើឲ្យខ្ញុំកាន់តែសង្ស័យទៅទៀត គឺពួកបូព៌ា យោធាពួកបូព៌ាប្រមូលយកមកកម្ទេចនៅស-២១ មានពិតមែន តែអត់ឆ្លងព្រៃសទេ ។ ចូលត្រង់មកដល់ស-២១ ភ្នំពេញតែម្តង ។ សក្ខីកម្មមិត្ត ហ៊ុយ ប៉ុន្មានថ្ងៃមុននេះជាឧទាហរណ៍ស្រាប់ ។

ទីបី កាន់តែពិបាកស្តាប់ទៅទៀត គឺរឿង និយាយពីរឿងស្នូរចម្លើយ ពីរឿងធ្វើទារុណកម្ម ក្រោយឆ្នាំ១៩៧៩ នៅភ្នំក្រវាញ ជារឿងដែលមិនអាចកើតមានឡើយ ។ អត់មានអង្គភាពស-២១ ទៀតទេ ទាំងអស់គ្នានាំគ្នារត់ ។ ដូច្នេះ មេហើយនិងកូន នាំគ្នារត់ទាំងអស់គ្នា គិតតែធ្វើម៉េចកុំឲ្យតែដាច់ពោះងាប់ ប៉ុន្តែវានៅតែងាប់ដោយសារដាច់ពោះ ។

សរុបមកសក្ខីកម្មដែលធ្វើឲ្យខ្ញុំកាន់តែសង្ស័យលើបុគ្គលលោក អ៊ុក ប៊ុនសេង នេះគឺសក្ខីកម្មបីបែបនេះដែលខ្ញុំបានរៀបរាប់ជូនអង្គសវនាការ ។ សូមគោរពរាយការណ៍ជូនប៉ុណ្ណេះ ដោយគោរព ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាក អង្គជំនុំជម្រះប្រកាសសម្រាក ១៧នាទី រហូតចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការរបស់យើង ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១៤:៤៤នាទី ដល់ម៉ោង ១៥:០៦នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

អញ្ជើញ សហព្រះរាជអាជ្ញាអន្តរជាតិលើកដៃ សូមអញ្ជើញចង់មានយោបល់អ្វីទៅ?

**លោក វាំងសង់ វ៉ាយជ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមត្រឡប់ទៅអ្វីដែលខ្ញុំបានលើកឡើងមុនហ្នឹង ។ ខ្ញុំជឿថាហាក់ដូចជាមិនបានបកប្រែទាំងស្រុងនោះទេ ។ ខ្ញុំសូមដាក់សំណើអំពីសាក្សី តយ តេង ទាក់ទងទៅនឹងកថាខណ្ឌនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ ។ ទាក់ទងទៅនឹងកន្លែងដឹកជញ្ជូន គឺឯកសារ D48.1/1 នោះ ហើយនិងស្នើសុំឱ្យលើកឡើងអំពីឯកសារតទល់ D52 ផងដែរ ។ ខ្ញុំសូមឱ្យអាននូវឯកសារទាក់ទងទៅលោកសាក្សី តយ តេង នេះផងដែរនៅក្នុងឯកសារតទល់ផ្សេងៗ ដោយសារព្រឹកមិញនេះដូចយើងជាអត់បានអានទេ ។

**ប្រធានអង្គជំនុំ៖**

ហេតុផលយ៉ាងម៉េចទៅបានជាកាលពីព្រឹកមិញ លោកមិនបានធ្វើសំណើភ្លាមៗនៅពេលដែលអង្គជំនុំជម្រះប្រគល់វេទិកាទៅឱ្យលោកធ្វើការកត់សម្គាល់លើកំណត់ហេតុទាំងនេះ ហើយមកដល់ថ្មើរនេះបែរជាលោកទើបតែស្នើសុំទៅវិញ?

**លោក វាំង សង់វាយជ៍ ដេស្មាឯល៖**

នៅពេលបញ្ចប់ព្រឹកមិញនេះ ភាគីស្នើសុំឱ្យផ្តល់យោបល់លើឯកសារពីរដំបូងបន្ទាប់មកតុលាការបានសម្រាកហូបអាហារថ្ងៃត្រង់ ។ យើងបានគិតថាឯកសារពីរនោះគឺគេនឹងអាននៅពេលដើមរសៀល ហើយយើងនឹងអាចមានឱកាសក្នុងការដាក់សេចក្តីសង្កេតរបស់យើងទៅលើផ្នែកដែលពាក់ព័ន្ធ ចំពោះកំណត់ហេតុជាលាយលក្ខណ៍អក្សរនោះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

តាមធម្មតាលោកស្តាប់មេធាវីការពារក្តី ក្រោយពីយើងអាននូវកំណត់ហេតុ មាស ប៉េងគ្រី ក្រោយពីអានចប់សព្វគ្រប់ យើងបានធ្វើឱ្យគាត់ធ្វើការកត់សម្គាល់នៅលើឯកសារកំណត់ហេតុ គាត់បានលើកដៃ ហើយសុំឱ្យតុលាការចាត់ឱ្យក្រឡាបញ្ជីអាននូវឯកសារដែលពាក់ព័ន្ធ ។ នេះគឺយើងនៅចងចាំច្បាស់ ហើយយើងបានធ្វើការណែនាំអំពីរបៀបរបបនៅក្នុងការធ្វើដូច្នេះ ដើម្បីចៀសវាងថាសក្ខីកម្មសាក្សីមួយរូបនាំឱ្យធ្វើការពីរ ឬបី ឬបួនដង វានាំឱ្យអូសបន្លាយពេលវេលា ។ យើងសម្រេចតាមបំណង

លោក ប៉ុន្តែគប្បីមានការប្រយ័ត្នប្រយែងហើយរៀបចំឲ្យបានល្អនៅក្នុងដំណើរការនេះ ពីព្រោះជាឯកសារសក្ខីកម្មពាក់ព័ន្ធគ្នា ចៀសវាងរឿងមួយធ្វើដល់ទៅដប់លើក នោះវានឹងអាចធ្វើការ នាំឲ្យមានការយឺតយ៉ាវពេលវេលា ។

[១៥:១០:៤០]

ក្រឡាបញ្ជីអាននូវឯកសារD48/1 នៅចំណុច ឬកថាខណ្ឌដែលពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីឈ្មោះ តយ តេង ហើយបន្ទាប់មកគឺអាននូវឯកសារ D52 គឺផ្នែកពាក់ព័ន្ធនឹង តយ តេង ដោយសារពេលថ្ងៃមិញគាត់បានសុំដែរ ប៉ុន្តែមិនបានបញ្ជាក់ជាក់លាក់ដូចនេះទេ គឺពាក់ព័ន្ធជាមួយនឹង មាស ប៉េងគ្រី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

“ឯកសារលេខ D48/1 នេះគឺជាកំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨ វេលាម៉ោងប្រាំបីព្រឹក នៅទីកន្លែងមណ្ឌលប្រល័យពូជសាសន៍ជើងឯកដែលស្ថិតនៅចម្ងាយ១៥គីឡូម៉ែត្រ ខាងទិសនីរតីទីក្រុងភ្នំពេញ ក្នុងខេត្តកណ្តាល ដែលមានវត្តមានលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលចូលរួមដោយមេធាវីរបស់ខ្លួន លោក ការ សាវុត្ថ និងលោក ហ្វ្រង់ស្វ័រ រូ ។ សាក្សីមាស ប៉េងគ្រី, ហ៊ឹម ហ៊ុយ, ឈុន ផល និង តយ តេង ។

កថាខណ្ឌទីមួយ៖ នៅពេលកោះហៅវត្តមានជនត្រូវចោទប្រកាសថាស្គាល់តែ ហ៊ឹម ហ៊ុយ ម្នាក់ប៉ុណ្ណោះក្នុងចំណោមសាក្សីទាំងបួន ។ ចំណែកឯ ឈុន ផល វិញ និងតយ តេង ប្រកាសថា មិនដែលស្គាល់ជនត្រូវចោទឡើយ ។

កថាខណ្ឌទីពីរ៖ សាក្សី ឈុន ផល និង តយ តេង បញ្ជាក់ថានេះគឺជាលើកទីមួយហើយដែលខ្លួនមកកាន់ជើងឯកនេះ ។

កថាខណ្ឌ៣.៣៖ សាក្សី តយ តេង បញ្ជាក់ថាខ្លួនត្រូវបានគេចាត់តាំងឲ្យយាមអ្នកទោស ហើយខ្លួនមានវត្តមាននៅពេលទទួលអ្នកទោស ។

កថាខណ្ឌ៤.២៖ សាក្សី តយ តេង មានការច្របូកច្របល់បន្តិចដោយសារបរិយាកាសមានការផ្លាស់ប្តូរ ។ ប៉ុន្តែ គាត់បញ្ជាក់អំពីទីតាំងរបស់ផ្ទះឈើនេះ ។ គាត់គូសបញ្ជាក់ថា ម៉ាស៊ីនភ្លើងនៅជិតខ្ទមតូចដែលមានសព្វថ្ងៃនេះ តាមសម្តីរបស់គាត់អ្នកទោសមិនចំណាយពេលនៅក្នុងផ្ទះនេះយូរទេ មុនយកទៅ

សម្លាប់ ។ គាត់ពន្យល់ថា គាត់បានកាន់បញ្ជីមួយគូសអ្នកដែលមកដល់ និងអ្នកដែលត្រូវយកទៅសម្លាប់ ដើម្បីកុំឲ្យបាត់ម្នាក់ ។ គាត់ប៉ាន់ស្មានចំនួនអ្នកទោសដែលមានវត្តមានក្នុងពេលដំណាលគ្នា ប្រមាណជាម្ភៃ ឬសាមសិបរូប តែមិនច្បាស់ទេ ។

[១៥:១៤:១១២]

កថាខណ្ឌ ៥.៣៖ សាក្សី តយ តេង ប្រកាសថា មិនអាចកំណត់ទីតាំងច្បាស់លាស់ឡើយ ព្រោះដើមឈើបានលូតលាស់ធំណាស់ ។

កថាខណ្ឌ៥.៤៖ នៅជិតរណ្ដៅដែលគេរកឃើញឆ្អឹងរបស់ក្មេង សាក្សីប្រកាសថាទាំងអស់គ្នាមិនដែលឃើញមានក្មេងនៅជើងឯកទេ ។ តយ តេង ដែលបញ្ជាក់ថា ធ្លាប់ធ្វើការនៅជើងឯកប្រាំទៅប្រាំមួយ ខែគឺនៅឆ្នាំ១៩៧៨ រហូតដល់រំដោះ រំឭកថា ខ្លួនបានឃើញមានបុរស និងស្ត្រី ប៉ុន្តែមិនដែលឃើញមានកុមារឡើយ ។ គាត់បញ្ជាក់ថាស្ត្រី និងបុរសត្រូវបានសម្លាប់ ហើយកប់នៅកន្លែងជាមួយគ្នា ។

កថាខណ្ឌ៦.៣៖ សាក្សី តយ តេង លើកឡើងថា ខ្លួនមិនដែលដឹងអំពីហេតុការណ៍ដែលរៀបរាប់ដោយ ហ៊ីម ហ៊ុយ ទេ ព្រោះថាខ្លួននៅតែក្នុងផ្ទះ ។ គាត់បញ្ជាក់ថា មិនដែលឃើញ ឌុច ទេ ឃើញតែសមមិត្តហ៊ី អាចថា ឌុច មកជើងឯកដោយគាត់មិនបានឃើញ ប៉ុន្តែគាត់មិនឮគេនិយាយអំពីរឿងនេះទេ ។

កថាខណ្ឌ ៧.២៖ សាក្សី តយ តេង បញ្ជាក់អះអាងថា ខ្លួនត្រូវបានចាត់តាំងទៅជើងឯកដោយ ហ៊ីម ហ៊ុយ ដែលជាអ្នកដែលខ្លួនទទួលបញ្ជាពី និងថាភារកិច្ចរបស់ខ្លួនគឺទទួលអ្នកទោសនៅពេលមកដល់ជីករណ្ដៅ និងកប់វិញបន្ទាប់ពីការសម្លាប់ ។ បន្ទាប់ពីបានប្រកាសថា នៅពេលដែលអ្នកទោសត្រូវបានបញ្ជូនទៅរណ្ដៅគាត់ប្រចាំការនៅក្នុងផ្ទះ ហើយមិនដឹងមានរឿងអ្វីកើតមានឡើងនោះទេ ។ គាត់សារភាពថា សមាជិករបស់អង្គភាពគាត់ គឺទទួលបន្ទុកការសម្លាប់ និងទទួលស្គាល់ដោយខ្លួនឯងថាបានសម្លាប់ផ្ទាល់ដោយខ្លួនឯងផង ដែលនៅពេលខ្លះ ។ ប៉ុន្តែបញ្ជាក់ថា វាមិនមែនជាភារកិច្ចប្រចាំថ្ងៃឡើយ ។ បន្ទាប់ពីប្រតិបត្តិការសម្ដែងឡើងវិញខាងលើ អ្នកចូលរួមទាំងអស់ចាកចេញពីទីកន្លែងនាវេលាម៉ោងដប់ពីរនិងដប់ប្រាំនាទីដោយគ្មានឧប្បត្តិហេតុអ្វីឡើយ ។ ការសម្ដែងឡើងវិញត្រូវបានថតជាសំឡេង និងជារូបភាពដែលបានប្រគល់ឲ្យជនត្រូវចោទមួយច្បាប់ផងដែរ ។ ឯកសារដើមនៃកំណត់ហេតុនេះត្រូវបានតាក់តែងឡើងជាភាសាខ្មែរ និងបារាំង និងបកប្រែជាភាសាអង់គ្លេស ។

[១៥:១៧:៣០]

ឯកសារលេខ D52 នេះគឺជាកំណត់ហេតុនៃការតទល់មុខគ្នានៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៨ វេលាម៉ោងប្រាំបួន និងហាសិបនាទី ដែលមានវត្តមានមេធាវីការពារក្តីលោក ការ សាវុត្ថ និង ហ្វ្រង់ស្វ័រ រូ ។ ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច សាក្សី ហ៊ីម ហ៊ុយ, តយ តេង, ឈុន ផល, មាស ប៉េងគ្រី ដែលបានស្បថរួច ហើយស្របតាមវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។

ការតទល់មុខគ្នា៖

សំណួរ៖ កាលពីពីរថ្ងៃមុននេះ លោកទាំងអស់បានទៅជើងឯកជាមួយយើងដើម្បីធ្វើការរៀបចំឡើងវិញ ។ តើលោកនៅតែអះអាងអ្វីដែលលោកបាននិយាយនៅទីនោះដែរឬទេ?

សាក្សី តយ តេង៖ បាទ ខ្ញុំនៅតែបញ្ជាក់អះអាងដដែល ។

សំណួរ៖ ក្នុងចំណោមអ្នកដែលមានវត្តមាននៅទីនេះ តើលោកម្នាក់ៗស្គាល់អ្នកណាខ្លះ?

សាក្សី តយ តេង៖ ខ្ញុំស្គាល់តែ ហ៊ីម ហ៊ុយ និងមាស ប៉េងគ្រី ទេ ។ ចំពោះឌុច ខ្ញុំមិនច្បាស់ទេ ។

សំណួរ៖ តើនេះជាលើកទីមួយដែលលោកទាំងអស់ត្រឡប់ទៅជើងឯកវិញចាប់តាំងពីឆ្នាំ១៩៧៩មកឬ?

សាក្សី ឈុន ផល និងតយ តេង៖ បាទ ។

សំណួរ៖ តើលោកម្នាក់ៗមានតួនាទីអ្វីខ្លះនៅជើងឯក?

សាក្សី តយ តេង៖ គឺពិតប្រាកដហើយ បងហ៊ុយ ជាមេរបស់ខ្ញុំ ។

សំណួរ៖ លោក តយ តេង លោកបាននិយាយនៅជើងឯកថា ក្រុមរបស់លោកទទួលបន្ទុកជាអាទិ៍ជីករណ្តៅ និងសម្លាប់អ្នកទោស ។ ហើយលោកខ្លួនឯងក៏បានសម្លាប់ខ្លះដែរ ប៉ុន្តែ មិនញឹកញាប់ទេ តើលោកនៅតែអះអាងដដែលឬ?

សាក្សី តយ តេង៖ ខ្ញុំនៅតែអះអាងអ្វីដែលខ្ញុំបាននិយាយកាលពីពីរថ្ងៃមុនដដែល ។

[១៥:២០:០៤]

សំណួរ៖ នៅពេលដែលយើងបានធ្វើដំណើរទៅដល់ដើមឈើដែលគេចាត់ទុកថា ជាកន្លែងដែលគេប្រើសម្រាប់សម្លាប់កុមារ លោកម្នាក់ៗបានប្រកាសថា លោកមិនដែលបានចូលរួមក្នុងការសម្លាប់បែបនេះទេ ។ តើលោកនៅតែនិយាយអ៊ីចឹងដដែលឬ?

សាក្សី តយ តេង៖ ខ្ញុំក៏មិនដែលឃើញកុមារដែរ ។

ឯកសារច្បាប់ដើមនៃការថតរូបភាពនិងសំឡេងត្រូវបានបិទស្លាក បោះត្រានៅចំពោះមុខជនត្រូវចោទនេះ និងមេធាវីរបស់ជននេះ និងត្រូវបានចុះហត្ថលេខាដោយយើងក្រឡាបញ្ជី សហព្រះរាជអាជ្ញា ជនត្រូវចោទ និងមេធាវីរបស់ជននេះ ។

ឯកសារច្បាប់ដើមមួយច្បាប់នៃការថតរូបភាពនិងសំឡេង ត្រូវបានប្រគល់ឲ្យជនត្រូវចោទនេះ ដោយសារមូលហេតុបច្ចេកទេស យើងមិនអាចប្រគល់នូវឯកសារច្បាប់ដើមមួយច្បាប់នៃការថតរូបភាព និងសំឡេង ទៅឲ្យសាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណីនាពេលនេះទេ ។ ប៉ុន្តែ យើងប្រគល់ឲ្យពួកគេនូវច្បាប់ថតចម្លងមួយច្បាប់ នៃកំណត់ហេតុនេះ ។

នៅវេលាម៉ោងដប់ប្រាំពីរនិងសាមសិបនាទីល្ងាច យើងបានឲ្យក្រឡាបញ្ជីអានខ្លាំងៗនូវកំណត់ហេតុនៃការតទល់មុខគ្នាទៅតាមអ្វីដែលបានកត់ត្រា ។

អានឲ្យស្តាប់ហើយ ជនត្រូវចោទ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី មិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ។"

**ប្រធានអង្គជំនុំ៖**

ក្រោយពីស្តាប់ក្រឡាបញ្ជីអានរួចហើយ តើសហព្រះរាជអាជ្ញាមានអ្វីកត់សម្គាល់ដែរឬទេ លើខ្លឹមសារនៃចម្លើយផ្តល់សក្ខីកម្មរបស់សាក្សី តយ តេង ដែលទើបតែអានអម្បាញ់មិញនេះ?

**លោកវាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមថ្លែងអំណរគុនដល់លោកប្រធាន អស់លោក លោកស្រីចៅក្រមដែលបានបង្គាប់ឲ្យអានផ្នែកទាំងអស់នេះ នៅក្នុងកំណត់ហេតុដែលកត់ត្រានេះ យើងខ្ញុំពុំមានការធ្វើសង្កេតអីផ្សេងទៀតទេ ។ សូមអរគុណ ។

[១៥:២២:00]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានអ្វីកត់សម្គាល់ទេ?

**លោកស្រី ស៊ីលឃី ស្ទូតហ្វ៊ីនស្គី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមស្នើឡើងទាក់ទងទៅនឹងឯកសារចុងក្រោយដែលទើបតែអានអម្បាញ់មិញនេះ ទាក់ទងទៅនឹងទំព័រទីបួននៃឯកសារចុងក្រោយនេះ ដែលមានការអានចម្លើយរបស់ តយ តេង នោះនៅពេលដែលយើងស្តាប់ទៅលើចម្លើយនោះ គឺចម្លើយរបស់ ហ៊ីម ហ៊ុយ គួរតែអានផង

ដែរ ដោយសារតែចម្លើយរបស់ តយ តេង នោះ គឺវាពាក់ព័ន្ធដោយផ្ទាល់ទៅនឹងចម្លើយ ហ៊ឹម ហ៊ុយ គឺវានៅក្នុងទំព័រទីបួន ដូច្នេះហើយ យើងគួរតែយល់ថាតើ តយ តេង គាត់មានន័យយ៉ាងម៉េចទាក់ទងទៅនឹង ហ៊ឹម ហ៊ុយ នោះ ។ ដូច្នេះ គឺខ្ញុំស្នើសុំលោកប្រធានឲ្យក្រឡាបញ្ជីអានចម្លើយរបស់ ហ៊ឹម ហ៊ុយ ផងដែល ផ្ដើមពីតួនាទីជាក់លាក់ ។ល។ និង ។ល។ ដែលវានៅក្នុងទំព័រទីបួន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ចំណុចជាក់លាក់ណាមួយសូមផ្ដល់ឲ្យបានត្រឹមត្រូវ ទំព័រទីបួន ហើយបន្ទាត់ទីប៉ុន្មានទៅ? ហើយជាភាសាខ្មែរ ឬក៏ភាសាអង់គ្លេស ឬក៏ភាសាបារាំង ដែលលោកស្រីឲ្យកត់សម្គាល់ច្បាស់លាស់ថាត្រូវអាននោះ? ហើយប៉ុន្មានបន្ទាត់និយាយឲ្យបានច្បាស់លាស់? ចៀសវាងការសម្រេចទៅមានការភាន់ច្រឡំដូចអ្វីដែលបានសម្រេចពីព្រឹកមិញដោយសារមូលហេតុការនិយាយមិនច្បាស់លាស់ នាំឲ្យអ្នកសម្រេចក៏សម្រេចមិនត្រឹមត្រូវដែរ ។

**លោកស្រី ស៊ីលឃី ស្ទូតហ្វ៊ីនស្ដី៖**

ឯកសារអង់គ្លេសគឺក្នុងទំព័រទីបួន ។ រាប់ពីក្រោមមក នៅក្នុងទំព័របួនភាសាអង់គ្លេសហ្នឹងគឺកថាខណ្ឌទី៦ រាប់ពីក្រោម ហើយនោះជាចម្លើយ ហ៊ឹម ហ៊ុយ ដែលលើកឡើងថា តួនាទីរបស់ខ្ញុំគឺជាប្រធានអង្គភាព ហើយនៅពេលដែលថា មើលឯកសារខ្មែរនោះ យើងត្រូវរក-- ចំណាយពេលមួយចំនួនដើម្បីស្វែងរកចំណុចជាក់លាក់ ប្រហែលជាលោកក្រឡាបញ្ជីអាចធ្វើការរកផ្នែកនោះបាន ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជី រកឃើញទេ? បើឃើញអានតាមសំណើរនេះទៅ ដើម្បីឲ្យវាអស់សង្ស័យ ។

[១៥:២៥:៣៥]

**លោកស្រី សែ កុលវុឌ្ឍី៖**

“សំណួរលោកសហចៅក្រមស៊ើបអង្កេត៖ តើលោកម្នាក់ៗមានតួនាទីអ្វីខ្លះនៅជើងឯក?

សាក្សី ហ៊ឹម ហ៊ុយ៖ ទាក់ទងនឹងតួនាទីពិសេសរបស់ខ្ញុំ ខ្ញុំជាប្រធានរបស់អង្គភាពដែលទទួលបន្ទុកដឹកជញ្ជូនអ្នកទោសពីស-២១ ទៅជើងឯក ។ ហ៊ី បានចាត់តាំងក្រុមរបស់ខ្ញុំដើម្បីធ្វើកិច្ចការនេះ ។ ហ៊ី បានបញ្ជាខ្ញុំឲ្យចាត់តាំងមនុស្សមួយនាក់ចាំទទួលនិងយាមអ្នកទោសនៅជើងឯក ។ ក្រុមរបស់ តយ តេង ជាអ្នកទទួលខុសត្រូវលើការងារនេះ ។ ក្រុមនេះមានគ្នាប្រាំបីនាក់ ហើយត្រូវជីករណ្ដៅ និងសម្លាប់អ្នកទោស ។

សាក្សី តយ តេង៖ គឺពិតប្រាកដហើយ បងហ៊ុយ ជាមេរបស់ខ្ញុំ ។”

**ប្រធានអង្គជំនុំ៖**

មានអ្វីចង់កត់សម្គាល់ដែរទេក្រៅពីសុំឲ្យអានបន្ថែម មេធាវីអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី?

**លោកស្រី ស៊ីលឃី ស្ទូតហ្សិនស្គី៖**

យើងខ្ញុំពុំមានសេចក្តីសង្កេតអីផ្សេងទេពីខាងភាគីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តី ឯកសារដែលអានបន្ថែមផ្នែកដែលពាក់ព័ន្ធជាមួយនឹងសក្ខីកម្មរបស់ តយ តេង ហើយនិងបន្ថែមនូវមួយកថាខណ្ឌដែលជាចម្លើយពាក់ព័ន្ធជាមួយនឹងសាក្សី ហ៊ឹម ហ៊ុយ ដែលជាការអានបន្ថែមអម្បាញ់មិញនេះ តើមេធាវីការពារក្តីមានអ្វីត្រូវកត់សម្គាល់ដែរឬទេ? បើមានសូមអញ្ជើញ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ខ្ញុំបាទកត់សម្គាល់ពីព្រឹកមិញម្តងទៅហើយ ដោយថាខ្ញុំបានឯកភាពទៅជាមួយនឹងលោក ហុង គឹមសួន ដែលថាសាក្សីរូបនេះបានធ្វើសក្ខីកម្មយ៉ាងត្រឹមត្រូវហើយ ហើយជាពិសេស សាក្សីរូបនេះបានបញ្ជាក់ថាមិនដែលឃើញជនជាប់ចោទទៅជើងឯកទេ ។ ហើយអម្បាញ់មិញនេះទៀត រឹតតែច្បាស់ថែមទៀតថា អ្នកដទៃទៀតក៏មិនដែលឮអ្នកណាមួយនិយាយថា ជនជាប់ចោទបានទៅជើងឯកនោះទេដែរ ។ ខ្ញុំការកត់សម្គាល់មានតែប៉ុណ្ណេះ ។ សូមអរគុណលោកប្រធាន ។

[១៥:២៨:០២]

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទមានអ្វីកត់សម្គាល់បន្ថែមលើសក្ខីកម្មសាក្សី តយ តេង ដែលបានអានបន្ថែមនូវកំណត់ហេតុតទល់ និងកំណត់ហេតុចុះដល់ ពិនិត្យដល់កន្លែងកើតហេតុនេះដែរឬទេ?

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ខ្ញុំអត់មានអីបញ្ជាក់ថែមទេ ។ សូមគោរព ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត លោក ឌុច ផារី អាននូវកំណត់ហេតុស្តាប់ចម្លើយសាក្សី ហ៊ីន អៀម ដែលមានឯកសារ D28/5 ។

**លោក ឌុច ផារី៖**

"ឯកសារលេខ D28/5 នេះគឺជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ិន អៀម ឈ្មោះហៅក្រៅ ម៉ឹង កើតនៅឆ្នាំ១៩៥៣ ។ កំណត់ហេតុនេះបានធ្វើនៅថ្ងៃទីម្ភៃប្រាំបួន ខែវិច្ឆិកា ឆ្នាំពីរពាន់ប្រាំពីរ វេលាម៉ោងប្រាំបីនិងដប់នាទីព្រឹក ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណួរ៖ សូមលោករៀបរាប់អំពីប្រវត្តិមុនឆ្នាំ៧៥ ។

ចម្លើយ៖ ខ្ញុំសូមនិយាយប្រវត្តិបែកពីម្តាយ ។ ពីឆ្នាំ៧៥ ខ្ញុំចេញមកធ្វើទ័ពនៅកងពល៧០៣ ប្រធានឈ្មោះតាណាត វរសនាធំ១១២ ដល់ឆ្នាំ៧៥ បានរំដោះចូលភ្នំពេញ ។ ខ្ញុំបានរស់ក្នុងវរសេនាធំ ១១២ រួចគេរៀបចំអង្គភាពថ្មី១៤២ ប្រធានឈ្មោះ ការីម ហៅ រិទ្ធ ។ ពេលនោះគេឲ្យធ្វើស្រែ ភ្លួរនៅអូរបែកក្អម ។ គេថាខ្ញុំធ្វើការមិនល្អ ឲ្យខ្ញុំទៅធ្វើខាងដាំបាយឲ្យគេវិញ ។ បានរយៈពេលបីខែក្រោយមកទៀត គេឲ្យខ្ញុំមកធ្វើប្រវត្តិរូបនៅវរសេនាធំ ១៧ ក្នុងកងពល៧០៣ នៅទល់មុខពេទ្យមុនីវង្ស ។ ខ្ញុំធ្វើប្រវត្តិរូបអស់រយៈពេលបីថ្ងៃ ខ្ញុំមិនចាំច្បាស់អ្នកធ្វើប្រវត្តិរូបឲ្យខ្ញុំ រួចហើយឲ្យខ្ញុំឈរយាមនៅសាលាព្រះស៊ីសុវត្ថិយាមអ្នកធំ ដែលគាត់រៀននៅទីនោះ ។ តែខ្ញុំមិនដឹងគេរៀនអំពីអ្វី ។ អស់រយៈពេលបីខែ ដកខ្ញុំចេញវិញ ឲ្យខ្ញុំទៅយាមនៅគុកងងឹត នៅខាងក្រៅ គឺគុកដាំផេង នៅជិតផ្សារថ្មីជាប់របងពេទ្យមុនីវង្ស មានបន្ទប់តូចៗ មានបន្ទប់ធំៗ មានដែកចំរឹងជុំវិញ ។ កាលពីសង្គ្រាមប្រាំឆ្នាំ គេសរសេរនៅលើជញ្ជាំងជាឈាមក្រហមឆ្អៅថា ដាំផេង ជាអ្នកតស៊ូដែលជាប់គុក ។ គេឆ្លាក់បេះដូងក្រហមឆ្អៅ ហើយដាក់ឈ្មោះដាំផេង ។ ការឆ្លាក់នៅលើជញ្ជាំងខាងក្នុង ខ្ញុំមិនបានឃើញ តែអ្នកខាងក្នុងប្រាប់ខ្ញុំ ។

[១៥:៣២:៣០]

ប្រធាននៅទីនោះឈ្មោះ ឌុច ដដែល ខ្ញុំឮសួរគេនិយាយ ។ ខ្ញុំយាមនៅទីនោះប្រហែលបីខែក្រោយ១៧ មេសា ៧៥ ខ្ញុំយាមដល់ឆ្នាំ១៩៧៦ ទើបផ្លាស់កន្លែង-- គេឲ្យផ្លាស់កន្លែង ហើយគេយកអ្នកទោសទៅមុនបាត់ ។ ពេលគេនាំយកចេញ គេនាំដាក់ឡានដោយចងមុខ និងដាក់ខ្នោះដៃ ។ ពេលយកអស់ហើយ ស្អែកឡើងបានគេឲ្យខ្ញុំផ្លាស់ទាំងអស់គ្នា ។

ពេលមកដល់ទួលស្លែងក៏អត់ឃើញអ្នកទោសទេ ក៏នាំគ្នាថា "ចុះអ្នកទោសដែលនាំយកមកនោះនៅឯណា?" ដល់ពេលនោះមេក្រុមគាត់ថា "អ្នកយាមដឹងតែយាមទៅ!" ។ រយៈពេលបីថ្ងៃ គេនាំអ្នកទោសមកថ្មីទៀត នាំចូលមកដាក់ខ្នោះដៃ ចងមុខ គឺចម្រុះ មានទាហាន ប្រជាជនសហករណ៍ មាន

វៀតណាមនៅឆ្នាំ៧៦ ។ អ្នកដែលមកខ្លះនិយាយវៀតណាម មិននិយាយខ្មែរទេ ។ ខ្ញុំនៅយាមពេលខ្លះនៅខាងក្នុង ពេលខ្លះនៅខាងក្រៅរបង ប្រហែលមួយខែផ្លាស់ម្តង ។ ក្នុងមួយកងដប់ពីរនាក់ ក្នុងមួយក្រុមមានបួននាក់ ។ មេក្រុមឈ្មោះ ចំរើន ក្រោយមកត្រូវគេចាប់ ។ ក្រោយមកមេក្រុមឈ្មោះ សុខ ក៏ត្រូវចាប់ដែរ ។ គេចាប់ ចំរើន ខ្ញុំមិនដឹងមូលហេតុទេ តែចម្រើនឆ្លើយថា ពេលគាត់ធ្វើការ គាត់ចេះតែនិយាយប្រាប់កូនក្រុមរបស់គាត់ ដូចជា "យើងអ្នកយាមត្រូវធ្វើយ៉ាងម៉េចកុំឲ្យអ្នកទោសសម្លាប់ខ្លួនឯងបាន" ។ សុខ គឺជាអនុក្រុម ក្រោយមកគេដំឡើង សុខ ជាប្រធាន ។ ក្រោយមក គេក៏ចាប់គាត់ប្រហែលម៉ោងប្រាំពីរយប់ ខ្ញុំមិនដឹងមូលហេតុទេ ។

ពេលយាមនៅខាងក្នុង ពេលដែលអ្នកទោសទៅថ្មី គេសួរខ្ញុំថា តើមានបន្ទប់ណាទំនេរទេ? ប្រសិនបើមាន ខ្ញុំជាអ្នកនាំអ្នកទោសទៅដាក់ក្នុងបន្ទប់ រួចដោះកំណាត់ចងមុខ និងដាក់ខ្នោះជើង ហើយបានខ្នោះដៃ ។ អ្នកខ្លះគេដាក់ខ្នោះជើងពីរ គឺគេមើលទៅតាមមាឌ មាឌធំ ដាក់ជើងទាំងពីរហើយប្រាប់អ្នកទោសថា ប្រសិនបើពួឈើ បត់ជើង ឬស្រែកទឹកប្រាប់ខ្ញុំ។ បន្ទប់តូចៗ មាននៅជាន់ទីមួយ ឬផ្ទាល់ដី។ ជាប្រចាំថ្ងៃគឺមានគេមកដូរវេនយាម ទៅញ៉ាំបាយ ដល់វេនខ្ញុំយាម ខ្ញុំមកយាមវិញ គឺវេនព្រឹក មួយវេនថ្ងៃ ។ ពេលយប់មានពីរវេនដូចគ្នា គឺមួយថ្ងៃមួយយប់ ខ្ញុំត្រូវយាមពីរវេន ។

[១៥:៣៥:៥៥]

សំណួរ៖ ចុះការឲ្យបាយទឹកអ្នកទោស គេធ្វើរបៀបណា?

ចម្លើយ៖ អ្នកដែលទោសស្រាលគឺគេឲ្យទៅដាំបាយ ចិញ្ចឹមជ្រូក ឬធ្វើជាងឡានទៅតាមជំនាញ។

សំណួរ៖ ចុះអ្នកទោសនៅខាងក្នុង?

ចម្លើយ៖ គេយកបាយទៅឲ្យក្នុងមួយថ្ងៃពីរដង ម្តងបាយមួយចាន សម្លមួយចាន ។ ខ្ញុំមិនដឹងថាគ្រប់ ឬមិនគ្រប់ទេ គេកំណត់ឲ្យ ។

សំណួរ៖ ចុះសុខភាពវិញ?

ចម្លើយ៖ អ្នកខ្លះគេសួរចម្លើយរួចទៅ មកវិញបែកខ្នង ទ្រុឌទ្រោម អ្នកខ្លះមកវិញស្លាប់ក្នុងបន្ទប់ក៏មាន ខ្លះស្គមចេញឆ្អឹង មានទាំងស្រីប្រុស តែចំពោះក្មេងខ្ញុំមិនដែលឃើញទេនៅកន្លែងខ្ញុំ ។

សំណួរ៖ មានសង្កេតឃើញឆ្នាំណាដែលមានអ្នកទោសមកច្រើនជាងគេ?

ចម្លើយ៖ គឺក្នុងឆ្នាំ៧៧ ទៅឆ្នាំ៧៨ ។ តាមខ្ញុំយាម ខ្ញុំមិនដែលបានសួរអ្វីទេ ។ ពេលនាំអ្នកទោសទៅអ្នកខាងក្រៅ គេឲ្យសោបន្ទប់មក ខ្ញុំចាក់សោយកអ្នកទោសឲ្យគេទៅ ។ ខ្ញុំមិនដឹងថា គេនាំទៅសួរ

ឬយកទៅណាទេ ។

សំណួរ៖ លោកចាំថា ត្រូវយកអ្នកទោសមួយណា បើលោកមិនចេះអក្សរផង?

ចម្លើយ៖ គេប្រាប់ថា យកអ្នកទោស ឧទាហរណ៍បន្ទប់តូចៗមួយធំ ។ បន្ទប់តូចមានតែម្នាក់ទេ ក្នុងមួយបន្ទប់ធំមានច្រើនបន្ទប់តូច តែយកមកតាមលេខមិនអាចយកច្រឡំទេ ។

សំណួរ៖ អ្នកសួរចម្លើយណាដែលលោកធ្វើការជាមួយញឹកញាប់ជាងគេ?

ចម្លើយ៖ ខ្ញុំអ្នកយាមខាងក្នុង ខ្ញុំមិនដឹងទេ ពេលគេមកយកអ្នកទោស គេមកទាក់ទងជាមួយអ្នកយាមទ្វារនៅខាងក្រៅ ហើយអ្នកយាមទ្វារខាងក្រៅជាអ្នកយកសោមកឲ្យ ។ អ្នកយាមខាងក្រៅឈ្មោះ យ៉ាង ។ យ៉ាង ក៏ត្រូវគេចាប់ដែរ គេថាពាក់ព័ន្ធជាមួយ សុខ និង ចំរើន ។

[១៥:៣៨:៤៣]

សំណួរ៖ អ្នកទោសដែលនាំចេញទៅ ដែលមិនឃើញត្រឡប់មកវិញនោះមានច្រើនទេ?

ចម្លើយ៖ អ្នកយកចេញទៅដែលមិនឃើញត្រឡប់មកវិញទេនោះ មានចំនួនច្រើន ហើយភាគច្រើនជាអ្នកដែលទ្រុឌទ្រោម ។ ហើយក៏មានតែអ្នកទោសថ្មីចូលច្រើន ។

សំណួរ៖ មានអ្នកទោសស្លាប់ ទាំងជាប់ខ្នោះទេ?

ចម្លើយ៖ ខ្ញុំធ្លាប់ឃើញមានស្លាប់ជាប្រចាំថ្ងៃ ដោយសារភាពទ្រុឌទ្រោមក្រោយពេលសួរចម្លើយ ជួនកាលក្នុងមួយថ្ងៃមានស្លាប់ពីរនាក់ ។ ក្រោយពីគេចាប់ យ៉ាង ទៅប្រហែលជាមួយខែគេផ្លាស់ខ្ញុំឲ្យទៅយាមខាងក្រៅរបង ។ យាមបានរយៈពេលមួយអាទិត្យ ខ្ញុំយាមងក់ងុយដេក ថ្វាសខ្ញុំងក់ចូលជាមួយរបងលួស មេខ្ញុំទាន់ ក៏រុញក្បាលខ្ញុំថែម ។ មេខ្ញុំឈ្មោះ ប៉េង ហើយថា ទំនងពួកឯងខ្សែតែមួយ ។ ខ្ញុំក៏ថា បងអើយ ខ្ញុំងងុយខ្លាំងណាស់ ។ រួចហើយគាត់ឲ្យខ្ញុំចុះមកងូតទឹក ហើយគាត់យាមជំនួសវិញ ។ ខ្ញុំងូតរួចខ្ញុំទៅយាមជំនួសវិញ គាត់ថា យាមឲ្យប្រយ័ត្ន ប្រសិនបើយាមងក់ទៀតនោះ គ្រោះថ្នាក់ធំហើយ ។ អ្នកយាមខាងក្នុងឮ ក៏សួរយ៉ាងម៉េចតា ខ្ញុំក៏ថា បងប៉េង ទាន់ពេលខ្ញុំយាមងក់។ ពួកអ្នកយាមខាងក្នុងក៏ថា តាឯងប្រយ័ត្ន បើពេលនោះ ។ ហើយពេលនោះ ខ្ញុំក៏ឈប់និយាយជាមួយ ព្រោះខ្លាចមេក្រុមឮ ។

ក្រោយពីនោះមួយអាទិត្យ គេក៏ចាប់ខ្ញុំ ដាក់ខ្នោះដៃចងមុខខ្ញុំ ដាក់ច្រវាក់ខ្ញុំនៅក្នុងបន្ទប់តែឯង នៅអគារកណ្ដាលឲ្យកូនក្មេងតូចនៅយាមខ្ញុំ ។ អ្នកចាប់ខ្ញុំ គឺកងចាប់ អ្នកចាប់ខ្ញុំគឺ ហ៊ុយ តូច មានគេបញ្ជាពីលើមក គេដាក់ច្រវាក់ ហើយគេមិនឲ្យនិយាយ ។ ខ្ញុំមិនដឹងពីមូលហេតុអ្វីទេ គេបង្អត់បាយ និងទឹកអស់រយៈពេលមួយអាទិត្យក្មេងយាមខ្ញុំឈ្មោះ ហេង ហៅ ឆក ស្រុកកំណើតនៅកំពង់ឆ្នាំង ស្រុករលាប្អៀរ

ហើយវាលួច មើលមេ វាសួរតាស្រេកទឹកទេ? ខ្ញុំក៏ថា ក្មួយឯងរក្សាសុខខ្លួនឯងចុះ រឿងតាស្រេចតែតា វាក៏ហុច ទឹកមួយផ្តិល ហើយយកជើងឈូសក្រណាត់មកឲ្យខ្ញុំ ។ វាឲ្យខ្ញុំផឹកទឹកស្រក់លើក្រណាត់ ដើម្បីកុំឲ្យមានស្លាកស្នាម ។ ហើយវាក៏ប្រាប់ តាកុំប្រាប់ថា ខ្ញុំឲ្យតាផឹកទឹក បើគេសួរ ។ តាថាស្រេកទឹកទៅ បើគេដឹងថា ខ្ញុំឲ្យទឹកតា តាក៏ស្លាប់ខ្ញុំក៏ស្លាប់ ។ បានពីរថ្ងៃក្រោយមក ហេង លួចយកបាយមកឲ្យខ្ញុំហូប ពេលយាមចប់ ។ ច្រកស្បោងឲ្យខ្ញុំហូប ឲ្យដេកហូប ខ្ញុំក៏អរគុណក្មួយអ្នកយាម ។ ស្អែកឡើងគេយកខ្ញុំទៅសួរថាតើដឹងរឿងអត់ខ្លួនឯងសព្វថ្ងៃ? ខ្ញុំក៏ឆ្លើយថា ខ្ញុំអត់ដឹងរឿងអីទេ ។ ខ្ញុំដឹងថា ប៉ុន្មានថ្ងៃមុនខ្ញុំបានយាមងក់មែន តែដោយអចេតនាទេ ព្រោះខ្ញុំងងុយ ហើយអ្នកសួរខ្ញុំនោះឈ្មោះ ទុយ ។ តែ ទុយ នោះក៏ត្រូវគេចាប់ដាក់ក្នុងគុកផងដែរ ។ តើដឹងខ្លួនក្រៅពីងក់នេះទេ? ខ្ញុំក៏ឆ្លើយថា ខ្ញុំថា ខ្ញុំដឹងតែយាម ពេលវេនយាមខ្ញុំមកយាម ពេលហូបបាយ ខ្ញុំហូបបាយ ។ ហើយគេព្រមានខ្ញុំថា កុំឲ្យធ្វើអីចឹងទៀត ហើយគេក៏ដោះលែងខ្ញុំ ។

[១៥:៤៣:២១]

សំណួរ៖ ចុះក្រោយមកទៀត ដែលមានបញ្ហាអ្វីទេ?

ចម្លើយ៖ ក្រោយមកទៀត គេក៏ឲ្យខ្ញុំយាមខាងក្រៅរបងស័ង្កសីរហូត ។ ខ្ញុំឃើញគេបណ្តើរអ្នកទោសពេលយប់ ដែដាក់ខ្នោះចងមុខ ឃើញរាល់ខែ មិនកំណត់ តែខ្ញុំមិនដឹងយកទៅណាទេ ។ ខ្ញុំឃើញបងហ៊ី, ហ៊ុយ ធំនៅព្រៃស តាឌុច នៅទីនោះ ។ តា ឌុច គឺនៅអចិន្ត្រៃយ៍នៅក្នុងនោះតែម្តង ។ ពេលដែលគេដឹកអ្នកទោសចេញពេលយប់ គាត់នៅឈរមើលនៅមាត់ផ្លូវតែម្តង ។ គាត់ថា ពេលដែលយកទៅត្រូវឲ្យដឹងចំនួនប៉ុន្មាននាក់ គាត់ប្រាប់ទៅអ្នកបើកឡាន ។ ពេលខ្ញុំយាមនៅខាងក្រៅ ខ្ញុំឮសួរ ឌុច និយាយប្រាប់អ្នកបើកឡានផ្ទាល់ ។ ពេលឡានទៅបាត់អ្នកធំៗ គេចូលទៅកន្លែងគេវិញ ។ ខ្ញុំធ្លាប់ឃើញ ឌុច ជិះឡានផ្សេង តាមឡានដែលដឹកអ្នកទោសចេញ ។ ពេលគេនាំអ្នកទោសចូលមក មានកងពិសេសគេបណ្តើរចូលទៅក្នុងដើម្បីប្រគល់ឲ្យអ្នកយាមខាងក្នុង ។ កងពិសេសនោះ មាន ហ៊ុយ តូចជាមួយក្រុមគេនោះ ។ ពេលបណ្តើរនោះគេដាក់ខ្នោះដៃចងមុខបណ្តើរចូល ។ អ្នកទោសទាំងនោះមានស្រី មានប្រុសក្មេងចាស់ ។ ខ្ញុំមិនបានឃើញជនជាតិផ្សេងក្រៅពីយួនទេ ។ យួនស្លៀកពាក់ទាហានវៀតណាម ពាក់មួកដាក់ខ្នោះដៃនិងចងមុខ ។ ពេលខ្លះឃើញបីនាក់ ពេលខ្លះប្រាំនាក់ សរុបទៅប្រហែលរាប់រយនាក់ដែរ ។ ខ្ញុំក៏ធ្លាប់ឃើញ អ្នកសួរចម្លើយ នាំយកអ្នកទោសទៅសួរ និងនាំចូលមកវិញអ្នកខ្លះមានស្នាមរបួស ។

សំណួរ៖ ដែលឃើញអ្នកទោសមានផ្ទៃពោះទេ?

ចម្លើយ៖ ខ្ញុំឃើញមាន ។ ចំណែក ក្មេង ខ្ញុំមិនធ្លាប់ឃើញទេ ។ អ្នកទោសគ្រប់ខែ គេប្រាប់អ្នកយាមថា ឈឺពោះសម្រាលកូន ។ អ្នកយាមខាងក្នុងប្រាប់អ្នកយាមខាងក្រៅ ហើយអ្នកយាមខាងក្រៅហៅពេទ្យមកយកទៅសម្រាល ។ អ្នកទោសដែលសម្រាលកូន ឃើញមានញឹកញាប់ដែរ ។

សំណួរ៖ អ្នកទោសស្រី គេដាក់សុទ្ធតែស្រី ឬយ៉ាងណា?

[១៤:៤៦:០៩]

ចម្លើយ៖ អ្នកទោសស្រី គេដាក់សុទ្ធតែស្រីៗ ក្នុងបន្ទប់ធំ ។ អ្នកទោសដែលមានផ្ទៃពោះ គេដាក់ច្រវាក់កជើង ។ អ្នកទោសស្រីដែលចង់រករឿងជាមួយអ្នកយាម គេយកខ្នោះមកដាក់ ។

សំណួរ៖ ចុះការងូតទឹករបស់អ្នកទោស ការបត់ជើង បត់ដៃ ការផ្លាស់សម្លៀកបំពាក់វិញ?

ចម្លើយ៖ អ្នកយាមដូចខ្ញុំជាដើម ហុចទុយោឲ្យអ្នកទោសប្រុសងូតទឹកខ្លួនឯង ដោះខោអាវខ្លួនឯង ស្លៀកពាក់ខ្លួនឯង ដោយមិនចាំបាច់ដោះខ្នោះជើង ។ ហើយការបត់ជើង គេឲ្យបត់ជើងក្នុងបន្ទប់ដាក់ក្នុងកែសគ្រាប់ ។ ហើយអ្នកទោសស្រោលដើរយកក្នុងមួយថ្ងៃម្តង ។ ចំណែក អ្នកទោសស្រីវិញ គេដោះច្រវាក់ជើងឲ្យដើរទៅបន្ទប់ផ្សេង សម្លៀកបំពាក់ផ្លាស់ប្តូរខ្លួនឯង ។ ពេលនោះខ្ញុំតាមមើល ខ្លាចអ្នកទោសចងក ឬធ្វើឃាតខ្លួនឯង ។

សំណួរ៖ និយាយពីរចនាសម្ព័ន្ធវិញ តើ ប៉េង ដែលរុញក្បាលលោកគាត់ជាអ្វី?

ចម្លើយ៖ ប៉េង គឺជាវរសេនាធំ ក្រោម ហ៊ី និង ឌុច ។ ឌុច ជាប្រធាន និង ហ៊ី ជាអនុប្រធាន ។ ប្រវត្តិ ហ៊ី និង ប៉េង ខ្ញុំមិនបានដឹងទេ ។

សំណួរ៖ បងនិយាយថា ហ៊ុយ ជាកងពិសេស តើកងពិសេសហ្នឹង យ៉ាងម៉េចដែរ?

ចម្លើយ៖ កងពិសេសហ្នឹង គឺសម្រាប់ចាប់តែម្តង ។ កងពិសេសក៏ទៅចាប់អ្នកទោសមកពីខាងក្រៅផងដែរ ចាប់ពីតាមខេត្ត ឬយកពីសហករណ៍ ។ ហ៊ុយ តូចនៅក្នុងកងពិសេស តែមេៗទៀត ខ្ញុំមិនដឹងអ្នកណាទេ ។

សំណួរ៖ នៅក្នុងស-២១ បែងចែកជាអង្គភាពអ្វីខ្លះ?

ចម្លើយ៖ អង្គភាព២២ គឺអ្នកយាម ។ អង្គភាព២១ គឺអ្នកសួរចម្លើយ ។ ហើយគេមានបំបែកទៅអ្នកស្រែមាន ហ៊ុយ ធំ មានលេខគេផ្សេង ។ ក្រៅពីនោះ ខ្ញុំមិនបានដឹងទេ ។

សំណួរ៖ ពេលលោកយាមនៅខាងក្នុង តើធ្លាប់ឃើញ ឌុច ដើរមើលទេ?

[១៥:៤៨:៤៦]

ចម្លើយ៖ ខ្ញុំធ្លាប់ឃើញ ឌុច ដើរមើល តែមិនដែលនិយាយជាមួយខ្ញុំទេ ។ ពេលដែលឃើញខុសអ្វី ឌុច ប្រជុំជាមួយ ប៉េង ។

សំណួរ៖ តើលោកធ្លាប់ឃើញ ឌុច នៅកន្លែងណាផ្សេងទៀតទេ?

ចម្លើយ៖ ធ្លាប់ឃើញ ឌុច ពេលរៀនសូត្រចំនួនពីរដង គឺពេលដែលខ្ញុំទៅរៀននយោបាយ ។ គេលើកពីប្រទេសជាតិយើង យើងត្រូវកសាងប្រទេសយើង ឲ្យទៅជាសង្គមនិយម ។ ការធ្វើស្រែពីបីតោនទៅប្រាំពីរតោន ហើយយើងអ្នកធ្វើការសព្វថ្ងៃធ្វើឲ្យបានខ្លាំង ដូចអ្នកស្រែ ។ គេដាក់ពាក្យស្លោកថា “កម្លាត់ខ្មាំងម៉ែឪ កម្លាត់ខ្មាំងម៉ែឪក៏ជាខ្មាំង ហើយក៏អាចសម្លាប់បានដែរ យកតែមនុស្សល្អទេ ដែលធ្វើជាម៉ែឪបាន” ។ នៅក្នុងវគ្គខ្ញុំរៀនផ្ទាល់ ខ្ញុំឃើញ ប៉េង និង ឌុច ទេ តែអ្នកដែលរៀនវគ្គផ្សេងៗ ថាមាន ប៉ុល ពត, ខៀវ សំផន, នួន ជា មកបង្រៀនដែរ ។ ខ្ញុំបានឮពេលដែលគេចេញពីរៀននិយាយប្រាប់ពេលដែលខ្ញុំឈរយាម ។ នៅក្នុងបន្ទប់សាលារៀន គេដាក់រូបថត នួន ជា, ខៀវ សំផន, ប៉ុល ពត និងដាក់អក្សរពីក្រោម ។

សំណួរ៖ និយាយពីការគ្រប់គ្រងវិញ តើ ឌុច មានទំនាក់ទំនងល្អជាមួយ ហ៊ី ទេ?

ចម្លើយ៖ ខ្ញុំមិនដឹងរឿងអ្វីទេ គេចាប់ ហ៊ុយ ធំ តែក្រោយមកគេចាប់ ហ៊ី ហ្នឹងយកទៅដែរ ។ ខ្ញុំឃើញគេបណ្តើរ ហ៊ី ទៅសួរចម្លើយ ។

សំណួរ៖ តើ ឌុច ជាអ្នកតែងតាំងបុគ្គលិក ឬអ្នកណាផ្សេងជាអ្នកចាត់តាំង?

ចម្លើយ៖ ខ្ញុំមិនដឹងទេ ខ្ញុំគ្រាន់តែដឹងថា គាត់ជាអ្នកគ្រប់គ្រង ហើយគាត់មិនដែលដាក់វិន័យផ្ទាល់ដល់ខ្ញុំទេ។ វិន័យនៅស-២១ ដែលខ្ញុំចាំ ខ្ញុំអ្នកការពារដឹងតែពីការពារ មិនឲ្យដឹងរឿងអ្វីផ្សេង មិននិយាយជាមួយអ្នកផ្សេង ។

សំណួរ៖ មានដែលគេពិន័យចំពោះអ្នកយាមឯក់ផ្សេងទៀតទេ?

ចម្លើយ៖ បាទមាន ។ ឃើញចាប់មកពីគ្រប់អង្គភាព ខាងការពារ ខាងសួរចម្លើយ កងពិសេសមានច្រើន ហើយយកមកដាក់ក្នុងគុកនេះដដែល ។

សំណួរ៖ តើលោកធ្លាប់បានឃើញ ឌុច ធ្វើទារុណកម្មទេ?

ចម្លើយ៖ ខ្ញុំមិនដែលធ្លាប់បានឃើញទេ ។

សំណួរ៖ តើលោកស្គាល់អ្នកឆ្លាក់ អ្នកធ្លាប់ធ្វើការនៅស-២១ ផ្សេងទៀតទេ?

ចម្លើយ៖ ខ្ញុំធ្លាប់ឃើញ ចាន់ សម្រែង នៅរស់ ខ្ញុំជួបគាត់ពេលទៅរកស៊ីប៉ុន្មានឆ្នាំមុន នៅតាស្ការ ជាយដែន ។ តួនាទីគាត់ធំដែរ គាត់នៅជាមួយតា ឌុច ។ ឈ្មោះ ប៉ុន ត្រូវគេចាប់ក្នុងនោះផងដែរ គាត់មានសម្បុរស ទាបល្មម ។ ពេលដែលគេបណ្តើរគាត់ ខ្ញុំស្គាល់មុខច្បាស់ណាស់ ។ ពេទ្យឈ្មោះ ហ៊ី ត្រូវបានគេចាប់ មានពេទ្យឈ្មោះ សឿង តែខ្ញុំមិនដឹងគេចាប់ឬអត់ទេ ។ មានពេទ្យឈ្មោះ ដន មិនដឹងនៅរស់ ឬស្លាប់ ។ មានឈ្មោះ ឆេន នីរសាររបស់ ឌុច មិនដឹងនៅរស់ ឬស្លាប់ មិនដឹងស្រុកកំណើត ។ គាត់មានសម្បុរស រាងស្តើង ។

[១៥:៥៣:១៥]

សំណួរ៖ ពេលវៀតណាមចូលលោកនៅឯណា?

ចម្លើយ៖ ថ្ងៃនោះ មិនទាន់ដល់វេនខ្ញុំយាមទេ ពេលឮសូរគ្រាប់កាំភ្លើងក៏នាំគ្នារត់មកលិច អស់រយៈពេលពីរខែទើបដល់ទឹកដីថៃ ហើយមកដល់ស្រុកកំណើតវិញនៅពេលមាតុភូមិនិវត្តន៍ មុនពេលបោះឆ្នោតអ៊ុនតាក់ ។

ឯកសារថតចម្លងនៃកំណត់ហេតុមួយច្បាប់ ត្រូវបានប្រគល់ឲ្យសាក្សីនេះ ។

អានឲ្យស្តាប់ហើយសាក្សី មិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ។"

**ប្រធានអង្គជំនុំ៖**

បន្ទាប់ពីស្តាប់នូវការអានសក្ខីកម្ម របស់សាក្សី អៀម ហ៊ាន មក តើតំណាងសហព្រះរាជអាជ្ញាមានអ្វីកត់សម្គាល់លើខ្លឹមសារ នៃកំណត់ហេតុនេះដែរឬទេ?

**លោក តាន់ សេណារ៉ុង៖**

សូមគោរពលោកប្រធានអង្គជំនុំជម្រះ តំណាងសហព្រះរាជអាជ្ញា គ្មានការកត់សម្គាល់អ្វីទៅលើឯកសារនេះទេ ។

**ប្រធានអង្គជំនុំ៖**

ខាងមេធាវីអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី តើមានអ្វីចង់កត់សម្គាល់លើសក្ខីកម្មរបស់សាក្សី អៀម ហ៊ាន ដែលអានដោយក្រឡាបញ្ជីអម្បាញ់មិញនេះដែរឬទេ? គឺឯកសារ D28/5 ។

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក៏មិនមានអ្វីកត់សម្គាល់លើឯកសារលេខ D28/5 នេះទេបាទ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ចុះខាងមេធាវីការពារក្តី តើមានអ្វីចង់កត់សម្គាល់ដែរឬទេលើឯកសារនេះ?

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។ មេធាវីការពារក្តីក៏គ្មានអ្វីកត់សម្គាល់លើឯកសារនេះដែរ ។

សូមអរគុណ ។

[១៥:៥៥:១២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះទុកឱកាសដល់ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់លើខ្លឹមសារនៃសក្ខីកម្មរបស់សាក្សី អៀម ហ៊ន ដែលបានផ្តល់សក្ខីកម្មនៅចំពោះអ្នកស៊ើបអង្កេត ឯកសារ D28/5 ដែលអានដោយក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ។ សូមអញ្ជើញបាទ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! មុននឹងខ្ញុំបាទមានមតិអំពីសក្ខីកម្មរបស់លោក អៀម ហ៊ន ហៅ ម៉ឺង នេះ ខ្ញុំសូមកែតម្រូវពាក្យខ្ញុំមួយម៉ាត់ពីមុននេះ ។ សន្និបាតស-២១ ឆ្នាំ១៩៧៧ ដែលលោកគ្រូ សុន សេន គាត់អញ្ជើញចុះ មិនមែននៅថ្ងៃ ១៤ មេសា ទេ គឺនៅថ្ងៃ ២៧ មេសា ។ នេះខ្ញុំសូមកែតម្រូវពាក្យខ្ញុំដែលបាននិយាយអម្បាញ់មិញនេះ ។

តទៅនេះ ខ្ញុំសូមធ្វើការចាប់អារម្មណ៍អំពីសក្ខីកម្មរបស់លោក អៀម ហ៊ន ហៅ ម៉ឺង ។ ដំបូងខ្ញុំសូមបញ្ជាក់ថា សាមីខ្លួននៅព្រៃកក្រសា បើតាមខ្ញុំសួរគេសួរឯង ព្រៃកក្រសា នៅប្រហែលជាពីរគីឡូម៉ែត្រកន្លះពីតាខ្មៅ គឺនៅសង្កាត់ស្វាយរលំ ។ ដូច្នេះ បុគ្គលនេះនិយាយថា គាត់ចូលកងទ័ព ខ្ញុំដូចជាមានការចាប់អារម្មណ៍សង្ស័យ ព្រោះគេមិនយកយុវជនជម្លៀសទៅធ្វើកងទ័ពទេ នេះជាបញ្ហាមួយ ។

បញ្ហាទីពីរ ខ្ញុំមិននិយាយល្អិតដល់កន្លែង*ប៉ៃហ្ស៊ី* ទេ ព្រោះកន្លែងហ្នឹងវាបាត់ហើយ គ្រាន់លក្ខណៈក្នុងសក្ខីកម្មនេះ ហាក់ដូចជាប្លែក ។ រឿងដែលខ្ញុំសូមកត់សម្គាល់ទីពីរ គឺបុគ្គលលោក អៀម ហ៊ន ហៅ ម៉ឺង នេះ មានប្រសាសន៍ថា ប៉េង ចាប់ដាក់គុក ដោយបានការសម្រេចពីលើទៅ សំដៅ គឺពីខ្ញុំ ដោយសារតែរឿងយាមងក់ នេះជាចំណុចទីពីរ ។ ហើយក្រោយមកគាត់មានប្រសាសន៍ថា គាត់រួចវិញ នេះគឺជាចំណុចសង្កេតទីបី ។ ទន្ទឹមនេះ គាត់មានប្រសាសន៍ថា មិត្តទុយ ជាកម្មាភិបាលសួរចម្លើយម្នាក់របស់ខ្ញុំគាត់ត្រូវចាប់ មិត្តហ៊ី អនុលេខារបស់ខ្ញុំក៏ត្រូវចាប់ មិត្តប៉ុន ជាអ្នកសួរចម្លើយដែលខ្ញុំជឿទុកចិត្តបំផុតក៏

ត្រូវចាប់ ។

សរុបមក សក្ខីកម្មរបស់មិត្ត អៀម ហ៊ន នេះ ខ្ញុំគិតថា មានលក្ខណៈប្រហាក់ប្រហែលគ្នារបស់សក្ខីកម្មរបស់KW-31 ធ្វើឲ្យខ្ញុំមានមន្ទិលសង្ស័យថា បុគ្គលរូបនេះមិនមែនជាបុគ្គលិករបស់មន្ទីរស-២១ ។ នេះខ្ញុំសូមសរុបជូនប៉ុណ្ណេះ ។ សូមគោរព ហើយសូមចប់ ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ម៉ោងបួនហើយ ហើយការអាននូវកំណត់ហេតុមួយៗត្រូវប្រើចំណាយពេលវេលាកន្លះម៉ោងរហូតដល់ទៅមួយម៉ោង ទាំងការកត់សម្គាល់ផ្សេងៗរបស់ភាគី ហើយដោយសារនៅសល់តែដប់ប្រាំមីនុតប៉ុណ្ណោះ ដល់ពេលត្រូវសម្រាក ។ ហើយបើសិនជាអានតទៅទៀត ក៏មិនអាចអានចប់ដែរដូច្នេះ អង្គជំនុំជម្រះសម្រេចផ្អាកសវនាការថ្ងៃនេះត្រឹមនេះ ។ ហើយសវនាការលើកទៅបន្តធ្វើនូវថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹកទៅ ។ ហើយនៅថ្ងៃស្អែកនេះនៅពេលព្រឹកអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សី KW-29 ហើយពេលនៅសល់ អង្គជំនុំជម្រះនឹងអាននូវកំណត់ហេតុស្តាប់សក្ខីកម្មសាក្សី ដែលអង្គជំនុំជម្រះសម្រេចមិនកោះហៅមកឆ្លើយនៅចំពោះមុខអង្គសវនាការបន្ត ហើយនងប្រឹងប្រែងឲ្យចប់នូវសាក្សីការអានកំណត់ហេតុសាក្សីនៅរសៀលថ្ងៃស្អែក ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង ១៦:០១នាទី]*